ការិយាល័យមេធាវីខ្មែរ
LAW OFFICE OF
Stewart H. Lim & Associates
Stewart H. Lim
Car Accident, Child Support, Immigration, Divorce, Bankruptcy, Living Trust, Defense you in Court
Main Office
100 Oceangate Blvd., Suite 1200, Long Beach, CA 90802
(562) 590-7181 FREE CONSULTATION



# ខ្មែរប៉ុស្តិ៍ Khmer Post



ឱសថស្ថាន ខ្មែរថ្ងៃនេះ
Today Pharmacy
សូមស្វាគមន៍ !
Fast and Friendly Service
Today Pharmacy
FREE DELIVERY
• ទទួលយកទាំង Medicare & Medical និង Insurance ។
2200E. Anaheim St. #C Long Beach, CA 90804
Tel: (562) 438-2031 . Fax: (562) 438-2031
(2 Blocks East of Cherry Ave.)



KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 | ISSUE 11 | March 25th - April 15th | 2008 | ADVERTISING (562) 313-2129 | WWW.THEKHMERPOST.COM


# ដំណើរទៅកាន់ខ្ទមកុមារីបេះដូងប្រហោង


ឃើញតែខ្ទមម្ចាស់នៅឯណា

## ប្រពាច់កចិន លោនអណ្តាតខ្មែរ

***ភ្នំពេញ : គីម សារឿន***

ចាប់តាំងពីតម្លៃសាំងឡើងថ្លៃខ្ពស់ រយៈពេលជិតមួយឆ្នាំកន្លងមកនេះ ទំនិញសព្វសារពើនៅទីផ្សារក៏ឡើងតាមដែរ ។ បញ្ហាទំនិញឡើងថ្លៃគ្មានមធ្យោបាយទប់ស្កាត់នេះ ធ្វើឱ្យអ្នកលក់ និងអ្នកទិញរអ៊ូរទាំដាក់គ្នាមិនឈប់ថា **(តនៅទំព័រទី០៨ )**

## ហ៊ុន សែន ប្រមាថអ្នកដែលនិយាយពីទឹកដីកម្ពុជាក្រោម

***ឡុង ប៊ិះ សុភាឫទ្ធិ***

ជនជាតិនានានៅលើពិភពលោក មេដឹកនាំរបស់គេតែងតែបណ្តុះទឹកចិត្តឱ្យប្រជាពលរដ្ឋស្រឡាញ់ការពារ និងក្រោកឡើងទាមទារបូរណភាពទឹកដីដែលបានបាត់បង់មកវិញឱ្យខានតែបាន ។

ដោយឡែកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានចរិតចំឡែកខុសគេឱ្យតែសកម្មជនសិទ្ធិមនុស្ស អ្នកនយោបាយ និង **( តនៅទំព័រទី០៩ )**

***បាត់ដំបង : គីម សារឿន***

●●●បន្ទាប់ពីកាសែតខ្មែរប៉ុស្តិ៍ធ្វើការចុះផ្សាយអំពីដំណើរមកកាន់ការវះកាត់បេះដូងប្រហោងរបស់កុមារី តេង ដាវិក ដ៏អភ័ព្វនៅសហរដ្ឋអាមេរិក ក្រោមគំនិតផ្តួចផ្តើមរបស់លោក Peter Chhun ជាផលិតករទូរទស្សន៍ដ៏ល្បីមួយរូបរបស់អាមេរិកឈ្មោះ NBC និងជាប្រធានអង្គការបេះដូងគ្មានព្រំដែនកន្លងមកនោះ ។

សប្បុរសជនខ្មែរដែលរស់នៅឯនាយសមុទ្រ **(តនៅទំព័រទី១៥ )**


ពិនិត្យសុខភាពមុនធ្វើការវះកាត់

## ចៅហ្វាយក្រុងច្រានចោលការអញ្ជើញ សុខ អាន

### កម្មករសំណង់ក្លាយជាអ្នកគ្រប់គ្រង V.O.A នៅស្រុកខ្មែរ

***ភ្នំពេញ : សម្ផស្ស***

●●●ទោះបីជាយើងស្ថិតនៅក្នុងស្ថានភាពក្រលំបាកយ៉ាងណាក៏ដោយឱ្យតែមានសេចក្តី តស៊ូ អត់ធ្មត់ មានឆន្ទៈមុតស្រួចនិងគោលដៅច្បាស់លាស់ ប្រាកដជាបានសំរេច (តនៅទំព័រទី០៩)



***ឡុងប៊ិច : មាជ សុវណ្ណារ៉ា***

●●●កាលពីដើមខែមីនានេះ ចៅហ្វាយក្រុង Long Beach, Bob Foster បានច្រានចោលការអញ្ជើញលោកឧបនាយករដ្ឋមន្ត្រីខ្មែរ សុខ អាន ដោយបញ្ជាក់ថា ការិយាល័យរបស់លោកពុំបានចេញលិខិតអញ្ជើញអ្នកដឹកនាំខ្មែរណាមួយឱ្យមកចូលរួម **( តនៅទំព័រទី១២ )**


PHNOM PENH express
ក្រុមហ៊ុនទទួលផ្ញើប្រាក់ និងលក់សំបុត្រយន្តហោះ

Law Offices of Boroth Chay
No Recovery . No Fees ! New Location
2501Cherry Ave , Ste.245 , Signal Hill , CA 90755
Office: (562) 997- 8500 . Direct : (562) 453 - 5898

TOP AUTO INSURANCE AGENCY
Free Quote, Low Rates, LOW MONTHLY
AUTO-LIFE-HEALTH-HOME-COMMERCIAL
⇒រថយន្ត ⇒ជីវិត ⇒សុខភាព ⇒គេហដ្ឋាន ⇒ហាងពាណិជ្ជកម្ម
នាងខ្ញុំនិយាយភាសាខ្មែរ សូមទូរស័ព្ទទាក់ទង
Tel: (562) 989-1800
Tiffany Prak
Agent/Broker Lic.0E44334
2760E. Spring St., Ste 140 . Long Beach, CA 90806

FARMER INSURANCE
Douglas Horn Agency
License #0B83665
Life Insurance, Home Insurance, Business Insurance, Auto Insurance, Health Insurance, One Stop Service, Bail Bond,
1360E Anaheim St., Ste 203 , Long Beach CA 90813
Tel: (562) 591- 3100 Fax : (562) 591- 3911

ក្រុមហ៊ុនធានារ៉ាប់រង State Farm
Peter Kong Insurance Agency
■ Business Liability Insurance
■ Auto Insurance
■ Home Insurance
■ Life Insurance
■ Health Insurance
■ Apartement Insurance
■ Disability Insurance
■ Family & Individual Coverage
Savannara + Sokha
(Notary Public)
2750E. Spring Street, Suite 201, Long Beach, CA 90806
Tel: (562) 426-9189 Fax: (562) 426-4669




# ក្រុមហ៊ុនអង្គរទេសចរណ៍
# Angkor Travel

## ការជ្រើសរើសតែមួយគត់សំរាប់ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា

- ទទួលបំរើកិច្ចការធ្វើដំណើរក្នុងសហរដ្ឋ និងអន្តរជាតិ ។
- តម្លៃសំបុត្រលក់ចុះថ្លៃជាពិសេសសំរាប់ការធ្វើដំណើរក្នុងស្រុកចេញពីចំណតយន្តហោះ LAX ទៅកាន់គ្រប់ទីក្រុងក្នុងសហរដ្ឋអាមេរិក ។
- មានលក់កាតសំរាប់ទូរស័ព្ទដិរិញពិភពលោក ( លក់ដុំ និងលក់រាយ) ។
- ទទួលធ្វើ Re-Entry Permit លិខិតឆ្លងដែន ។
- ទទួលធ្វើ Re-Entry Permit ប្រញាប់ជូនភ្លាមៗ!!!
- ជួយរកតម្លៃសំបុត្រយន្តហោះថោកជាងគេទៅស្រុកខ្មែរតាមរយៈក្រុមហ៊ុន Eva Air , Cathay Pacific,Malaysia Air , Singapore Air.

**បើលោកអ្នកចង់ដឹងតម្លៃពិសេស សូមអញ្ជើញទាក់ទងនាងខ្ញុំ**

**Tel: (562) 599-0877 , Fax: (562) 599 4758**

1569 E. Anaheim St.,C Long Beach ,
CA 90813 (កាច់ជ្រុងផ្លូវ Anaheim & Walnut)

## Cellphonatic
Wireless Super center

យើងខ្ញុំមានលក់កាតទូរស័ព្ទ ទិញដាក់បញ្ចូលទឹកលុយទៅក្នុងទូរស័ព្ទដៃ និងទូរស័ព្ទនៅផ្ទះបានភ្លាមៗ!!!

*NO CONNECTION FEE !*
*NO EXPIRATION DATE !*

metroPCS No te limites.

FREE PHONE !!!

តម្លៃត្រឹមតែ $30 ក្នុងមួយខែ !





## បណ្ណាធិការ និងថាងហ្វាងការផ្សាយ

| | | |
|---|---|---|
| | : | លោក មាដ សុវណ្ណារ៉ា |
| ប្រធានក្រុមទីប្រឹក្សា | : | លោក ពិន សំខុន |
| និពន្ធនាយក | : | លោក គីម សារឿន |
| និពន្ធនាយករង | : | លោក សួន សលា |
| ការិយាល័យទំនាក់ទំនង | : | លោក ឯល ម៉ាន់ថា |
| ប្រធានបច្ចេកទេសកុំព្យូទ័រ | : | លោក ឌុក ឌុន្នី |
| ការិយាល័យនិពន្ធ | : | ឡុង ប៊ិច : (562) 5914 902 / ភ្នំពេញ : (855) 177 390 61 |
| ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម | : | (562) 3132 129 |

Long Beach : E-mail : Sovannaram04 @yahoo.com / websibe : www.thekhmerpost.com
Philadelphia: 5730 Rising Sun Ave Philadelphia, PA 19120 Phone : (267) 254-8758


## ផ្សាយពាណិជ្ជកម្មជាមួយខ្មែរប៉ុស្តិ៍

- បានទៅដល់ដៃលោកអ្នកគ្រប់ទិសទី
- លោកអ្នកនឹងបានចំរើនក្នុងកិច្ចការងារ និងរបររកស៊ីរបស់លោកអ្នក ។
- កាសែតខ្មែរប៉ុស្តិ៍មានចែកចាយដល់សហគមន៍ខ្មែរនៅទូទាំង ស.អ.រ ។
- ទំនាក់ទំនងទូរស័ព្ទផ្ទាល់លេខ: (562) 313-2129



TOYOTA
HOOMAN
TOYOTA
Of Long Beach
TOYOTA
On the Road to 2 MILLION Sold!
CERTIFIED
CHUCK CHET
Cambodian Sale Managers
LINDA HING
► គ្មានក្រេឌីត, ខូចក្រេឌីត, ក្ស័យធន, អត់មានបញ្ហា
► យើងខ្ញុំជួយសំរួលកិច្ចការជូនលោក-អ្នក
► យើងខ្ញុំជាខ្មែរ មានបទពិសោធន៏ជាង 20 ឆ្នាំ
ជាមួយជំនាញលក់ឡាន និងមានទំនាក់ទំនងល្អ
ក្នុងសហគមន៏ខ្មែរ ។
► សូមមេត្តាទូរស័ព្ទផ្ទាល់មកលេខខ្ញុំ : (562) 325-9647
បើលោកអ្នកមានបំណងចង់ទិញឡានពីក្រុមហ៊ុន TOYOTA យើងខ្ញុំ ។
UP TO $4,000 Rebate
91
710
LAKEWOOD
AT THE CIRCLE
405
605
TRAFFIC CIRCLE
PCH
7TH STREET
22
4401E. Pacific Coast Highway Long Beach, CA 90804
Phone: (562) 494- 4444 / Fax: (562) 494-1350


DARANY´S FASHION
ហាងយើងខ្ញុំមានលក់
.Beauty Suplies . Phone Card .
ម៉ៅលាបបំបាត់មុន.ជាំមុខ. ឡេចិញ្ចឹមស្បែកឱ្យបានស្អាត
ហាងយើងខ្ញុំមានសំលៀកបំពាក់ខ្មែរដែលរចនាម៉ូដដោយជាងចំណានៗ
ធ្វើពី ហូល ផាមួង និងក្រណាត់ប៉ាក់ មានតុបតែងមុខសំរាប់ពិធីផ្សេងៗ.
មានលក់ថ្នាំបញ្ចុះទម្ងន់ មានទទួលផ្ញើរអីវ៉ាន់ និងគ្រឿងសម្ភារៈផ្សេងៗ
ទៅកាន់ស្រុកខ្មែរ ។
.ថ្នាំម៉ាស្សាត្រាំទឹកដោះគោ .ឡេម្សៅល្មៀតលាបខ្លួន
.គ្រឿងអលង្ការធ្វើពីប្រាក់ .គ្រឿងលំអគ្រប់ប្រភេទ
Open 10:00 AM-6:00PM
( MON,SAT )
& 10:00 AM-5:00 PM
( SUNDAY )
DARANY´S FASHION
មានសំលៀកបំពាក់ស្អាតៗ
គ្រប់ម៉ូដសំរាប់ពិធីមង្គលការ,
ជប់លៀង និងសំរាប់ទៅវត្ត
នៅឱកាសបុណ្យចូលឆ្នាំថ្មី ៖
បញ្ចុះតម្លៃពិសេស
១៥%ពីថ្ងៃនេះ
រហូតដល់ថ្ងៃបុណ្យចូលឆ្នាំ
2201E. Anaheim St.# 102 . Long Beach, CA 90804
Store : (562) 438-2488 . Cell: (562) 786-2095


GRAND OPENING SPECIAL!!
Limited time offer!!
K WIRELESS
13858 Chase Street | Panorama City, CA 91402
kaywireless@gmail.com
$39.99 PLAN
1000 Anytime Mins
Unlimited Night & Weekend
Unlimited Mobile-to-Mobile
SE S500i
Motorola W510
Samsung Black Jack
NOKIA N72
LG KE970 Shine
Samsung D900i
LG KE800 Choco
Motorola V3
Samsung D840
NOKIA 7500
SE W830i
LG KE770 Shine
FREE!
ជូនសំបកទូរស័ព្ទដោយឥតគិតថ្លៃ
verizonwireless
Palm Treo 700P
BlackBerry Pearl
LG Voyagers
Samsung Flipshot
LG VX990 ENV
LG VX8550 Choco
T-Mobile™ • Verizon Wireless™. All offers will expire on April 1, 2008. Offer requires a two years contract.
$69.99 FAMILY PLAN
FREEPhones!!
with qualifying airtime plans
& bluetooth headset
while supplies last
FREE!
SE T650i
SE W880i
Samsung BlackJack II
NOKIA N73
Motorola Q
Samsung G600
FREE!
SE K530i
Motorola V8
Samsung U600
NOKIA 5700
NOKIA 6280
SE K800i
សូមអញ្ជើញទាក់ទងនាងខ្ញុំ Tiffsany (626) 228-7189
P 818.895.2623 | F 626.675.8523
UNLOCKED & IMPORTS
Iphone 16G
Nokia N96
SE P1
LG Prada
SE K850i
Samsung Armani

# នរណាជាអ្នកឈ្នះ ហ៊ីឡារី ឬបារ៉ាក់ ?

***ហ៊ីឡារីដែលហ៊ីយ៉ា : ពិន សំខុន***

សេចក្តីសង្ឃឹមថា "គេនឹងឃើញបេក្ខជនណាម្នាក់ ក្នុងចំណោម ហ៊ីឡារី គ្លីងតុន និង បារ៉ាក់ អូបាម៉ា នឹងលេចធ្លោចេញពីលទ្ធផលនៃការបោះឆ្នោតជុំទី១ (PRIMARY) សំរាប់អាណត្តិប្រធានាធិបតីថ្មីជាមិនខាន ក៏ប៉ុន្តែគេបែរជាចិត្តទៅវិញ ដោយ បារ៉ាក់ នៅតែមិនឈ្នះ ហ៊ីឡារី នៅតែមិនចាញ់ដដែលមិនតែប៉ុណ្ណោះ ការស្មុគស្មាញក្នុងគណបក្សប្រជាធិបតេយ្យអាមេរិកាំងរឹតតែខ្លាំងថែមទៀត ។ ការបោះឆ្នោតកាលពីថ្ងៃទី៤ មីនា នោះ បានទទួលលទ្ធផលពីរចំណុច :

**១**-លោក ជន ម៉ាកេន ព្រឹទ្ធសភាសហរដ្ឋ



John Mcaim (Repuplican Party)



Hillary Clinton (Democratic Party)



Obama (Democratic Party)

អាមេរិក បានទទួលការគាំទ្រពីប្រតិភូគណបក្សសាធារណរដ្ឋគ្រប់គ្រាន់ ហើយបានទទួលការតែងតាំងជាបេក្ខជនប្រធានាធិបតីនៃសហរដ្ឋអាមេរិក ខាងគណបក្សសាធារណរដ្ឋជាផ្លូវការរួចហើយ ។

**២**-ខាងគណបក្សប្រជាធិបតេយ្យវិញ លោក បារ៉ាក់ អូបាម៉ា (Barak Obama) និងលោកស្រី ហ៊ីឡារីគ្លីងតុន (Hilary Clinton) នៅតែទទួលលទ្ធផលកៀកកិតគ្នានៅឡើយ ។ លោកស្រី ហ៊ីឡារី បានឈ្នះឆ្នោតនៅតំបន់តិចសាស, អូហាយ៉ូ និងរ៉ូដអាឡិន ក៏ប៉ុន្តែផ្ទុយនឹងសេចក្តីសង្ឃឹមរបស់ ហ៊ីឡារី លោកស្រីនៅតែចាញ់លោក អូបាម៉ា នូវចំនួនប្រតិភូប្រមាណ១០០សំលេងនៅឡើយ ។ លទ្ធផលនៅរដ្ឋតិចសាសនេះ បានត្រូវអ្នកវិភាគព័ត៌មាននិយាយថា "គេអាចបោះឆ្នោតបានពីរដងតាមច្បាប់រដ្ឋតិចសាស់ ហើយសមាជិកគណបក្សសាធារណរដ្ឋ ក៏អាចបោះឆ្នោតឱ្យគណបក្សប្រជាធិបតេយ្យបានដែរ អ្នកវិភាគបានពិពណ៌នាទៀតថា ពួកសាធារណរដ្ឋមានការព្រួយបារម្ភខ្លាច អូបាម៉ា ឈ្នះ ហ៊ីឡារី ហេតុនេះគេត្រូវសំរុកបោះឆ្នោតឱ្យ ហ៊ីឡារី ឱ្យបានច្រើនដើម្បីទប់ស្កាត់កុំឱ្យ អូបាម៉ា ឡើងមករួច ។ ចំណុចនេះ បានត្រូវគាំទ្រដោយការស្ទង់មតិដ៏សំខាន់មួយ ដែលនិយាយថា បើជន ម៉ាកេន ឈរឈ្មោះទល់នឹង ហ៊ីឡារី លោក ម៉ាកេន នឹងឈ្នះ តែបើលោកឈរប្រកួតនឹង បារ៉ាក់ វិញ លោក ម៉ាកេន នឹងចាញ់ ហេតុនេះហើយបានជាឆ្នោតពួកសាធារណរដ្ឋត្រូវបោះឱ្យលោកស្រី ហ៊ីឡារី ទៅវិញ ។

តើទៅអនាគតឆ្នោត ហ៊ីឡារី និង បារ៉ាក់ នឹងអាចឃ្លាតគ្នាឆ្ងាយបានទេ ? នៅខែមេសា ខាងមុខ គឺជាការបោះឆ្នោតនៅរដ្ឋផែនស៊ីវ៉ាញ៉ា (Pen-sylvania) ដែលសំបូរទៅដោយជនជាតិស្បែកខ្មៅ គេប៉ាន់ស្មានថា លោក បារ៉ាក់ មុខតែនឹងឈ្នះនៅទីនោះ ។ ការព្រួយបារម្ភនេះ បានធ្វើឱ្យលោក ប៊ិល គ្លីនតុន ជាស្វាមី និងជាអតីតប្រធានាធិបតីបានមកដល់ផែនស៊ីវ៉ាញ៉ានេះ ដើម្បីធ្វើការឃោសនាជួយភរិយារបស់លោកមុនគេ គឺមកដល់កាលពីព្រឹកថ្ងៃសុក្រ ទី៧ មីនា នេះរួចហើយ ។

ឥឡូវនេះ ព័ត៌មានថ្មីមួយទៀតបានធ្លាក់មកដល់ គឺបេក្ខភាពខាងគណបក្សប្រជាធិបតេយ្យត្រូវការសម្លេងប្រតិភូគាំទ្រចំនួន២០២៥នាក់ ដើម្បីធ្វើការតែងតាំងបេក្ខជនរបស់ខ្លួនជាផ្លូវការ បានគំនិតនេះបានត្រូវខូចខាតអស់រលីង ដោយសារតែទោះបីជាពីពេលនេះទៅ មានបេក្ខជនណាម្នាក់ឈ្នះ ( **តទៅទំព័រទី១៣** )

# ហ៊ុន សែន តែងតាំងទីប្រឹក្សាច្រើន សំរាប់បំរើជាតិ ឬដើម្បីការពារអំណាច?

***ឡុង ប៊ិច : សុភាបុទ្ធិ***

នៅប្រទេសកម្ពុជាសព្វថ្ងៃគណបក្សនយោបាយក៏ច្រើន មន្ត្រីរាជការពុករលួយក៏ច្រើន ហើយទីប្រឹក្សាក៏ច្រើនដែរ ។ ការតែងតាំងទីប្រឹក្សានោះ មិនទុកសំរាប់ធ្វើគ្រូអាចារ្យនោះទេ គឺអ្នកទាំងនោះជាអ្នកស្វែងរកលាភសក្ការៈ និងអំណាចតែប៉ុណ្ណោះ ។

ទីប្រឹក្សានៅស្រុកខ្មែរភាគច្រើន មិនមែនជាអ្នកចេះដឹង ឬអ្នកផ្តល់ដំបូន្មានសំរាប់ជាប្រយោជន៍ជាតិនោះទេ តែពួកគេទាំងនោះជាអ្នករកស៊ី អ្នកចំរៀង ឬចិនកាប់ជ្រូកទៅវិញ ។ បើអ្នកនយោបាយច្រើនជាអ្នកលើចញ្ចើ រត់សំលឹងឃើញផលប្រយោជន៍ផ្ទាល់ខ្លួន ក្បត់បក្សរបស់ខ្លួន ទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។ ប្រឹងធ្វើការទាំងយប់ទាំងថ្ងៃនោះ បានប្រាក់ខែតែ២០ដុល្លារប៉ុណ្ណោះ ។

ទីប្រឹក្សាដែលតែងតាំងភាគច្រើន ជាបក្ខពួករបស់លោក ហ៊ុន សែន ដើម្បីបំរើផលប្រយោជន៍ក្រុមរបស់ពួកគេប៉ុណ្ណោះ ។ ទីប្រឹក្សាមួយចំនួនពេលបានងារហើយ ទៅរកស៊ីខុសច្បាប់គំរាមកំហែងយកដីធ្លីអ្នកស្រុក ខ្លះទៀតរកស៊ីមិនបង់ពន្ធ ដោយយកផ្លាកទីប្រឹក្សាទៅសំឡុតមន្ត្រីរាជការតូចតាច ។

ថ្មីៗនេះ អ្នកដែលមានឋានៈគណៈកម្មការនាយកគណបក្ស សម រង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិចមួយចំនួន ទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ត្រូវលោក ហ៊ុន សែន តែងតាំងជាទីប្រឹក្សា មានឋានៈស្មើរដ្ឋមន្ត្រី និងទេសរដ្ឋ



លោកស្រី អ៊ុង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី



លោក ល៊ី ធុច អនុប្រធានរៀបចំបោះឆ្នោត

បើតាមការប៉ាន់ប្រមាណ ទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ទាំងផ្ទាល់ និងមិនផ្ទាល់នោះជិត១០០០នាក់ ដែលម្នាក់ត្រូវចំណាយប្រាក់ខែ៧៥០ដុល្លារ និងថ្លៃសេវាផ្សេងៗទៀត ។ ទីប្រឹក្សាដ៏ច្រើនមហិមានេះ បានធ្វើឱ្យប៉ះពាល់ដល់ថវិកាជាតិយ៉ាងច្រើន ចំណែកឯមន្ត្រីរាជការថ្នាក់កណ្តាល ដែលមានចំណេះដឹងពិតប្រាកដមន្ត្រី ។

សកម្មភាពរបស់លោក ហ៊ុន សែន នេះត្រូវបានគេមើលឃើញថា មានចរិតនយោបាយបំបែកបំបាក់គណបក្សផ្សេងៗ តាមរយៈការផ្តល់តួនាទីលុយកាក់ មុនពេលយុទ្ធនាការបោះឆ្នោត នាថ្ងៃទី២៧ កក្កដា ឆ្នាំ២០០៨ខាងមុខនេះ ។ ទីប្រឹក្សា

( **តទៅទំព័រទី១៤** )

Jim Suos
Realtor, Loan Consultant
jimsuos@hotmail.com
Fax (562) 426-1880
(562) 427-0767



First
AMERICAN TEAM REALTY
TM
ក្រុមហ៊ុនលក់-ទិញគេហដ្ឋាននិងខ្ចីប្រាក់
Cell: (562) 884-0892
ជំនាញឯកទេសជាទីទុកចិត្តនិងស្មោះត្រង់ចំពោះលោក-អ្នកក្នុងការរកស៊ី
លក់ដូរពិគ្រោះយោបល់ ជាមួយបទពិសោធន៍ជាង១២ឆ្នាំក្នុងកិច្ចការលក់-ទិញ
ផ្ទះ-ហាងជំនួញ និងខ្ចីលុយព្រមទាំងផ្នែកសាងសង់សំណង់ជិត៣០ឆ្នាំ

LONG BEACH
2501 CHERRY AVE. SUITE100
SIGNAL HILL, CA 90755

LOS ALAMITOS
10704 LOS ALAMITOS BLVD.
LOS ALAMITOS, CA 90720

HUNTINGTON BEACH
2100 MAIN ST. STE.225
HINTINGTON BEACH, CA 92648

# ហ៊ុន សែន ប្រមាថអ្នកដែល...

ប្រជាពលរដ្ឋហ៊ាននិយាយដល់ទឹកដីដែលបាត់បង់ដោយសារ យួន សៀម ឈ្លានពាន គឺគាត់គំរាមចាប់ដាក់គុក ដើម្បីបំបាក់ស្មារតីតែម្តង ។ ជាពិសេសនោះ ឱ្យតែប្រជាពលរដ្ឋខ្មែរណានិយាយពីរឿងទឹកដីកម្ពុជាក្រោម និងកោះត្រល់ គឺ ហ៊ុន សែន ព្រមានថា "ធ្វើក្តារមឈូសទុកឱ្យហើយទៅ" ។

ហ៊ុន សែន ព្រមានជាសាធារណៈជាញឹកញាប់ ចំពោះពលរដ្ឋខ្មែរណាដែលនិយាយរឿងការបាត់បង់ទឹកដី ហើយត្រូវប្រទេសជិតខាងឈ្លានពាន



ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្មែរ



សុន ឆ័យ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី

នោះ ។ ហ៊ុន សែន តែនិយាយទាំងក្រេវក្រោធថា "អ្នកដែលចង់បានទឹកដីកម្ពុជាក្រោមមកវិញ លោកសុំទិញក្តារមឈូសទុកឱ្យចុះ " ។

ការនិយាយចំអកឡកឡើយរបស់ ហ៊ុន សែន បែបនេះ គឺជាការប្រមាថចំពោះព្រលឹងអ្នកស្នេហាជាតិ ដែលស្លាប់បាត់បង់ជីវិតការពារទឹកដី និងប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេសយ៉ាងធ្ងន់ធ្ងរ ។

លោក អាង ចាន់រិទ្ធ នាយកប្រតិបត្តិអង្គការការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម បានប្រាប់កាសែតក្នុងស្រុកថា ទឹកដីកម្ពុជាក្រោមនៅតែជារបស់ខ្មែរដដែល ។ ពេលនេះ ខ្មែរកម្ពុជាក្រោមមិនចង់ឱ្យរដ្ឋាភិបាលយកដីមកវិញភ្លាមៗទេ គឺគ្រាន់តែជួយជំរុញឱ្យរដ្ឋាភិបាលវៀតណាមគោរពសិទ្ធិពលរដ្ឋខ្មែរតែប៉ុណ្ណោះ ។

លោក អាង ចាន់រិទ្ធ បានបន្តថា ការលើកឡើងរបស់ ហ៊ុន សែន បែបនេះ គឺជាសំដីអ្នកដឹកនាំខ្វះការទទួលស្គាល់ពីបូរណភាពទឹកដីរបស់ខ្លួន ព្រោះកម្ពុជាក្រោមជារបស់ខ្មែរ ។

គេនៅចាំបានថា សកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានមួយដែលនិយាយពីរឿងបូរណភាពទឹកដីកម្ពុជាក្រោម ត្រូវលោក ហ៊ុន សែន ចាប់ដាក់គុកជាបន្តបន្ទាប់ ដើម្បីបំបាក់ស្មារតីកូនខ្មែរកុំឱ្យរើសបំរាស់ចង់បានទឹកដីដែលបាត់បង់ទាំងនោះមកវិញ ។

លោក ម៉ម សូណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំ ( តនៅទំព័រទី១៤ )

# កម្មករសំណង់ក្លាយជាអ្នកគ្រប់គ្រង...

ថ្ងៃណាមួយមិនខានឡើយ ។

ជាក់ស្តែងលោក អ៊ឹម វណ្ណារិទ្ធ ដែលជាកូនកសិករក្រីក្រមានបងប្អូនច្រើន ត្រូវការលុយ ដើម្បីរៀនសូត្រ ហើយឪពុកម្តាយគ្មានលទ្ធភាពជួយឧបត្ថម្ភនោះ លោករៀនផង និងធ្វើកម្មករសំណង់ផង ។ នៅទីបញ្ចប់ការតស៊ូព្យាយាមជំនះរាល់ឧបសគ្គ ធ្វើឱ្យលោកទទួលបានជោគជ័យទាំងការសិក្សា និងការងារដ៏ត្រចះត្រចង់ ។

**● ស្ថានភាពគ្រួសារ :**

គ្រួសារដែលមានជីវភាពខ្សត់ខ្សោយតែងជួបការលំបាកខ្លាំងណាស់ ក្នុងការជួយឧបត្ថម្ភកូនចៅរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ ហើយពួកគាត់បានឱ្យកូនចៅជួយធ្វើការនៅម៉ោងទំនេរ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃថែមទៀត ។ ចំណែកលោក អ៊ឹម វណ្ណារិទ្ធ ដែលជាកូនកសិកររស់នៅទីក្រុងភ្នំពេញ ឪពុកឈ្មោះ អ៊ឹម វ៉ាន់ថា ជាអ្នកបើកបររថយន្តឱ្យក្រសួងសុខាភិបាល និងម្តាយឈ្មោះ អ៊ុយ សាវី លក់នំពុម្ព ដើម្បីដោះស្រាយជីវភាព ។ លោក អ៊ឹម វណ្ណារិទ្ធ កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៣ នៅទីក្រុងភ្នំពេញ និងជាកូនទី២ ដែលមានបងប្អូន៧នាក់ ។

**● ឆ្លៀតធ្វើកម្មករសំណង់ :**

លោក វណ្ណារិទ្ធ បានរំលឹកពីអតីតកាលថា នៅអំឡុងឆ្នាំ១៩៨០ ដល់១៩៨៥ រៀននៅបឋមសិក្សាបាក់ទូកពីឆ្នាំ១៩៨៥ ដល់១៩៨៨ រៀននៅវិទ្យាល័យបាក់ទូក និងពីឆ្នាំ១៩៨៨ដល់ឆ្នាំ១៩៩១ រៀននៅវិទ្យាល័យព្រះសីសុវត្ថិ ។

នៅពេលរៀនថ្នាក់វិទ្យាល័យ គ្រួសារលោកក្រលំបាកណាស់ ពុំមានលទ្ធភាពជួយកូនចៅបានរៀនសូត្រគ្រប់គ្រាន់ទេ គឺលោកត្រូវឆ្លៀតពេលទំនេរទៅធ្វើកម្មករសំណង់ នៅថ្ងៃអាទិត្យ និងថ្ងៃឈប់សំរាក ដែលកាលណោះធ្វើការសំណង់ក្នុងមួយថ្ងៃបានតែ៥០០រៀលប៉ុណ្ណោះ ។ ជាពិសេសពេលវ៉ាកង លោកខំប្រឹងធ្វើការនៅពេលថ្ងៃ និងឆ្លៀតរៀននៅពេលយប់ ដើម្បីយកលុយមកផ្គត់ផ្គង់គ្រួសារ និងការសិក្សា ។

**● ឬមករត់ម៉ូតូឌុប :**

បន្ទាប់ពីលោកបានប្រលងជាប់នៅសាលាបច្ចេកទេសកសិកម្មព្រែកលៀប ក្រុមគ្រួសារ ក៏ប្រឹងប្រែងរកលុយទិញម៉ូតូសំរាប់ធ្វើដំណើរទៅរៀន ព្រោះផ្លូវឆ្ងាយពេក ។ នៅពេលនោះ លោក អ៊ឹម វណ្ណារិទ្ធ ក៏ឆ្លៀតពេលទំនេររត់ម៉ូតូឌុប និងបំរើការងារនៅតាមហាងនៅពេលយប់ ដើម្បីរកលុយមកដោះស្រាយការសិក្សារៀនសូត្រ ។

នៅឆ្នាំ១៩៩៥ លោកក៏បានទទួលសញ្ញាប័ត្រ និងបំរើការងាររដ្ឋនៅក្រសួងកសិកម្មផ្នែកជលផល ខេត្តបន្ទាយមាន-ជ័យ ។

**● ការតស៊ូព្យាយាមរយៈពេល៤ឆ្នាំ :**

ទោះបីបានជាបំរើការងារហើយក្តី ក៏លោកឆ្លៀតបន្តយកការសិក្សាផ្នែកកសិកម្ម រហូតបញ្ចប់ថ្នាក់បរិញ្ញា ។ បន្ទាប់ពីមានប្រាក់ខែចាយវាយខ្លះ លោកក៏មានការចាប់អារម្មណ៍ផ្នែកសារព័ត៌មាន ហើយលោកបានព្យាយាមអានកាសែតជាតិ និងអន្តរជាតិ និងស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិក និងអាស៊ីសេរីអស់រយៈពេល៤ឆ្នាំ ដើម្បីដកស្រង់យកចំណេះដឹងបទពិសោធន៍ពីរៀមច្បង ។

លោក អ៊ឹម វណ្ណារិទ្ធ បានបន្តថា ក្រោយមកលោកក៏បានចូលធ្វើការកាសែត The Vission និងរៀនវគ្គកាសែតខ្លីៗនៅ IIC Internew CAJJ និងសិក្សាពីគោលការណ៍កាសែតយ៉ាងច្បាស់លាស់ ។ លុះដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ លោកក៏ចូលបំរើការងារនៅវិទ្យុសំលេងសហរដ្ឋអាមេរិក ។

អ្នករាយការណ៍ដ៏មានប្រជាប្រិយភាពនៅ V.O.A ឈ្មោះ ហេង រស្មី នេះគឺជាលោក អ៊ឹម វណ្ណារិទ្ធ ដែលបានបំរើអារម្មណ៍មហាជនអ្នកស្តាប់ទូទាំងពិភពលោកពីសភាពការណ៍នៅកម្ពុជាយ៉ាងពិរោះជក់ចិត្ត និងពិស្តារបំផុត ។

**● ក្លាយជាអ្នកគ្រប់គ្រង V.O.A :**

ដោយសារសេចក្តីតស៊ូព្យាយាម និងការលះបង់កំលាំងកាយចិត្តមិនស្តាយស្រណោះ ដើម្បីបំរើអារម្មណ៍មហាជន លោកត្រូវបានផ្លាស់ប្តូរ មកទីក្រុងភ្នំពេញ បំរើការផ្នែក V.O.A ហើយបានបន្តការសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយថ្នាក់អនុបណ្ឌិតទទួលបានសញ្ញាប័ត្រនៅឆ្នាំ ២០០៧ ។

ជាមួយគ្នានេះដែរ លោកត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងវិទ្យុសម្លេងសហរដ្ឋអាមេរិក ប្រចាំស្រុកខ្មែរនៅឆ្នាំ ២០០៦ ។ បន្ទាប់ពីបានជោគជ័យលើការសិក្សា និងការងារ លោកក៏សំរេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា ជា ចាន់លី នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៨ ដែលមានការចូលរួមអបអរសាទរពីសំណាក់ភ្ញៀវជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ ៕

# សមាគមខ្មែរនៅឡើបអាមេរិក

# CAMBODIAN ASSOCIATION OF AMERICA

A Nonprofit Human Services Organization

## លំនាំសុភមង្គលនៃស្វាមីភរិយា និងគ្រួសារ

តពីលេខមុន

**ស្តាប់ដោយបញ្ចេញសកម្មភាពជាសេចក្តីបញ្ជាក់ :**

-ខ្ញុំយល់អំពីអ្វីដែលអ្នកបាននិយាយហើយ

-ចុះ យ៉ាងម៉េចទៅហើយ

-អស្ចារ្យណាស់ ! !

-អ្នកមានន័យថា... !?

-មើលទៅ... អ្នកដូចជាចង់បាន...

**សំណួរ :**

-ប្រសិនបើលោកអ្នកមិនសប្បាយចិត្តក្នុងក្រុមគ្រួសារ រវាងស្វាមីភរិយា ឬក៏ប្រទះនឹងការលំបាកអ្វីមួយ តើឱកាសល្អប៉ុណ្ណាដែរ ដែលហុចជូនលោកអ្នក ដើម្បីជួយឱ្យទំនាក់ទំនងក្នុងគ្រួសារមានការរីកចំរើនឡើងវិញ ?

-មនុស្សជាច្រើនបានយល់ឃើញថា អាពាហ៍ពិពាហ៍ប្រៀបបាននឹងផ្លែឈើ ល្អិតណា បានទុំ ជោររលួយហើយ មិនអាចកែឱ្យមានលំអរស្រស់ត្រកាលវិញបានឡើយ ប៉ុន្តែការស្រាវជ្រាវមួយបានបញ្ជាក់ថា ពេលវេលាលំបាកតែងតែមានកើតឡើងក្នុងរង្វង់គ្រួសារជាធម្មតា នៅគ្រាន់ជាងគ្រួសារដែលមានភាពរកាំរកូសជានិរន្តន៍ ។ បើគេនៅខំព្យាយាមតស៊ូការលំបាកទាំងនោះបាន ក្រោយមកគេនឹងមានឱកាសរកឃើញដំណោះស្រាយល្អៗ ដែលនាំមកនូវសេចក្តីសុខដុមរមនា និងសុភមង្គលរបស់គ្រួសារគេឡើងវិញ ។ អ្នកមិនសប្បាយចិត្តជាមួយអាពាហ៍ពិពាហ៍នៅក្នុងរង្វង់គ្រួសាររបស់ខ្លួន មានដល់ទៅ៨០% តែនៅតែខំតស៊ូទ្រាំទ្រជានិច្ច ហើយក្រុមគ្រួសារនេះ ក្រោយមកក៏ត្រូវមានសុភមង្គល និងភាពរុងរឿងឡើងវិញជាស្ថាពរ ។

**ផលវិបត្តិដែលអាចកើតឡើងដោយអំពើហឹង្សា**

**+កំហឹងបង្កើតឱ្យមានកំហឹង :**

-បញ្ចេញកំហឹងឱ្យអស់តែម្តង ក្នុងពេលតែមួយ

-ការផ្ទុះកំហឹងអាចធ្វើឱ្យរិតតែមានកំហឹង ឡើង ។

**+កំហឹងអាចនាំឱ្យអ្នកប្រើអំណាចផ្តាច់ការមិនមែនជាផ្លូវដោះស្រាយឡើយ :**

-កំហឹងអាចធ្វើឱ្យយើងខ្វះការពិចារណា ចំពោះផលប្រ-យោជន៍របស់អ្នកដទៃ

-កំហឹងអាចក្លាយទៅជាអំពើឆេវឆាវឃោឃៅ ដែលអាចផ្លាស់ប្តូរសាច់រឿង ដែលត្រូវលើកមកដោះស្រាយ ហើយអាចឱ្យមានការឈឺចាប់រិតតែខ្លាំងឡើង

-កំហឹងអាចធ្វើឱ្យបាត់បង់ស្មារតី ។

**+កំហឹងធ្វើឱ្យមានស្នាមរបួស :**

-កំហឹងអាចធ្វើឱ្យខូចខាតដល់សុខភាពទាំង ផ្លូវកាយ និង-ផ្លូវចិត្ត

-ការខូចខាតទាំងនេះអាចធ្វើឱ្យមានការឈឺចាប់ទាំងសងខាង ហើយធ្វើឱ្យអាពាហ៍ពិពាហ៍គ្មានសុភមង្គល

-អាពាហ៍ពិពាហ៍មិនមានសុភមង្គលអាចធ្វើឱ្យខូចសុខភាព

-ធ្វើឱ្យអ្នកទាំងពីរលែងមានការទុកចិត្តគ្នាទៅវិញទៅមក ហើយមានការតូចចិត្ត កើតទុក្ខ គេងមិនលក់ និងពិបាកចិត្ត ។

តទៅលេខក្រោយ

Funding for This project is provided by U.S Department of Health and Human Services Administration for Children and Families Grant #90FE0065

# ភ្ញៀវទេសចរកើនឡើងតែចំណូលហូរចេញអស់ជាង៥០ភាគរយ

***ភ្នំពេញ : គីម សារឿន***

សម្បត្តិធនធានធម្មជាតិ និងសម្បត្តិមរតកវប្បធម៌ បានទាក់ទាញភ្ញៀវទេសចរពីគ្រប់មជ្ឈដ្ឋាន ឱ្យមកទស្សនាប្រទេសកម្ពុជាកាន់តែច្រើន ហើយវិស័យនេះបាននឹងកំពុងនាំមុខគេ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ កាលពីឆ្នាំ២០០៧កន្លងមក ភ្ញៀវទេសចរបានកើនឡើងជាង២លាននាក់ តែចំណូលទាំងនេះបានហូរចេញអស់ជាង៥០% ។



ភ្ញៀវទេសចរបរទេសទៅមើលប្រាសាទអង្គរវត្ត



ភ្ញៀវទេសចរបរទេសនាំគ្នាឡើងភ្នំបាខែងមើលថ្ងៃរៀបលិច

វិស័យទេសចរណ៍ជាឧស្សាហកម្មគ្មានផ្សែងមួយប្រភេទ ដែលបានរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាឱ្យមានការរីកចម្រើន ហើយបានទាក់ទាញមនុស្សគ្រប់ជាតិសាសន៍ឱ្យមកទស្សនាជាហូរហែជារៀងរាល់ថ្ងៃ ។

នៅឆ្នាំ២០០៧កន្លងមកនេះ បើតាមមន្ត្រីជំនាញនៃក្រសួងទេសចរណ៍បានឱ្យដឹងថា មានភ្ញៀវទេសចរប្រមាណជាង២លាននាក់ ដែលមកទស្សនាក្នុងប្រទេសកម្ពុជា ហើយខេត្តក្រុងដែលមានភ្ញៀវច្រើនជាងគេ គឺក្រុងភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ។ តាមរយៈភ្ញៀវទេសចរទាំងនេះ បានជួយឱ្យប្រជាពលរដ្ឋ ដែលរស់នៅតំបន់ទេសចរណ៍មានការងារធ្វើអាចរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារកាន់តែប្រសើរ និងរួមចំណែកកាត់បន្ថយភាពក្រីក្រដល់ប្រជាពលរដ្ឋបន្ថែមទៀតផង ។

**តំបន់ទេសចរណ៍សំខាន់**

កម្ពុជាសម្បូរទៅដោយសក្ដានុពលវប្បធម៌ធនធានធម្មជាតិ ប្រាង្គប្រាសាទពាសពេញផ្ទៃប្រទេស មរណីយដ្ឋាន សមុទ្រ បឹងបួ ព្រៃភ្នំក្រំថ្ម ជាពិសេសប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ដែលជាសម្បត្តិអច្ឆរិយនៅលើពិភពលោកក្នុងការទាក់ទាញភ្ញៀវទេសចរ ។

បើតាមឯកសាររបស់លោក យ៉ង វ៉ន ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍នៃក្រសួងទេសចរណ៍បានបញ្ជាក់ថា "តំបន់ទេសចរណ៍សំខាន់ៗចំនួន១៣១២កន្លែង រមណីយដ្ឋានធម្មជាតិមាន១០២កន្លែង រមណីយដ្ឋានប្រវត្តិសាស្ត្រ១២៦៩កន្លែង រមណីយដ្ឋានកែច្នៃ៤១កន្លែង និងរមណីយដ្ឋានដែលទើបរកឃើញមិនទាន់រាប់បញ្ចូលមួយចំនួនទៀត" ។

ក្រៅពីនេះ វិស័យទេសចរណ៍ក៏មានការរួមចំណែកពីកត្តាជាច្រើនទៀតដូចជា ប្រព័ន្ធគមនាគមន៍ផ្លូវគោក ទឹក និងអាកាសផ្ដល់ភាពងាយស្រួលដល់ភ្ញៀវទេសចរ ។ ចំណែកឯចំនួនសណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋានមានព្រោងព្រាតពាសពេញផ្ទៃប្រទេសមានតម្លៃសមរម្យសំរាប់បម្រើតាមតម្រូវការរបស់ភ្ញៀវមិនឱ្យទាស់ចិត្តឡើយ ។

ឯកសារដដែលបញ្ជាក់ថា ការដែលភ្ញៀវទេសចរមកទស្សនាកម្ពុជាច្រើននោះ មានកត្តាជាចម្បងផ្សេងទៀត ដូចជាចំនួនភ្នាក់ងារទេសចរទាំងក្រុមហ៊ុនជាតិ និងអន្តជាតិ អ្នកមគ្គុទ្ទេសក៏ទេសចរមានការកើនឡើង និងច្រកទ្វារអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានខេត្តសៀមរាប កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ។ ជាពិសេសនៅតាមព្រំដែនប្រទេសជិតខាងក៏មានបើកច្រកឱ្យភ្ញៀវឆ្លងកាត់ដែរ ខេត្តស្វាយរៀង (បាវិត) កណ្ដាល ព្រៃវែង (ក្អមសំណ និងកោះរកា) ខេត្តកោះកុង (ចាំ យាម) បន្ទាយមានជ័យ (ប៉ោយប៉ែត) ឧត្តរមានជ័យ (អូរស្មាច់ និងជាំ) និងខេត្តព្រះវិហារ (ជាំក្សាន្ត)... ។

ការដែលភ្ញៀវទេសចរចម្រុះជាតិសាសន៍មកទស្សនាប្រទេសកម្ពុជាកាន់តែច្រើននោះ ត្រូវបានលោក មឿន សុន ប្រធានគណៈកម្មការទេសចរណ៍ មានប្រសាសន៍ថា បណ្ដាលមកពីកត្តាពីរយ៉ាងគឺ ទី១.ប្រទេសខ្មែរមានប្រាសាទច្រើនខុសប្លែកពីគេ ដែលប្រទេសដទៃគ្មាន ជាពិសេសនៅខេត្តសៀមរាប ។ ទី២.ជនជាតិខ្មែរមានវប្បធម៌ពិសេសខុសប្លែកពីគេ ដែលអាចទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាស្រុកយើង ។ ម្យ៉ាងទៀត កំណើនភ្ញៀវទេសចរនេះ បណ្ដាលមកពីនយោបាយរបស់រាជរដ្ឋាភិបាលល្អប្រសើរលើគ្រប់វិស័យ មានសន្តិសុខល្អបង្កលក្ខណៈដល់ភ្ញៀវក្នុងដំណើរកម្សាន្ត ។

**ភ្ញៀវទេសចរកូរ៉េខាងត្បូងជាប់លំដាប់លេខ១**

បើតាមប្រសាសន៍លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ភ្ញៀវមកពីតំបន់អាស៊ីមកទស្សនាកម្ពុជាមានប្រមាណ៦០% អឺរ៉ុបជាង២០% អាមេរិក១៨% និងមកពីតំបន់មួយចំនួនទៀត ។

ទន្ទឹមនឹងការមកដល់នូវចំនួនទេសចរបរទេសគ្រប់ជាតិសាសន៍នៅកម្ពុជាភ្ញៀវមកពីកូរ៉េខាងត្បូងនៅតែរក្សាទីតាំងជួរមុខគេដដែល ។ យោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍ នៅឆ្នាំ២០០៧ នេះជនជាតិកូរ៉េខាងត្បូងមានចំនួនជិត៣០០.០០០នាក់ បានមកទស្សនានៅកម្ពុជា ដែលតាំងឱ្យ១៧% នៃចំនួនទេសចរបរទេសសរុប ខណៈដែលជនជាតិជប៉ុនឈរនៅលំដាប់ទី២ មានប្រហែល១៦២.០០០នាក់ ចំណែកឯជនជាតិអាមេរិកមកទស្សនាកម្ពុជាមានចំនួនជិត១៣៨.០០០នាក់ ។

លោក មឿន សុន កត់សម្គាល់ឃើញថា ការដែលភ្ញៀវជនជាតិកូរ៉េ មកទស្សនាប្រទេសយើងច្រើនជាងគេ ក៏ព្រោះតែប្រទេសយើងទាំងពីរមាននយោបាយល្អ សេដ្ឋកិច្ចប្រទេសគេខ្ពស់ធ្វើឱ្យប្រជាជនគេមានលទ្ធភាពមកលេងកម្ពុជា ។ ជាពិសេសអ្នកពាណិជ្ជករកូរ៉េខាងត្បូងមករកស៊ីនៅស្រុកខ្មែរច្រើន ហើយបានធ្វើការអូសទាញជនជាតិរបស់គេមកទស្សនាស្រុកខ្មែរកាន់តែច្រើនជារៀងរាល់ឆ្នាំ ។

ភ្ញៀវទេសចរដែលមកលេងស្រុកខ្មែរភាគច្រើនចាប់ពីខែតុលា ដល់ខែឧសភា ព្រោះក្នុងអំឡុងពេលនោះ អាកាសធាតុល្អ មិនមានបង្កការលំបាកដល់អ្នកដំណើរ ។ ដោយឡែកនៅខេត្តសៀមរាប ដែលជាតំបន់មានប្រាសាទបុរាណដ៏ល្បាញល្បី ក្នុងនោះប្រាសាទអង្គរវត្តជាសម្បត្តិបេតិកភណ្ឌពិភពលោក ។

**កត្តាដែលភ្ញៀវទេសចរមានការកើនឡើង**

ចំពោះភ្ញៀវទេសចរកើនឡើងនេះ លោក ពៅ ពិសិដ្ឋ អភិបាលរងខេត្តសៀមរាប បានឱ្យដឹងថា ភ្ញៀវទេសចរមកទស្សនាប្រាសាទអង្គរវត្តនៅដើមខែនេះ មានការកើនឡើងជាងឆ្នាំមុនប្រមាណ ២៨.៩៤% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០០៦ ។ ការកើនឡើងរបស់ភ្ញៀវបណ្ដាលមកពីកត្តា៣យ៉ាង គឺទី១.ដោយសារប្រទេសយើងមានសន្តិភាពពេញលេញនយោបាយល្អ ទាំងក្នុង និងក្រៅប្រទេស ។ ទី២.ក្រសួងទេសចរណ៍បានរៀបចំខ្សែបណ្ដាញទំនាក់ទំនងល្អ ជាពិសេសធ្វើការផ្សព្វផ្សាយបានទូលំទូលាយ ។ ទី៣.រាជរដ្ឋាភិបាលបានបើកជើងយន្តហោះហើរត្រង់ទៅបង្កលក្ខណៈងាយស្រួលដល់អ្នកទេសចរកាន់តែខ្លាំង ។

លោក ពៅ ពិសិដ្ឋ បានបញ្ជាក់ថា ខេត្តសៀមរាបមានក្រុមហ៊ុនភ្នាក់ងាទេសចរ១២៨ សំរាប់ដឹកជញ្ជូនភ្ញៀវសណ្ឋាគារចំនួន១០០ស្មើនឹង៧៣៩៤បន្ទប់ និងផ្ទះសំណាក់១៩៨ ស្មើនឹង២៣៣០បន្ទប់ មានអ្នកមគ្គុទ្ទេសក៏ចំណាន១ៗជាច្រើននាក់ សំរាប់នាំផ្លូវភ្ញៀវទៅកាន់តំបន់ផ្សេងៗ ។

**សារប្រយោជន៍ពីភ្ញៀវទេសចរ :**

ភ្ញៀវទេសចរដែលមកទស្សនាទាំងនោះ បាននាំមកនូវសារប្រយោជន៍ជាច្រើនដូចជា រួមចំណែកបង្កើនការងារប្រជាពលរដ្ឋរកប្រាក់ចំណូល ការអភិវឌ្ឍអាជីវកម្ម សេដ្ឋកិច្ច ផ្សព្វផ្សាយវប្បធម៌ អរិយធម៌ ប្រព័ន្ធគមនាគមន៍កាន់តែប្រសើរឡើង ។ ជាពិសេសជួយលើកស្ទួយសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើន និងធ្វើការផ្លាស់ប្ដូរវប្បធម៌ ភាសារវាងជាតិសាសន៍ផ្សេងៗ ។

យោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍ នៅឆ្នាំ២០០៧នេះ កម្ពុជាទទួលបានចំណូលពីវិស័យទេសចរណ៍ប្រមាណជាង១,៤ពាន់លានដុល្លារអាមេរិក នេះបើធៀបនឹងតួលេខនៅឆ្នាំ២០០៦ មានត្រឹមតែ១,០៤០លានដុល្លារ ។

ភ្ញៀវទេសចរទាំងនោះមានពីរប្រភេទ គឺភ្ញៀវមកតាមក្រុមហ៊ុន ដែលគេទាក់ទងមកពីបណ្ដាប្រទេសផ្សេងៗ ហើយក្រុមហ៊ុនជាអ្នកធានារ៉ាប់រងទាំងអស់ ។ ចំណែកឯភ្ញៀវទេសចរមួយប្រភេទទៀត មកដោយខ្លួនឯង ហើយពេលគេមកដល់ស្រុកខ្មែរ ទើបគេរកអ្នកនាំផ្លូវ និងជួលមធ្យោបាយធ្វើដំណើរ ។ សព្វថ្ងៃនេះ

( តនៅទំព័រទី២៧ )



# ល្ហុងប្រេងអាចចម្រាញ់ជាឱសថ ប្រេងរំអិល និងគ្រឿងសម្អាង

***បន្ទាយមានជ័យ : គីម សារឿន***

បន្ទាប់ពីមានការសិក្សាស្រាវជ្រាវ និងបង្ហាត់បង្ហាញពីអ្នកបច្ចេកទេសរួចមក ដំណាំល្ហុងប្រេងបាននឹងកំពុងទទួលការចាប់អារម្មណ៍ពីប្រជាកសិករនៅតាមតំបន់មួយចំនួន ហើយផលិតផលនេះ ត្រូវបានក្រុមហ៊ុនទទួលទិញទាំងអស់ ។

អ្នកបច្ចេកទេសបានអះអាងថា ល្ហុងប្រេងអាចចម្រាញ់ជាប្រេងរំអិលសម្រាប់ចាក់គ្រឿងយន្ត និងគ្រឿងសម្អាង ឱសថព្យាបាលជំងឺ ។ ដំណាំល្ហុងប្រេងមួយហិកតាអាចហុចផលពី១.៨ ទៅ២តោន ដែលក្នុងមួយតោនអាចលក់បានតម្លៃ១២០ដុល្លារ និងមានទីផ្សារល្អសម្រាប់ប្រជាកសិករទៀតផង ។

ល្ហុងប្រេង គេសង្កេតឃើញអ្នកស្រុកនៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ ដាំយ៉ាងច្រើន ក្រោមការជួយឧបត្ថម្ភផ្នែកពូជ បច្ចេកទេស និងទីផ្សារសម្រាប់លក់ផលិតផលពីសំណាក់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ។ ដំណាំល្ហុងប្រេងនេះអាចដាំបាននៅតំបន់ខ្ពង់រាប និងជួរភ្នំ ហើយអាចដាំពោត សណ្តែកដី និងសណ្តែកសៀងបានថែមទៀតផង ដោយទទួលបានទិន្នផលខ្ពស់គួរឱ្យពេញចិត្ត ។

ល្ហុងប្រេង គឺជាប្រភេទដំណាំម្យ៉ាងដែលមានអាយុចាប់ពី១២០ទៅ១៦០ថ្ងៃ វានឹងហុចផលដោយមានផ្លែទុំជាបន្តបន្ទាប់ទម្រាំចេញផ្លែអស់ ។ នៅពេលនោះគេអាចដាំពោត សណ្តែកដី និងសណ្តែកសៀងបាន ហើយវាហុចផលយ៉ាងច្រើនទៀតផង ។

ល្ហុងប្រេងអាចដាំបាននៅលើដីខ្មៅ ដីល្បាយខ្សាច់ ដីក្រហម និងដីសណ្តរមាត់ទន្លេ ដែលមិនលិចទឹក មិនជាប់ទឹក ឬមិនបៀមទឹក ។ មុនពេលដាំគេត្រូវភ្ជួរដីឱ្យល្អ ហាលដីឱ្យស្ងួត ដើម្បីចៀសវាងល្ហុងមានរោគ និងជំងឺផ្សេងៗ ជាពិសេសគេត្រូវការជ្រើសរើសពូជល្ហុងណាដែលមានទងធំគ្រាប់ល្អជាងគេយកហាលឱ្យស្ងួត ។

នៅពេលដាំក្នុងអំឡុងខែមេសា និងឧសភា ដោយក្នុងមួយគុម្ពដាក់គ្រាប់២ទៅ៣ ការពារគ្រាប់ដែលមិនដុះ បន្ទាប់ពីបាន៧ទៅ១០ថ្ងៃ វានឹងចេញជាពន្លក ។ ពេលល្ហុងបានមួយខែ បើពូជធូន់គេត្រូវដក ឬគ្រៀវវាចេញ ដើម្បីឱ្យទទួលផលបានច្រើន ដោយដាក់ជីធម្មជាតិ និងជីគីមីជំនួយមែក ស្លឹក និងផ្កា ព្រមទាំងថែទាំឱ្យបានល្អ ។

ដំណាំល្ហុងប្រេងមាន៣ប្រភេទ គឺពូជស្រាលហុចផលរយៈពេល១ឆ្នាំ ពូជមធ្យមឱ្យផលរយៈពេល២ឆ្នាំ និងពូជធូន់ផ្តល់ផលរយៈពេល៣ឆ្នាំ ចំពោះដំណាំល្ហុងនេះ គេអាចដាំពោត សណ្តែកដី និងសណ្តែកសៀងលាយគ្នាបាន ។ ប៉ុន្តែក្នុងចម្ការល្ហុងនោះ បើមានដាំដំណាំចម្រុះមួយហិកតាបានផល



ផលិតផលគ្រឿងសំអាងដែលចំរាញ់ចេញពីល្ហុងប្រេង



សកម្មភាពអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ ចុះជួយណែនាំប្រជាកសិករ

១.៨តោន ហើយបើមិនដាំដំណាំផ្សេងទៀត បានផល២តោនក្នុងមួយហិកតា ។ ល្ហុងប្រេងនេះ ឱ្យផលតិច ឬច្រើន វាអាស្រ័យលើអាកាសធាតុ បើភ្លៀងខ្លាំង ល្ហុងនឹងខូចរលួយគល់ ហើយហុចផលតិច ។

លោក មូល ផាត អាយុ៤៩ឆ្នាំ រស់នៅភូមិ អូរ-សំព័រទីពីរ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា គាត់ប្រកបរបរនេះតាំងពីឆ្នាំ២០០៤ រហូតមកទល់សព្វថ្ងៃមានផ្ទៃដី៥ហិក-តា ។ ក្នុងចម្ការនោះក៏មានដាំសណ្តែកសៀងផងដែរ ហើយសណ្តែកសៀង ក្នុងមួយហិកតាលក់បានតម្លៃប្រមាណ៣០០ដុល្លារ ។ ចំណែកឯល្ហុងប្រេងក្នុងឆ្នាំនេះ ទទួលផលតិចជាងឆ្នាំទៅ ដោយសារភ្លៀងជោកជាំខ្លាំងពេកធ្វើឱ្យវាស្អុក ។

ចំណែកលោក រាជ យ៉ុន អាយុ២៤ឆ្នាំ រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ បានឱ្យដឹងថា ក្រុមគ្រួសាររបស់គាត់បានដាំល្ហុងប្រេងលើផ្ទៃដីជិត១០ហិកតា និងមានដាំសណ្តែកសៀងលាយជាមួយផងដែរ ។ ការប្រកបរបរនេះ ធ្វើឱ្យគ្រួសាររបស់គាត់មានជីវភាពធូរធារជាងមុន ដោយក្នុងមួយឆ្នាំអាចរកចំណូលបានជាង១០០០ដុល្លារ ។ ចំណែកផលិតផលដែលធ្វើបានខាងអង្គការ និងក្រុមហ៊ុនទិញយកទាំងអស់ ។

ល្ហុងប្រេងមានកំពស់ចាប់ពី១ទៅ១.៥ម៉ែត្រ ដែលមានដើម មែកពណ៌ក្រហម ។ គេដាំវាជាជួរចន្លោះពី០.៧៥-១០ អាស្រ័យលើគុណភាពដី ហើយ

( តទៅទំព័រទី៣២ )

ឱសថស្ថានខ្មែរថ្ងៃនេះ
Today Pharmacy
2200 E. Anaheim St.#C Long Bach, CA 90804
Tel: (562) 438-2031 • Fax: (562) 438-2031
(2 Blocks East of Cherry Ave.)
Fast and Friendly Service
- Today Pharmacy គឺជាឱសថស្ថានបំរើការចែកចាយថ្នាំតាមវេជ្ជបញ្ជា ។
- ទទួលយកនៅ Medicare & Medical និង Insurance ។
- ដឹកជញ្ជូនថ្នាំផ្តល់ជូនឲ្យដល់គេហដ្ឋានដោយមិនគិតពីកំរៃផងដែរ ។
• FREE DELIVERY
TODAY:
ថ្ងៃល្អរបស់លោកអ្នក
សូមស្វាគមន៍!

# ចៅហ្វាយក្រុងច្រានចោល...

នៅក្នុងពិធីអ្វីមួយនៅក្នុងក្រុង Long Beach ទេ ។

● ប្រតិកម្មបែបនេះ បន្ទាប់ពីអភិបាលក្រុង Bob Foster បានជួបជាមួយក្រុមសកម្មជនប្រឆាំង ដែលបានធ្វើសេចក្តីថ្លែងការណ៍អំពីការមិនសប្បាយចិត្តរបស់បងប្អូនខ្មែរនៅទីក្រុង Long Beach និងជុំវិញពិភពលោក ចំពោះការឆ្លៀតឱកាសប្រើប្រាស់ "ក្រុងខ្មែរ" ទៅធ្វើជាឈ្នាន់សំរាប់ពង្រឹងឥទ្ធិពលនយោបាយនៃរដ្ឋាភិបាល ហ៊ុន សែន ជាពិសេសការពង្រីកឥទ្ធិពលនៃគណបក្សប្រជាជនកម្ពុជាជះចេញមកតាមសហគមន៍ខ្មែរនានានៅឯក្រៅប្រទេស ។

ចៅហ្វាយក្រុង Bob Foster បានសន្យាថា នឹងរកឱ្យឃើញនូវការពិត ពីព្រោះលិខិតអញ្ជើញនោះ ពិតជាពុំបានចេញពីរូបលោកទេ ។

ប្រធានក្រុងខ្មែរអ្នកស្រី សិទ្ធា សាន ថ្លែងប្រាប់កាសែតខ្មែរប៉ុស្តិ៍ថា គ្មានការអញ្ជើញឧប-នាយករដ្ឋមន្ត្រី សុខ អាន មកកាន់ក្រុង Long Beach ពីចៅហ្វាយក្រុងទេ ។ ហើយការដែលក្រុមប្រឆាំងស្នើសុំឱ្យចៅហ្វាយក្រុងលុបចោលការអញ្ជើញ សុខ អាន គឺចៅហ្វាយក្រុង Bob Foster មិនអាចទទួលយកបានឡើយ ព្រោះគាត់មិនបានស្នើសុំ ។

អ្នកស្រី សិទ្ធា សាន បន្តថា ការអញ្ជើញលោក សុខ អាន ក្នុងបំណងឱ្យចូលរួមបុណ្យព្យហយាត្រាអបអរសាទរបុណ្យចូលឆ្នាំខ្មែរតែប៉ុណ្ណោះ គ្មានការអញ្ជើញណាមួយឱ្យគាត់ធ្វើជាអធិបតីកាត់ខ្សែបូ ដូចដែលការអះអាងរបស់ក្រុមជំទាស់នោះទេ ។ ហើយការមក ឬមិនមកចូលរួមនោះ វាជាការសម្រេចចិត្តរបស់លោក សុខ អាន ។

រដ្ឋមន្ត្រី ឆាំង សុង និយាយថា ការច្រានចោលការអញ្ជើញ សុខ អាន ពីចៅហ្វាយក្រុង Long Beach វាសមទំនងតាមផ្លូវការច្បាប់ ព្រោះការអញ្ជើញថ្នាក់ដឹកនាំប្រទេសណាមួយត្រូវឆ្លងកាត់ស្ថានទូត, ក្រសួងការបរទេសជាដើមទៅនឹងទំនាក់ទំនងការងារសុវត្ថិភាពសន្តិសុខសង្គម ។ ចំណែកខាងភាគីរដ្ឋាភិបាលកម្ពុជា ស្ថិតនៅលើការសម្រេចចិត្តផ្ទាល់ពីលោកឧប-នាយករដ្ឋមន្ត្រី សុខ អាន ព្រោះរបាយការណ៍បានដាក់ជូនឱ្យលោករួចរាល់អស់ហើយ ចំពោះ



សុខ អាន ឧបនាយករដ្ឋមន្ត្រីខ្មែរ

ស្ថានការណ៍ប្រឆាំងពីក្រុមខ្មែរក្រៅប្រទេសទាក់ទិននឹងការអញ្ជើញរូបគាត់មកកាន់ក្រុងខ្មែរ Long Beach នាដើមខែមេសា ឆ្នាំ២០០៨ ។

អ្នកនាំពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រី ផៃ ស៊ីផាន និយាយថា គម្រោងទស្សនៈកិច្ចរបស់ឧបនាយករដ្ឋមន្ត្រី សុខ អាន មកកាន់ក្រុងខ្មែរ Long Beach មិនមានការផ្លាស់ប្តូរទេ ។

លោក ផៃ ស៊ីផាន បន្តថា ក្រុមជំទាស់កំពុងតែលេងល្បែងនយោបាយ ដើម្បីបំផ្លាញតំបន់សេដ្ឋកិច្ចរបស់ខ្លួនហើយ ព្រោះរដ្ឋាភិបាលកម្ពុជាមានបំណងធ្វើសំរាប់តែប្រយោជន៍សេដ្ឋកិច្ចរួមផ្លាស់ប្តូរទំនិញក្នុងទីផ្សារសេរីឱ្យគ្នាទៅវិញទៅមក ដោយគ្មានឥទ្ធិពលនយោបាយពង្រីកពង្រឹងគោលការណ៍បក្សណាមួយ ដូចដែលក្រុមជំទាស់បានចោទប្រកាន់នោះទេ ។

ក្រុងខ្មែរបានសម្រេចចិត្តឱ្យដោយអាជ្ញាធរក្រុង Long Beach កាលពីខែកក្កដា ឆ្នាំ២០០៧ ដែលទីក្រុងមួយនេះផ្តុំទៅដោយបងប្អូនខ្មែរមិនតិចជាង១០ម៉ឺននាក់ ។

ក្រុមអ្នកដឹកនាំក្រុងខ្មែរបានទៅកាន់ប្រទេសកម្ពុជា ជួបប្រមុខដឹកនាំកាលពីដើមខែធ្នូ ឆ្នាំ២០០៧ ដែលពួកគេអះអាងថា ក្នុងបំណងផ្សាភ្ជាប់ចំណងទាក់ទងការទូត និងរកស៊ីធ្វើជំនួញសេដ្ឋកិច្ចជាមួយគ្នា ដោយគ្មានបែបប្រជាភិថុតនយោបាយជ្រៀតជ្រែកទេ ។

ប៉ុន្តែការអះអាងរបស់អ្នកដឹកនាំក្រុងខ្មែរ ត្រូវបានទាត់ចោលដោយក្រុមជំទាស់ ដែលត្រឡប់ចោទប្រកាន់បកវិញថា អ្នកដឹកនាំធ្វើអ្វី តាមការអន្តោម័តមិនសួរយោបល់មតិភាគច្រើនដើម្បីធ្វើកិច្ចការសម្រេចអ្វីមួយ តាមបែបប្រជាធិបតេយ្យ ព្រោះការកើតមានក្រុងខ្មែរបានដោយសារកម្លាំងប្រជារាស្ត្រគាំទ្រ ។ ដោយអ្នកដឹកនាំទាំងនោះ មិនអាចធ្វើអ្វីតាមអំពើចិត្តនោះទេ ។ ញាតិដែលមានហត្ថលេខាចំនួនជាងមួយពាន់នាក់ ក្នុងនាមសកម្មជនសហគមន៍ខ្មែរបានប្រគល់ជូនដល់មន្ត្រីសាលាក្រុង Long Beach ហើយដែរ ដើម្បីស្នើសុំច្បាប់ធ្វើបាតុកម្មប្រឆាំងការមកកាន់ក្រុង Long Beach របស់លោកឧបនាយករដ្ឋមន្ត្រីខ្មែរ សុខ អាន ។

មកដល់ឥឡូវ គ្មានប្រភពប្រាកដណាមួយ ថាតើ សុខ អាន នឹងត្រូវមកកាន់ក្រុងខ្មែរ Long Beach ឬយ៉ាងណានោះទេ ខណៈដែលក្រុមខ្មែរក្រៅស្រុកត្រៀមខ្លួននឹងទទួលលោក សុខ អាន រយៈការធ្វើបាតុកម្មប្រឆាំងនោះ ៕

នាទី ប្រវត្តិសាស្ត្រ

## ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

***តពីលេខមុន***

-រដ្ឋមន្ត្រីព័ត៌មាន :មាស ហ៊ែល
-រដ្ឋមន្ត្រីមហាផ្ទៃ : អូ ឈីន
-រដ្ឋមន្ត្រីសាធារណការ និងគមនាគមន៍ : ទីម កេន
-រដ្ឋមន្ត្រីការបរទេស : សឺន សាន
-រដ្ឋមន្ត្រីការពារជាតិ : សុន វ៉ិនសៃ
-រដ្ឋមន្ត្រីធម្មការនិងវិចិត្រសិល្បៈ សមញ្ញាណ
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ញ៉ឹក ជូឡុង
-រដ្ឋមន្ត្រីអប់រំជាតិ និងយុវជន : ហ៊ុយ គន្ធុល
-អនុរដ្ឋលេខាធិការសុខាភិបាល និងសង្គមកិច្ច : សុន ម៉ម

ថ្ងៃទី ០៨ កុម្ភៈ ថ្នាក់ដឹកនាំបក្សកុម្មុនយនិស្តខ្មែរ១នាក់ បានទៅជួប ឡេ ឌឹកថូ ប្រធានកុម្មុយ-និស្ត វៀតណាម ហើយសម្រេចបង្កើតគណបក្សបដិវត្តន៍ប្រជាជនកម្ពុជា (PRPK) ។

ថ្ងៃទី ១១-១៩ កុម្ភៈ សន្និបាតទី២ របស់បក្សកុម្មុយនិស្តឥណ្ឌូចិន ។ សន្និបាតនេះបានប្តូរបក្សឱ្យទៅគណបក្សពលកវៀតណាមវិញ ក្នុងពេលនោះ គេបានប្រកាសពីកំណើត ទៅអនាគតយ៉ាងខ្លីខាង មុខនូវគណបក្សបដិវត្តន៍ប្រជាជនកម្ពុជាផងដែរ ។

**ឆ្នាំ១៩៥១ :**

**ខែមករា ថ្ងៃទី១ រដ្ឋាភិបាលទ្រង់ស៊ីសុវត្ថិមុនីពង្ស :**

***១០-រដ្ឋាភិបាលស៊ីសុវត្ថិមុនីពង្ស (១.១.១៩៥១-១.៣.១៩៥១):***

-នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសុខាភិបាល-ការងារ និងសង្គមកិច្ច : ស៊ីសុវត្ថិមុនីពង្ស
-រដ្ឋមន្ត្រីកសិកម្ម និងចិញ្ចឹមសត្វ :ឃួន ណៃ
-រដ្ឋមន្ត្រីយុត្តិធម៌ : ពីទូដឹម៉ុងតេរ៉ូ
-រដ្ឋមន្ត្រីព័ត៌មាន : មាស ហ៊ែល
-រដ្ឋមន្ត្រីមហាផ្ទៃ : អូ ឈីន
-រដ្ឋមន្ត្រីសាធារណការ និងគមនាគមន៍ : ទីម កេន
-រដ្ឋមន្ត្រីការបរទេស : សឺន សាន
-រដ្ឋមន្ត្រីការពារជាតិ : សុន វ៉ិនសៃ
-រដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ : សម ញាណ
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ញ៉ឹក ជូឡុង
-រដ្ឋមន្ត្រីអប់រំជាតិ និងយុវជន : ហ៊ុយ គន្ធុល
-អនុរដ្ឋលេខាធិការសុខាភិបាល និងសង្គមកិច្ច សុន ម៉ម

-ថ្ងៃទី៨ ខែកុម្ភៈ ថ្នាក់ដឹកនាំខ្មែរ៩នាក់ នៃបក្សកុម្មុយនិស្តឥណ្ឌូចិន បានទៅរួមប្រជុំជាមួយ ឡេឌិកថូ ហើយបានសម្រេចបង្កើតគណបក្សប្រជាជនបដិវត្តន៏កម្ពុជា ។

ថ្ងៃទី១១ដល់១៩ ខែកុម្ភៈ មហាសន្និបាតទី២ របស់កុម្មុយនិស្តឥណ្ឌូចិន បានប្រែឈ្មោះជាបក្សពលករវៀតណាម នៅពេលនោះ ។ ក្នុងឱកាសនោះដែរ គេបានប្រកាសពីកំណើតរបស់គណបក្សប្រជាជនបដិវត្តន៏កម្ពុជាផងដែរ តែថ្ងៃកំណើតពិតប្រាកដ គេនៅសង្ស័យនៅឡើយថា មិនច្បាស់ជាថ្ងៃ១៩ កុម្ភៈ ឬក៏២៨ មិថុនា ឬក៏៣០ កញ្ញា នៅឡើយទេ ។

ថ្ងៃទី៣ ខែមិនា ធ្វើនាយករដ្ឋមន្ត្រីបានបីខែ ទ្រង់ស៊ីសុវត្ថិមុនីពង្ស បានត្រូវប្តូរដោយនាយករដ្ឋមន្ត្រីថ្មីលោក អ៊ុំម ឈាងស៊ុន ។

**១១-រដ្ឋាភិបាល អ៊ុំម ឈាងស៊ុន (៣.៣.១៩៥១-១៣.៥.១៩៥១):**

-នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : អ៊ុំម ឈាងស៊ុន
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសាធារណសុខាភិបាល : សុន ម៉ម
-រដ្ឋមន្ត្រីអប់រំជាតិ និងវិចិត្រសិល្បៈ : ហ៊ុយ គន្ធុល
-រដ្ឋមន្ត្រីការបរទេស : នាល ផ្លែង
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ញ៉ឹក ជូឡុង
-រដ្ឋមន្ត្រីធម្មការ : សម ញាណ
-រដ្ឋមន្ត្រីយុត្តិធម៌ : ពីទូដឹម៉ុងតេរ៉ូ
-រដ្ឋមន្ត្រីមហាផ្ទៃ និងព័ត៌មាន : អូ ឈីន
-រដ្ឋមន្ត្រីកសិកម្ម : ផ្លែក ភីន
-រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម : ជា ជិនកុក
-រដ្ឋមន្ត្រីសាធារណការ : សុន វ៉ិនសៃ
-អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី : សម សារី

ថ្ងៃទី១១ ខែមីនា ចលនាកុម្មុយនិស្តខ្មែរ ឡាវ និងវៀតណាម បានជួបជុំគ្នា ហើយសម្រេចកម្មវិធីធ្វើការរួមគ្នាមួយ ។

ថ្ងៃទី១៤ ខែឧសភា រដ្ឋាភិបាលលោក អ៊ុំម ឈាងស៊ុន បានត្រូវសើរើ ។

***១២-រដ្ឋាភិបាល អ៊ុំម ឈាងស៊ុន (១៤.៥.១៩៥១-១២.១០.១៩៥១) :***

-នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : អ៊ុំម ឈាងស៊ុន
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសុខាភិបាល, ការងារ និងសង្គមកិច្ច :សុន ម៉ម
-ទេសរដ្ឋមន្ត្រីទទួលបន្ទុកព័ត៌មាន : ញ៉ឹក ជូឡុង
-រដ្ឋមន្ត្រីយុត្តិធម៌ : ពីទូដឹម៉ុងតេរ៉ូ
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : អូ ឈីន
-រដ្ឋមន្ត្រីការបរទេស : នាល ផ្លែង
-រដ្ឋមន្ត្រីមហាផ្ទៃ : ប្រាក់ សារិន
-រដ្ឋមន្ត្រីសាធារណការ-ផែនការ-គមនា-គមន៍ និងប្រៃសណីយ៍ : កុសល
-រដ្ឋមន្ត្រីអប់រំជាតិ និងវិចិត្រសិល្បៈ : ប៉ុក ធូន
-រដ្ឋមន្ត្រីធម្មការ : សម ញាណ
-រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្មៈ ទេព ផន
-រដ្ឋមន្ត្រីកសិកម្ម និងចិញ្ចឹមសត្វ : ជួប ហ៊ែល

ថ្ងៃទី២៦ ខែកក្កដា សម្តេច សីហនុ បានដាក់ងារក្រុមខ្មែរកុម្មុយនិស្តថា "ខ្មែរវៀតមិញ" ជាដំបូងបង្អស់ ។

ថ្ងៃទី៩ ខែកញ្ញា ការបោះឆ្នោតជ្រើសរើសសភាចាប់ផ្តើមឡើងវិញ បន្ទាប់ពីសម្តេច សីហនុ បំបិទចោល២៣ខែរួមមក ។ ការបោះឆ្នោតសារជាថ្មីនេះ គណបក្សប្រជាធិបតេយ្យបានឈ្នះសម្លេងភាគច្រើនដាច់ខាតដដែល ។

ថ្ងៃទី៣០ កញ្ញា គណៈកម្មការនាយកបណ្តោះអាសន្នរបស់បក្សកុម្មុយនិស្តខ្មែរបានកើតឡើង មាន សឺង ង៉ុកមិញ ជាប្រធាន, ទូ សាមុត ជាអនុប្រធាន ហើយ និង សៀវ ហេង ជាអគ្គ-លេខាធិការ ពេលនោះមានសមាជិកប្រមាណ ១០០០នាក់ ។ ***តទៅលេខក្រោយ***

នាទី ព្រះពុទ្ធសាសនា

# អត្ថបទស្តីអំពីខន្ធ៥ និងសមាធិវិប្បស្សនា

***ដោយ : ម៉ៅ ច័ន្ទសំណុំ***

អ្នកខ្លះញៀនគ្រឿងស្រវឹង បារី ល្បែងស៊ីសង ។ អ្នកខ្លះព្រោះមនុស្សជាទីស្រឡាញ់ស្លាប់ កើតទុក្ខក្រៀមក្រំ ។ អ្នកខ្លះកើតជម្ងឺមហារីកចាំតែពេលត្រឡប់ទៅវិញ ។

តើប្រព័ន្ធប្រតិកម្ម ឬសំពាយកម្ម ឬសង្ខារខន្ធ នេះអាចកាត់ផ្តាច់បានឬទេ?ឬអាចលប់បំបាត់បាន ឬទេ ? ឬជនដែលមានសំពាយកម្មក្រាស់អាចមានផ្លូវរួចរំដោះបានឬទេ ?

ព្រះពុទ្ធលោកបានបញ្ជាក់ក្នុងសច្ចៈធម៌ទី៣ ថា មានមាគ៌ាឱ្យរួចផុតពីទុក្ខពីការក្រៀមក្រំពីការទុក្ខព្រួយអំពីតណ្ហាអំពីភាពវង្វេងបានរួចរំដោះ ។ ការរចេញផុតពីទុក្ខក្រៀមក្រំការគាស់រំលើងតណ្ហា នឹងបានដល់ពន្លឺព្រះនិព្វាន សន្តិភាពផ្លូវចិត្ត ភាពស្ងប់ ភាពសុខសន្ត សុភមង្គល ។ ដូច្នេះសំពាយកម្ម ប្រព័ន្ធប្រតិកម្ម ឬសង្ខារខន្ធ អាចនឹងបន្ថយ ឬគាស់រំលើង ឬលប់បំបាត់ ពុំចាំរហូតដល់ជាតិក្រោយទេ គឺជាតិយើងជាមនុស្សនេះឯង ។

ខ្ញុំបានជួបនឹងពន្លឺព្រះនិព្វាន ក៏រិតទាបនេះរួចហើយ ។ ខ្ញុំពុំអាចរៀបរាប់ជូនបាន ព្រោះនេះហួសពីការគិតរបស់មនុស្សយើង ទោះរៀនដល់ណាចេះប៉ុណ្ណា ក៏ពុំអាចរៀបរាប់បាន ។ ព្រះពុទ្ធលោកសំដែងថា អ្នកអាចយល់ដឹងអំពីព្រះនិព្វាននេះតាមពិសោធន៍ប៉ុណ្ណោះ ជាពិសេសពិសោធន៍ផ្ទាល់ខ្លួន គ្មាននណាម្នាក់ជំនួសបានទេ ។

ខាងក្រោមនេះ ខ្ញុំសូមជំរាបជូនពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ដូចតទៅ

ពិសោធន៍ទី១ ក្នុងឆ្នាំ១៩៩៩ ខ្ញុំទទួលរងគ្រោះមួយជាទម្ងន់អាស្រ័យដោយកូនខ្ញុំស្លាប់ គឺពេលនោះខ្ញុំបានជួបដោយផ្ទាល់ នរកលើលោកកីយនេះ ចិត្តរបស់ខ្ញុំផ្តុកទៅដោយរឿងរ៉ាវពីមុនៗ ការប្រតិកម្មរបស់សង្ខារខន្ធ ខ្លាំងក្លារអស្ចារ្យ ។ ចិត្តរងទុក្ខជាទម្ងន់ ពីមួយនាទីទៅមួយនាទី ព្យុះចិត្តវាយវាត់ ហាក់បីដូចគេយកខ្សែរភ្លើងអគ្គិសនីទៅឆក់សន្លប់ ហើយដឹងខ្លួនវិញ ឆក់បន្តជាច្រើនដងភ្លើងកំហឹង ភ្លើងខកចិត្ត ភ្លើងព្រួយ ភ្លើងភ័យ កើតព្រមៗគ្នា ដូចគ្រាប់បែកផ្ទុះ ។ ខ្ញុំហាក់ជាមនុស្សមានតែរូបបាត់ប្រលឹង ។

ពេលនោះដោយនិស្ស័យពីអតិតជាតិ ខ្ញុំបានជួបកល្យាណមិត្តនៅហ្វីឡាដែលហ្វីយ៉ាសហរដ្ឋ-អាមេរិក ពួកគេបានទំនុកបំរុងខ្ញុំឱ្យទៅសាកល្បងអង្គុយសមាធិនៅ Texas បាន១០ថ្ងៃ ។ ប្រតិកម្មភ្លាមៗ ខ្ញុំពុំមានជំនឿទាល់តែសោះ ខ្ញុំគិតថា នេះគ្រាន់តែជាពិធីតាមរបៀបចាស់បុរាណគ្មានមូលដ្ឋានត្រឹមត្រូវអបិយជំនឿ ។ ប៉ុន្តែស្ថានភាពដែលខ្ញុំប្រឈមមុខនោះ គឺគេបានរុញផ្ទប់នឹងជញ្ជាំងទាល់ច្រករកគិតអ្វីលែងឃើញ (គេចវាសនា) ។ ខ្ញុំតម្រូវទៅសាកពិសោធន៍វិធីសមាធិនេះ ដោយទើសទាល់បំផុត ។

នៅ Texas ខ្ញុំបានអង្គុយសមាធិជាមួយនឹងជនជាតិផ្សេង ប្រមាណជិត៣០នាក់ ស្បែកខ្មៅស្បែកសគ្រូបង្ហាត់ជាជនជាតិអាមេរិកស្បែកស ។ ពេលខ្ញុំអង្គុយ ខ្ញុំមើលទៅគ្រូបង្ហាត់ហាក់ឃើញព្រះសង្ឃមួយអង្គគង់គ្រងចីពរនៅខាងមុខកន្លែងមនុស្សអង្គុយត្រៀបត្រា ។ បីថ្ងៃបីយប់ហើយព្យុះចិត្តនៅតែបន្តគ្មានស្រាក់ស្រាន្តទាលតែសោះ ខ្ញុំគិតថា ប្រហែលជាគ្មានបានការអ្វីទេ ។ ពេលថ្ងៃត្រង់ពេលសំរាក ខ្ញុំឡើងទៅសួរលោកគ្រូណែនាំចំពោះករណីខ្ញុំនេះ ។ លោកគ្រូមានប្រសាសន៏ថា "រលកចិត្តដែលអ្នកកំពុងឃើញនេះ បន្តិចទៀតថា ហាក់លែងមានសកម្មភាពទៀត ប៉ុន្តែក្នុងលក្ខខ័ណ្ឌមួយ (១) អ្នកឈប់គិតពិចារណា (២) អ្នកគ្រាន់ តែពិនិត្យ ហើយចាំមើលវាទៅ ខ្ញុំត្រឡប់មកវិញ បន្តអង្គុយទៅទៀត ម្តងនេះខ្ញុំខិតខំធ្វើតាមគ្រូណែនាំ ។ កន្លះម៉ោងក្រោយមកស្រាប់តែព្យុះចិត្តស្ងប់បន្តិចម្តងៗ រហូតដល់ខ្ញុំទទួលអារម្មណ៍ថា បានជួបនឹងសន្តិភាពពិតប្រាកដភាពស្ងប់ក្នុងចិត្តពិតប្រាកដ ។ ខ្ញុំអាចប្រៀបធៀបបាន ដូចជាអាប់ត្រូវពន្លឺព្រះអាទិត្យរលាយអស់ហើយ ភាពភ្លឺថ្លា ចែងចាំងមកជំនួសវិញ ។ ខ្ញុំនិយាយឧទានក្នុងខ្លួន ឯងថា Great discovery!! ខ្ញុំរកឃើញមួយដ៏ធំក្នុងជីវិតនេះ !! អស្ចារ្យណាស់ អស្ចារ្យណាស់!! វិធីនេះ សាមញ្ញសោះ ហេតុអ្វីក៏មានឥទ្ធិពលអាចបន្សាប ព្យុះចិត្តបាន ? ខ្ញុំគិតថា ប្រាកដជាមានអាថិកំបាំងអ្វីពីក្រោយបច្ចេកទេសនេះហើយ ។ ពីពេលនោះ មកខ្ញុំសំរេចចិត្តថា នឹងស្រាវជ្រាវបញ្ហានេះ ។ គួរកត់សំគាល់ថា ភាពស្ងប់នេះ បានត្រឹមតែមួយថ្ងៃមួយយប់ទេ ព្យុះនោះប្រឡប់មកវិញដដែល ។ មកដល់ពេលនេះបានខ្ញុំដឹងថា សង្ខារខន្ធនេះ មានច្រើនស្រទាប់ជាកម្មមួយស្រទាប់ផុតទៅមួយស្រទាប់ឡើងមកទៀត...

***តទៅលេខក្រោយ***

## នរណាជាអ្នកឈ្នះ ហ៊ីឡារី ឬ...

រហូតដល់ចប់នាខែមិថុនាខាងមុខ ក៏មិនអាចរកបានចំនួនប្រតិភូគាំទ្រ២០២៥នោះបានដែរ នេះក៏ជាព្រឹត្តការណ៍គ្មានសំណាងមួយទៀត ដែលគេពុំទាន់ដឹងថា តើនឹងមានការព្រមព្រៀងរវាងហ៊ីឡារី នឹង ប៉ារ៉ាក់ របៀបណានៅឡើយទេ ។

យោងតាមរូបភាពនៃព្រឹត្តការណ៍ចុងក្រោយនេះ ថ្វីត្បិតតែជាទូទៅគេទស្សន៍ទាយថា គណបក្សប្រជាធិបតេយ្យមុខតែនឹងមានសំណាងបានឡើងជាប្រធានាធិបតីបន្តពី ជច ប៊ុស តែបែរជាឱ្យសំណាងថ្មីមួយដល់គណបក្សសាធារណរដ្ឋឱ្យអាចឈ្នះឆ្នោតទៅវិញបានដែរ នេះក៏ដោយសារតែគណបក្សប្រជាធិបតេយ្យនៅជាប់រវល់ប្រកួតប្រជែងតែជាមួយនឹងគ្នាឯង ពុំមានឱកាសមកយកឈ្នះលើគណបក្សប្រឆាំងរបស់ខ្លួន គឺលោក ជន ម៉ាកេន បាននៅឡើយទេ ។

សមាគមស្បែកខ្មៅ, សមាគមស្ត្រី, សមាគមស្បែកស, សមាគមស្បានីស បានកម្រើករញ្ជួយ ហើយជម្រុញឱ្យបេក្ខជនដែលខ្លួនស្រឡាញ់ពេញចិត្តយ៉ាងស្វាហាប់ ។ សមាគមខ្មែរដែលកាលពីលើកមុនៗតែងតែមានការប្រឹងប្រែងគួរឱ្យគត់សំគាល់ ឥឡូវស្លាប់ត្រចៀកស្ងួនស្ងៀមពុំមានឮប្រកូកហៅគ្នា សំដែងការគាំទ្របេក្ខជនខាងណាមួយទៀតទេ ទំនងជារង់ចាំការគាំទ្រអ្នកឈ្នះតែម្តងទើបមិនខុស ។ សមាគមខ្មែរនៅហ្វីឡាដែលហ្វីយ៉ា ឬនៅឡូវែល ឬ រ៉ូដអាយឡិន និងតំណាងមួយចំនួនទៀត ជាសមាគមក្រីក្រត្រូវការអ្នកចេះឱ្យជួយត្រួសត្រាយផ្លូវរកប្រ-យោជន៏មកជួយសមាគមខ្លួន តែអ្នកចេះខ្មែរយើងភាគច្រើនទៅបំរើប្រយោជន៏ផ្ទាល់ខ្លួនយ៉ាងជ្រាលជ្រៅនៅឡើយ ដូច្នេះប្រធានាធិបតីថ្មីប្រាកដជាពុំមានការជំពាក់គុណស្រ័យអ្វីនឹងសមាគមខ្មែរ ដែលត្រូវជំនួយចាំបាច់សំរាប់រីកចំរើនបានឡើយ ៕

# ហ៊ុន សែន ប្រមាថអ្នកដែល...

ត្រូវគេចាប់ដាក់គុកព្រៃស នៅថ្ងៃទី១១ តុលា ឆ្នាំ ២០០៥ បន្ទាប់ពីលោកធ្វើបទសម្ភាសន៍ លោក ស៊ាន់ ប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា នៅប្រទេសបារាំង ។ លោកបានហៅសិទ្ធិសញ្ញាខុសច្បាប់ ( ១៩៨៥ រវាង ហ៊ុន សែន និង យួន ) ។


លោក អៀ ចាន់ណា

លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀន ដែលនិយាយរឿងព្រំដែន ក៏ត្រូវគេចាប់ដាក់គុកព្រៃស ដែរ ។ ចំណែកសកម្មជនសិទ្ធិមនុស្សមួយចំនួនទៀត ដែលបានបញ្ចេញមតិយោបល់រឿងព្រំដែនត្រូវលោក ហ៊ុន សែន គំរាមចាប់ខ្លួនរត់ទៅក្រៅដូចជា លោក ម៉ែន ណាត, អៀ ចាន់ណា និង ឆាំ ឆានី ជាដើម ។

យោងតាមទស្សនាវដ្ដីសារព័ត៌មានសេរី បានអះអាងថា ការចុះហត្ថលេខារវាងលោក ហ៊ុន សែន ជាមួយប្រទេសយួន នៅឆ្នាំ១៩៨២- ១៩៨៣ និង១៩៨៥ សិទ្ធិសញ្ញាខុសច្បាប់ ។ លោក ស៊ាន ប៉េងសែ ប្រធានគណកម្មកាធិការការពារព្រំដែនកម្ពុជានៅប្រទេសបារាំង បានអះអាងថា រឿងចុះហត្ថលេខាធ្វើឱ្យយួនចំណេញទឹកដី ។ ជាពិសេសនៅឆ្នាំ១៩៨៧ យួន និងសៀម បានចែកតំបន់សមុទ្រខ្មែរត្រួតត្រាអស់រាប់ម៉ឺនគីឡូម៉ែត្រការ៉េ ។

លោក ស៊ាន ប៉េងសែ បានអះអាងថា ទឹកដីខ្មែរទាំងគោក និងទឹកត្រូវយួន និងសៀមរំលោភយករាប់សិបគីឡូម៉ែត្រការ៉េ ។ ក្នុងផែនទីកម្ពុជាដាក់តម្កល់នៅអង្គការសហប្រជាជាតិ ឆ្នាំ ១៩៥៥ ពុំមានតំបន់សទេ ។ ប៉ុន្តែចាប់តាំងពីមានការចុះហត្ថលេខាដោយ ហ៊ុន សែន រួចមក ក៏មានតំបន់សតែម្តង ហើយយួន សៀមធ្វើស្រេចតែចិត្ត ចំណែកខ្មែរមិនអាចធ្វើបានឡើយ ។

ចំណែកកោះត្រល់បានបាត់បង់នៅឆ្នាំ ១៩៨២ ដោយការចុះហត្ថលេខាព្រមព្រៀងលើសិទ្ធិព្រំដែនរវាង ហ៊ុន សែន រដ្ឋមន្ត្រីការបរទេសរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និង ង្វៀន កូថាច់ រដ្ឋមន្ត្រីការបរទេសវៀតណាម ។

ប្រទេសផ្សេងៗ មេដឹកនាំរបស់គេតែងតែរំលឹកដល់ប្រជាពលរដ្ឋឱ្យមានឆន្ទៈចង់បានទឹកដី ដែលបានបាត់បង់មកវិញ ទោះបីជារាប់សិបឆ្នាំក៏ដោយ ។ ដោយឡែក ហ៊ុន សែន បែរជាគំរាមកំហែងជាតិសាសន៍ឯង ដែលមានគំនិតចង់បានទឹកដីដូនតាមកវិញ ដោយចាប់ដាក់គុក និងគំរាមតាមរូបភាពផ្សេងៗ ។

សកម្មភាពរបស់ ហ៊ុន សែន នោះត្រូវបានអ្នកវិភាគមួយចំនួនយល់ថា ហ៊ុន សែន ជាអ្នកចុះហត្ថលេខាប្រគល់ទឹកដីឱ្យ យួន និងចង់យកចិត្តចៅហ្វាយនាយ ដើម្បីរក្សាតួនាទី និងអំណាចដែលយួនបន្ទុបឱ្យធ្វើបន្ទាប់ពីផ្តួលរំលំរបបខ្មែរក្រហមរួចមក ។

ទោះបីជាមានការប្រមាថជីវិតពីសំណាក់ ហ៊ុន សែន យ៉ាងនេះក្តី ក៏ប្រជាពលរដ្ឋខ្មែរគ្រប់ទិសទីទាំងក្នុង និងក្រៅប្រទេស នៅតែចិញ្ចឹមចិត្តទាមទារទឹកដីដែលបាត់បង់នោះមកវិញ តាមរយៈផ្លូវច្បាប់ឱ្យខាងតែបាន ៕







## ដំណឹងលក់ហាង

-ហាង Donut ត្រូវការលក់ក្នុងតម្លៃ **$150,000.00**

សូមទាក់ទង Cindy:(562) 6193 265/ (714) 9644 380

Revenue : $14,000.00 to $ 15,000.00

Rent : $ 2793.00 include CAM (Common Area)

Lease : 4.5 years left and 5 more years (Optional)


# ហ៊ុន សែន តែងតាំង...

ដ៏ច្រើនស្ទើកស្ទះនេះ វាមិនបានខាតបង់លុយកាក់របស់គណបក្សប្រជាជនកម្ពុជាទេ ប៉ុន្តែវាធ្វើឱ្យខូចប្រយោជន៍បក្សផ្សេង និងថវិកាជាតិធ្ងន់ធ្ងរ ។ ជាពិសេសនោះរំលោភលើរដ្ឋធម្មនុញ្ញមាត្រា ទី៥៦ ថែមទៀត ។

យោងតាមឌឹខែមបូឌាដេលី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ បានឱ្យដឹងថា លោក សុន ឆ័យ សមាជិកសភាមកពីគណបក្ស សម រង្ស៊ី បានសរសេរលិខិតទៅកាន់លោក ហ៊ុន សែន ដោយស្នើរឱ្យឈប់ជាបន្ទាន់ ព្រោះទីប្រឹក្សាមានច្រើនណាស់ហើយ ។ លោក សុន ឆ័យ បានចោទប្រកាន់រដ្ឋាភិបាលពីបទអនុវត្តន៍ច្បាប់ខុស ដោយផ្តល់តួនាទីឱ្យក្រុមដែលចាកចេញពីគណបក្ស សម រង្ស៊ី និងហ៊្វុនស៊ិនប៉ិច ទៅចូលរួមជាមួយគណបក្សកាន់អំណាចនោះ ។

លោក ហ៊ុន សែន បានមានប្រសាសន៍ក្នុងពិធីសម្ពោធស្ពាន នាថ្ងៃទី២២ កុម្ភៈ ថា យើងត្រូវការមនុស្សមកពីគណបក្សប្រឆាំង ពីព្រោះពួកគេដឹងពីចំណុចខ្សោយរបស់រាជរដ្ឋាភិបាល។ ប្រសិនបើមានមនុស្ស១០០នាក់មកទៀត យើងនឹងទទួលយកទាំងអស់ ហើយខ្ញុំមានសិទ្ធិតែងតាំងពួកគេឱ្យធ្វើជាទីប្រឹក្សារដ្ឋាភិបាល ឬទីប្រឹក្សានាយករដ្ឋមន្ត្រី ។

លោក ហ៊ុន សែន បានបញ្ជាក់ថា វាមិនមែនលុយរបស់អ្នកឯងទេ គឺជា "លុយរបស់ជាតិ" ។ ចំណែកលោក សុន ឆ័យ បានឱ្យដឹងថា យើងចង់ឱ្យរាជរដ្ឋាភិបាលអនុវត្តន៍ច្បាប់ ហើយការតែងតាំងនេះ វារំលោភចំពោះរដ្ឋធម្មនុញ្ញ និងធ្វើឱ្យប៉ះពាល់ដល់ថវិកាជាតិថែមទៀតផង ។ ថវិកាជាតិមិនមែនសំរាប់នាយករដ្ឋមន្ត្រីចាត់ចែងធ្វើឱ្យស្រេចតែអំពើចិត្តនោះទេ ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានមានប្រសាសន៍ថា អ្នកចាកចេញទាំងនោះ សុទ្ធតែជាមនុស្សឱកាសនិយម ហើយពួកគេកំពុងរកពាក្យពេចន៍ ដើម្បីនិយាយបិទបាំងពីទង្វើអាក្រក់របស់ខ្លួន ។ ជាពិសេសរកពាក្យអាក្រក់និយាយប្រាប់មហាជនពីបក្សដែលខ្លួនធ្លាប់រស់នៅ ដើម្បីផ្គាប់គុណគណបក្សប្រជាជនកម្ពុជា ។

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យរបស់រដ្ឋាភិបាល បានឱ្យដឹងថា អ្នកចុះចូលទាំងនោះនឹងទទួលបានប្រាក់ខែម្នាក់៧៥០ដុល្លារ មានឋានៈជាទីប្រឹក្សារបស់រាជរដ្ឋាភិបាល ។

សំរាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិមួយចំនួនយល់ថា គណបក្សកំពុងអនុវត្តន៍យុទ្ធសាស្ត្របំបែកបំបាក់ និងដណ្តើមយកមន្ត្រីដែលមានប្រជាប្រិយភាពមកពីគណបក្សផ្សេង និងប្រើប្រាស់ឱកាសនៃការចាក់ចេញជាសង្គ្រាមចិត្តសាស្ត្រ។

ការតែងតាំងទីប្រឹក្សាដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ត្រូវបានគេមើលឃើញថា លោក ហ៊ុន សែន ធ្វើឡើងដើម្បីបម្រើផលប្រយោជន៍គណបក្សប្រជាជនកម្ពុជា និងបំបែកបំបាក់គណបក្សដទៃប៉ុណ្ណោះ ។

ឧទាហរណ៍ទីប្រឹក្សាលោក ហ៊ុន សែន. ជា ស៊ីម, ហេង សិរិន ភាគច្រើនជាអ្នករកស៊ីជាឧកញ៉ា អ្នកចម្រៀង ចំណែកអ្នកនយោបាយក៏មានច្រើនដែរ ។ ក្នុងរាជការសព្វថ្ងៃអនុប្រធានមន្ទីរមានតួនាទីជាទីប្រឹក្សា ធ្វើអ្វីស្រេចតែចិត្តមិនស្តាប់ប្រធាន ហើយប្រធានគ្មានឋានៈជាទីប្រឹក្សាមិនហ៊ានណែនាំ ព្រោះខ្លាចអំណាចទីប្រឹក្សាបានធ្វើឱ្យមានភាពរញ៉េរញ៉ៃកាន់តែខ្លាំង ក្នុងប្រព័ន្ធរដ្ឋាភិបាលសព្វថ្ងៃ ។ ថ្មីៗនេះចៅហ្វាយខេត្តចៅហ្វាយខេត្តរងប្រធាននាយកដ្ឋានខ្លះ ត្រូវបានតែងតាំងជាទីប្រឹក្សាលោក ហ៊ុន សែន មានឋានៈស្មើរដ្ឋមន្ត្រីរដ្ឋលេខាធិការ ដែលអ្នកទាំងនោះមានប្រវត្តិមិនសូវល្អជាមួយប្រជារាស្ត្រ ។ ទីប្រឹក្សាខ្លះទៅរកស៊ីកាងពួកនាយទុនខុសច្បាប់មិនព្រមបង់ពន្ធចូលរដ្ឋ ធ្វើឱ្យខាតបង់ថវិកាជាតិកាន់តែធ្ងន់ធ្ងរ។

ទីប្រឹក្សារបស់លោក ហ៊ុន សែន ត្រូវបានគេមើលឃើញថា ភាគច្រើនពុំមែនសំដៅអ្នកដែលមានចំណេះដឹងនោះទេ គឺជាអ្នកដែលពូកែអែបអបស្វែងរកលាភសក្ការៈយសសក្តិ ទៅរកស៊ីធ្វើភាពមានបានសំរាប់ក្រុមគ្រួសាររបស់គេ ។

ទីប្រឹក្សារាប់ពាន់នាក់របស់លោក ហ៊ុន សែន នេះ គឺជាការធ្វើឡើងសំរាប់បំរើផលប្រយោជន៍នយោបាយគណបក្សប្រជាជនកម្ពុជា និងខាតបង់ផលប្រយោជន៍ជាតិកាន់តែធ្ងន់ធ្ងរ ៕


# Unipaq Realty & Financial

Complete Real Estate Services

សូមអញ្ជើញដោយមេត្រីភាព !

*-បំរើកិច្ចការងារលក់ដូរទិញផ្ទះទូទៅ*

*-អ្នកប្រឹក្សាពិគ្រោះយោបល់នៃការខ្ចីប្រាក់*



**David Kuoch**
*Real Estate Agent*
*Loan Consultant*

Cell: (714) 351-2803
Office: (714) 892-2070
Fax: (714) 893-2059
Residence: (714) 774-4061
12062 Valley View St., Suite 204B
Garden Grove, CA 92845
Email: davidkuoch@sbcglobal.net

# LAW OFFICES OF BOROTH CHAY

# ការិយាល័យមេធាវី



▶មេធាវីខ្មែរពូកែក្តីក្តាំនូវករណីគ្រោះថ្នាក់ចរាចររថយន្ត
◆អន្តោប្រវេសន៍ (ធានាប្តីប្រពន្ធ, កូនកណ្តឹង, បងប្អូន) ◆ច្បាប់គ្រួសារ
◆បណ្តឹងលែងលះ ◆ប្រាក់ចិញ្ចឹមកូន ◆រដ្ឋប្បវេណី ◆ច្បាប់ក្ស័យធន
▶បើមិនឈ្នះក្តី គឺមិនគិតកម្រៃ .ពិគ្រោះយោបល់ ឬពិភាក្សាមិនគិតថ្លៃ
▶ករណីប្តឹងផ្តល់នឹងផ្តល់ចម្លើយជូនលោកអ្នក ថាតើបណ្តឹងរបស់លោកអ្នក មានសង្ឃឹមឈ្នះឬយ៉ាងណា? តើគួរធ្វើការប្តឹងផ្តល់ដែរឬទេ? ។



## Up to 50% of Settlement to Clients

▸Bankruptcy ▸Family Law ▸Dissolution of Marriage
▸Child and Spousal Support ▸Immigration
▸Family Sponsor Petition ▸Auto Accident
▸Low Contingency ▸No Recovery ▸No Fee.

**Personal Injury:**

Auto Accident Free Consultation
How strong is your case?
Should you file a claim?

We'll answer your questions !

**Other Legal Representations:**

Family Law: Dissolution of Marriage,
Spousal and Child Support Bankruptcy
Immigration Law: Family sponsored petition

2501Cherry Ave , Ste.245 , Signal Hill , CA 90755
Office: (562) 997- 8500 . Direct : (562) 453 - 5898




# ឃុន ហេង

ឃុន ហេង គឺជាផ្សារខ្មែរដ៏ធំមួយតាមដងផ្លូវ
អាណាហែម មានលក់ទំនិញគ្រប់មុខ
☞សាច់ បន្លែ ផ្លែឈើស្រស់ៗ
☞ អាហារស្ងួត និងម្ហូបកំប៉ុងមកពីអាស៊ី
☞និងមានលក់ម្ហូបឆ្អិនស្រាប់ៗផងដែរ
☞ហើយនឹងមានលក់បាច់ផ្កាសំរាប់ពិធីបុណ្យនានា ។

ទោះទៅទីណា
សូមកុំភ្លេចផ្សារ ឃុន ហេង

915 E. Anaheim Street
Long Beach, CA 90813






WINSTAR CAPITAL

A Residential Mortgage Lending
License: # 01834778

100% CONFORMING
SISA AVAILABLE

**WANTED: LOAN OFFICER AND Sr. LOAN OFFICER!!!**

**We're looking for:**

- Motivated and career minded individual to join our sales team
- Seasoned Loan Officers and Senior Loan Officers
- Opportunity to build your team and manage your own branch
- We provide leads and referrals
- Generous commission splits
- We provide friendly, supportive & beautiful working environment
- Khmer speaking preferred

**For confidential interview, please call Dan at:**
**(714) 594 - 5131**

**REAL ESTATE AGENTS & BROKERS COOPS**

- Have an LO assigned to your office
- Coops Marketing plan
- Programs to boost your New Year 2008
- 100% Conforming Full Doc
- Jumbo Loan
- Hard Money

**For more info, contact our sales team:**
**(714) 594 – 5135**

17150 Newhope Street, Suite 503, Fountain Valley, CA 92708




# Quality
## Assured
## Collision Center



"We do what's right to ensure your vehicle gets back to pre - accident condition"

1427 long beach Blvd., Suite B
Long Beach , CA 90813
Tel : (562) 599 0766, Fax : (562) 599 6504
QACollison@yahoo.com

" Mission Statement "

To Provide the highest quality of workmanship in reasonable time , while building a lifetime relationship with our customers

ធ្វើតួ និង បាញ់ថ្នាំឡាន
ជាមួយជាងជំនាញៗ មានបទពិសោធន៍ខ្ពស់
ធ្វើឱ្យលោកអ្នកមិនខកបំណងឡើយ !











" Services Offered "

- Fast repairs with State-of-the-art equipment .
- Lifetime warranty on body and paint .
- Free estimates .
- Shuttle service .
- Free loaner vehicles , up 7 days .
- Free towing with vehicle repairs .
- I-CAR certified technicians .
- Customer Friendly staff .
- Waiting room with wireless internet .
- Computerized frame measurement , print out .
- Expert color match .
- Auto mechanic on staff .
- 25 working bays .
- 65,000 square feet facility .
- We work with all insurance companies .

STATE -OF-THE-ART Equipment

- 2 chief EZ liner 3 post frame machine .
- Garmat downdraft Heated spray booth .
- PPG paint mixing room .
- Robinair air condition system reclaim ,evacuate and recharge equipment .
- CCC pathways estimating software .



C&B CROISSANTS
WHOLESALE ONLY

ORDER BY PHONE:
(562) 495-5713
(800) 974-3888
Cell: (562) 607-3258
Fax: (562) 495-7544

# ហាងខ្មែរផលិតនំ ក្រូហ្សង់






-ធានាគុណភាពទុកបាន ៣០ ថ្ងៃ
-ដឹកជញ្ជូនដោយមិនគិតថ្លៃ ពីថ្ងៃ ច័ន្ទ-សុក្រ
-ហាងយើងខ្ញុំមានលក់ដុំតែប៉ុណ្ណោះ
-អ្នកទិញត្រូវឱ្យដឹងមុន ១ថ្ងៃ

| Item | Net Wt Each | Packaging | Price/Package |
|---|---|---|---|
| - Butter Croissant | 4.50 oz | 50 | $1 .00 |
| - Triangle Croissant | 5.00 oz | 50 | $1 .00 |
| - Square Croissant | 5.00 oz | 50 | $1 .00 |
| - Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Blueberry Cream Cheese Croissant | 6.oo oz | 50 | $2 .00 |
| - Strawberry Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Raisin Cinnamon Croissant | 6.00 oz | 50 | $2 .00 |
| - Raisin Custard Croissant | 6.00 oz | 50 | $2 .00 |
| - Apple Croissant | 6.00 oz | 50 | $2 .00 |
| - Chocolate Croissant | 6.00 oz | 50 | $2 .00 |
| - Chocotate Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Pineapple Cream Cheese Croissant | 6.00 oz | 50 | $2 .00 |

FREE DELIVERY
We guarantee our products up to 30 days. Order must be made 1 day in advance.
WHOLE SALE ONLY

1339 W. Gaylord Street• Long Beach, CA 90813




# ផ្ញើប្រាក់ទៅកាន់ខេត្តណាមួយនៅកម្ពុជា តាមរយៈ Western Union

## ជាមួយថ្លៃ* សេវាកម្មផ្ញើប្រាក់ទាប $11.99 ដុល្លារ

សម្រាប់ការផ្ញើប្រាក់ទៅកាន់ខេត្តក្រុង** ដែលបានជ្រើសរើសក្នុងចំនួនតិចជាង 500 ដុល្លារ

## ជាទូទៅប្រាក់អាចទទួលបានតែប៉ុន្មាននាទី*** ប៉ុណ្ណោះ

- ✓ ថ្លៃ*សេវាកម្មផ្ញើប្រាក់មិនមានការប្រែប្រួលទៅតាមទីកន្លែងរបស់ភ្នាក់ងារទទួលប្រាក់ឡើយ
- ✓ មានភ្នាក់ងារផ្ទេរប្រាក់ជាង 100 កន្លែងនៅ 24 ខេត្តក្រុងទូទាំងប្រទេសកម្ពុជា
- ✓ មិនចាំបាច់មានគណនីនៅធនាគារទាំងអ្នកផ្ញើ និងអ្នកទទួល
- ✓ មិនមានការគិតថ្លៃសេវាកម្មផ្ទេរប្រាក់ពីអ្នកទទួលឡើយ

WESTERN UNION

សេវាកម្មផ្ទេរប្រាក់ទូទាំងពិភពលោក រហ័សទាន់ចិត្ត និងគួរឲ្យទុកចិត្ត

**សូមទាក់ទងទូរស័ព្ទ**
**1-800-325-6000**

ភ្នាក់ងារផ្ទេរប្រាក់នៅកម្ពុជាដែលទទួលបានការអនុញ្ញាតពី Western Union: ACLEDA Bank Plc. CAB BANK SBC Bank

| | | | | |
|---|---|---|---|---|
| **NHA THUOC THIEN NHIEN**<br>1299 E. ANAHEIM ST<br>LONG BEACH, CA 90813<br>TEL: 562-218-2328 | **MONEY MART #0772**<br>1001 E. PACIFIC COAST HWY<br>LONG BEACH, CA 90806<br>TEL: 562-599-0991 | **MONEY MART #0767**<br>2375 LONG BEACH BLVD<br>LONG BEACH, CA 90806<br>TEL: 562-427-0253 | **CONTINENTAL CURRENCY #704**<br>3106 SAN GABRIEL BLVD<br>ROSEMEAD, CA 91770<br>TEL: 626-280-0380 | **TOPANGA CHECK CASHING**<br>7239 TOPANGA CANYON BLVD<br>CANOGA PARK, CA 91303<br>TEL: 818-594-0057 |
| **CONTINENTAL CURRENCY #408**<br>1301 LONG BEACH BLVD<br>LONG BEACH, CA 90813<br>TEL: 562-599-1550 | **ANTOJITOS LATINOS LIQUOR**<br>25381 ALICIA PKWY STE N<br>LAGUNA HILLS, CA 92653<br>TEL: 949-215-9708 | **NADERS MARKET**<br>25227 REDLANDS BLVD # I<br>LOMA LINDA, CA 92354<br>TEL: 909-796-1660 | **CONTINENTAL CURRENCY #413**<br>237 LONG BEACH BLVD<br>LONG BEACH, CA 90802<br>TEL: 562-432-5883 | **SIAM MARKET**<br>2505 E. ANAHEIM ST<br>LONG BEACH, CA 90802<br>TEL: 562-607-8970 |

*សម្រាប់ការផ្ញើប្រាក់ដុល្លារអាមេរិចប៉ុណ្ណោះ។

**ថ្លៃសេវាកម្មផ្ញើប្រាក់នេះមានសុពលភាពចាប់ពីថ្ងៃទី 22 ខែ តុលា ឆ្នាំ 2007 នេះនៅតាមបណ្ដាភ្នាក់ងារនានាដែលបានចូលរួមក្នុងកម្មវិធីរបស់ខ្លួននៅតំបន់ប្រជុំជន Los Angeles និង Philadelphia ។ Western Union សូមរក្សាសិទ្ធិក្នុងការកែប្រែដោយមិនចាំបាច់ជូនដំណឹងជាមុន។ ថ្លៃសេវាកម្មផ្ញើប្រាក់អាចត្រូវបានគិតច្រើនជាងនេះសម្រាប់ការផ្ញើប្រាក់តាមរយៈទូរស័ព្ទ និង តាមរយៈគេហទំព័រ www.westernunion.com ។

***រយៈពេលនៃការទទួលប្រាក់អាស្រ័យទៅលើកត្តាមួយចំនួននៃសេវាកម្មរួមទាំងម៉ោងធ្វើការ និងទីតាំងរបស់ទីភ្នាក់ងារផ្ទេរប្រាក់ព្រមទាំងភាពខុសគ្នារវាងម៉ោងនៅក្នុងតំបន់នីមួយៗផងដែរ។ ពិនិត្យមើលកត្តាកំណត់ និងល័ក្ខខ័ណ្ឌនានានៅក្នុងបែបបទ "ផ្ញើប្រាក់"។

©2007 Western Union Holdings, Inc. All Rights Reserved.


CATHAY PACIFIC
CATHAY PACIFIC
CATHAY PACIFIC
ធ្វើដំណើរជាមួយ Cathay Pacific លោកអ្នកនឹងទទួលបានអារម្មណ៍
សុខស្រួល និងភាពទំនើបនៃយន្តហោះ Cathay Pacific
ចាប់ពីខែ មេសា ឆ្នាំ ២០០៨ នេះទៅ យន្តហោះ Boeing ថ្មីទាំងអស់ ដែលរចនាតុប
តែងឡើងក្នុងលក្ខណៈពិសេស និងទំនើបបំផុត ។ ពិដានរចនាឡើងយ៉ាងល្អប្រណិត និងខ្ពស់ ។
កៅអីធំ និងរចនាដោយប្រើបច្ចេកទេសខ្ពស់ងាយស្រួលអង្គុយ និងចេញចូល ហើយអាចសន្ទូក
ជើងបានទៀតផង ។ ទូរទស្សន៍ផ្ទាល់ខ្លួនមានទំហំរហូតដល់ ៩ អ៊ីង ។ Cathay Pacific
ហោះហើរពាជើងក្នុង ១ ថ្ងៃ ពី Los Angeles ទៅ Hong Kong ។ ហើយតភ្ជាប់ពី
Hong Kong ទៅ Phnom Penh ដោយ Dragon Air រៀងរាល់ថ្ងៃ ដោយប្រើ
សុទ្ធតែយន្តហោះ Airbus A321 ថ្មីទាំងអស់ ។
រយៈពេលហោះហើរពីហុងកុងទៅភ្នំពេញ តែ២ម៉ោងកន្លះប៉ុណ្ណោះ ។


PHNOM PENH express
ក្រុមហ៊ុនទទួលផ្ញើប្រាក់ និងលក់សំបុត្រយន្តហោះ
CHINA AIRLINES
Mon-Sat 9am-6pm
Sunday: 10am-5pm
Anaheim St
INCOME TAX
TRAVEL
សេវារហ័សទាន់ចិត្ត
និងជឿជាក់សំរាប់លោកអ្នក
មានយើងខ្ញុំមានបញ្ចូលទឹកលុយនៅក្នុងទូរស័ព្ទដៃ និងទូរស័ព្ទផ្ទះសំរាប់ CALL ចេញពីគ្រប់ STATES ទៅកាន់ស្រុកខ្មែរ
ទទួលផ្ញើប្រាក់ទៅកាន់ប្រទេសកម្ពុជា - វៀតណាម, មានលក់សំបុត្រយន្តហោះគ្រប់ក្រុមហ៊ុន,
ទៅគ្រប់ប្រទេស, លក់កាតទូរស័ព្ទគ្រប់ម៉ាក និងទទួលបង់វិក័យប័ត្រនានា ។ បំរើអតិថិជន៧ថ្ងៃក្នុងមួយសប្តាហ៍ ។
2140E. Anaheim St., Long Beach CA 90804 . Tel: (562) 434-3322, (562) 434-3760



# ASIAN PACIFIC INTL TRAVEL

## ក្រុមហ៊ុនលក់សំបុត្រយន្តហោះ និងផ្ញើប្រាក់

**មានលក់សំបុត្រគ្រប់ក្រុមហ៊ុនទៅកម្ពុជាដូចជា:**

-Eva Airways
-China Airlines
-Singapore Airlines
-Thai Airways
-Malaysia Airlines
-Cathay Pacific
-Korea Airlines
-Asiana Airlines

* មានលក់សំបុត្រទៅប្រទេសផ្សេងៗទៀត ដូចជា: អឺរ៉ុប
* មានលក់សំបុត្រក្នុងប្រទេស USA
* មានលក់សំបុត្រយន្តហោះពីភ្នំពេញមក USA

**កន្លែងនាងខ្ញុំមានប្រថាប់ត្រា**

-Notary Public
-Phone Card ( Buy 4 get 1 free )

$ 869 Eva Tax included

ទទួលរៀបចំធ្វើ

Re-entry Permit Urgent ,

ជានាប្ដីប្រពន្ធ,គូដណ្ដឹង, ក្រុមគ្រួសារ
សូមលោកអ្នកអញ្ជើញមកដោយមេត្រី

Prepaid - Phone Cards
Toll Free 1-800- 359 -6698

មានទទួល Pay Bill

**ផ្ញើប្រាក់ទៅស្រុកខ្មែរលឿនជាងគ្រប់ក្រុមហ៊ុនទាំងអស់**

➲ ផ្ញើ $100 យកកម្រៃ $4 ➲ ផ្ញើ $1.000 ឬ $10.000 យកឈ្នួល
ចុះថ្លៃច្រើនថែមទៀត !
➲ ផ្ញើទៅស្រុកខ្មែរលឿនរហ័សទាន់ចិត្ត
ប្រគល់ប្រាក់ដក់ដៃភ្លាមៗជាមួយ
បង្កាន់ដៃទទួលប្រាក់ជូនផងដែរ ។



Léssé passe
៣ថ្ងៃយកដោយ
មិនបាច់ម្រើ
Re-entry Permit
និងធ្វើលិខិតឆ្លងដែនខ្មែរថ្មី
ឬបន្តឆ្នាំលិខិតឆ្លងដែនខ្មែរ
ដែលផុតកំណត់

ចុះថ្លៃពិសេសទៅ
ស្រុកខ្មែរ សំបុត្រត្រូវ
ទិញឱ្យបានឆាប់បំផុត

**CAL -STATE**
**Realty & Lending**

Real Estate *Home Loans
*Residential * Commercial
You will get the best deal
Magaret (LiLy) Chung
Realtor
Sell your home at 3.5%
Buy your home at 1 % Rebate
ធ្វើការដោយស្មោះត្រង់និងយកចិត្តទុកដាក់ជានិច្ច

1065 E. Anaheim Street.
Long Beach, CA 90813
Tel: (562) 599 - 5464
Fax : (562) 599-5604
Tony´s Cell : (562) 537-3546
LiLy´s Cell : (562) 682-6588

4510 E. Pacific Coast Hwy,.
Ste.540 Long Beach, CA 90804
Tel: (562) 599-5464
Cell: (562) 682-6588
Fax: (562) 599-5604
Email : margaretchung@charter.net


KING KONG
STUDIO & DIGITAL LAB
Photography
"Capturing Moments..."
1617 E. Anaheim St. | Long Beach, CA 90813 | Tel.: (562) 591-2296
Hours: Monday - Sunday (9:30am - 6:00 pm)
Passport+Immigration Photo - in 5min.
Wedding
Glamour
Family
Children
Restoration
មានសំលៀកបំពាក់
សំរាប់តុបតែង
ថតរូបបែបបុរាណ
និងសម័យ
@ www.kksphotostudio.com
●ទទួលផ្ញើលិខិតឯកសារតាម E-mail
●មានធ្វើ Flyer , Name Card,Notary
មានទទួលធ្វើតាក់ សូមអញ្ជើញមកជួបអ្នកជំនាញឯកទេសCPA
Photography | Videography | Film | Digital Media | Frames
KKS
មានថតរូបសំរាប់ធ្វើលិខិតឆ្លងដែន ,ទិដ្ឋាការ និងកិច្ចការអន្តោប្រវេសន៍
1617 E. Anaheim St. | Long Beach, CA 90813 | Tel.: (562) 591-2296



ពី RHODE ISLAND
ហាង វីដេអូ ពិភពខ្មែរ
Khmer World Video Store (KW)
មានលក់
●DVD & CD ខ្មែរ គ្រប់ផលិតកម្ម
●រឿងកំប្លែងខ្លី, កុនខ្មែរ, កុនថៃ និងកុនចិនភាគ គ្រប់រឿង
●ម៉ាស៊ីន Karaoke និងប្រព័ន្ធសំលេង
●អនុស្សាវរីយ៍គ្រប់ប្រភេទ
●ទូរស័ព្ទដៃ (Unlocked) ដែលអាចប្រើជាមួយ ទូរស័ព្ទគ្រប់ប្រព័ន្ធ
KW
Address: 301 Reservoir Ave. Providence RI 02907, Tell: (401) 467 5900

# MODERN FABRIC & SHOES



សូមស្វាគមន៍
ដោយក្តីញញឹម !











-ហាងយើងខ្ញុំមានលក់ ក្រណាត់ប៉ាក់ ស្បែកជើង
សំលៀកបំពាក់
-ទទួលកាត់សំលៀកបំពាក់គ្រប់ម៉ូដសំរាប់បុរស និងស្ត្រី
-សំអាងការតាមបែបបុរាណ និងសម័យ

1636 E. Anaheim Street Long Beach, CA 90813

Tel: (562) 599-3333 • (562) 599-3237




# វិធីថែរក្សាសក់ដោយវិធីងាយៗ

**●វិធីធ្វើឱ្យសក់ក្រាស់**

ប្រសិនបើលោកអ្នកមានសក់តិច ឬស្តើង (មិនមែនក្បាលទំពែក) ហើយចង់បានសក់ក្រាស់នោះ តាមក្បួនបូរាណបានណែនាំថា ឱ្យយកក្បាលខ្ទិះដូងដែលទើបច្របាច់ហើយថ្មីៗលាយជាមួយទឹកក្រូចសើច បន្ទាប់មកយកសក់លោកអ្នកជ្រលក់ចូលទឹកដែលផ្សំនោះ ទុកចោលមួយសន្ទុះ ប្រសិនយកកន្សែងជូតទុកផងរិតតែប្រសើរ ។ ក្រោយមកលោកអ្នកកក់វាចេញជាការស្រេច ។ បើលោកអ្នកធ្វើតាមវិធីនេះច្រើនដងនោះ មិនយូរទេសក់លោកអ្នកឡើងក្រាស់ខ្មៅ ហើយភ្លឺរលោងទៀតផង ។

ឯវិធីនេះគេអាចប្រើបណ្តុះរោមចិញ្ចើមផងដែរ គឺយើងលាយចំណែកផ្សំស្អិត ហើយយកច្រាសដុះធ្មេញជ្រលក់ទឹកថ្នាំលាបលើរោមចិញ្ចើមទុកវាចោលឱ្យស្ងួត ។ លោកអ្នកត្រូវចាំថា ពេលដែលលាបទឹកថ្នាំគួតេងផ្ងារ ដើម្បីឱ្យទឹកថ្នាំហូរចូលភ្នែក លុះទុកចោលមួយសន្ទុះក្រោយមកល្មមតែទឹកថ្នាំជ្រាបចូលរន្ធរោម ហើយទើបលាងចេញនោះ ចិញ្ចើមលោកអ្នកមានរោមក្រាសហើយខ្មៅផង ។ កុំភ្លេចសាកល្បងធ្វើតាមវិធីនេះណា ។

**●សក់ខ្មៅរលើបរលោងដោយក្រូចសើច**

សក់ស្អាតខ្មៅរលីបរលោងជាវត្ថុបំណង ដែលគ្រប់គ្នាប្រាថ្នាចង់បាន ប៉ុន្តែប្រសិនបើមានអង្គែមករំខាន ក៏អាចធ្វើអ្នកអស់ទំនុកចិត្តដូចគ្នា ។ ចូលអ្នកធ្វើសាកល្បងតាមវិធីនេះលមើល យកផ្លែក្រូចសើចទៅស្ងោរក្នុងទឹកពុះ ។ ក្រោយពីស្ងោររួចហើយ យកក្រូចនោះមកច្របាច់យកតែទឹក ហើយយកវាមកលាបផ្អាប់លើកសក់ ទុកចោលប្រមាណ ១០-១៥ នាទីហើយលាងចេញ ។ វិធីបែបនេះ បើលោកអ្នកអាចធ្វើបាននោះ ពិតជាធ្វើឱ្យសក់ក្បាលរបស់លោកអ្នកមានសុខភាពល្អ និងគ្មានអង្គែរំខានឡើយ ។

**●សក់ទន់ស្អាតដោយស្រាបៀរ**

**និងស៊ុតផ្លែកស**

ចំពោះលោកអ្នកដែលមានសក់ក្បាលស្ងួតមិនរលើបរលោងនោះ លោកអ្នកអាចសាកល្បងយកវិធីងាយស្រួលមួយ ដោយលោកអ្នកយកស្រាបៀរ ដែលក្លាសេ្សឱ្យត្រជាក់មកលាយជាមួយនឹងពងមាន់យកតែផ្នែកស ហើយយកមកច្របល់លាយឱ្យសព្វជាមួយនឹងស្រាបៀរ រួចហើយយកមកជ្រលក់លាបឱ្យសព្វសក់ទុកចោលមួយសន្ទុះ ហើយលាងចេញដោយទឹកស្អាត ។ តែប៉ុណ្ណោះសក់របស់លោកអ្នកខ្មៅរលីបរលោងបន្ថែមភាពជឿជាក់ដល់ខ្លួនអ្នកមួយកម្រិតទៀត ។ ក្រៅពីវិធីខាងលើនេះ គឺមានវិធីមួយទៀតចំពោះអ្នកដែលមានសក់ស្ងួត គឺលោកអ្នកគ្រាន់តែយកពងមាន់ពីរគ្រាប់លាយជាមួយនឹងប្រេងប៉ារ៉ាហ្វីនមួយស្លាបព្រា រួចហើយយកទៅលាយនឹងស្រា-សមួយកែវតូចកូរជាមួយគ្នាឱ្យសព្វ ហើយបន្ទាប់មកលោកអ្នកត្រូវចាក់ទឹកលើសក់ឱ្យជោកសិន ទើបយកល្បាយដែលលាយហើយនោះ មកជ្រលក់លាបឱ្យសព្វលើសក់ក្បាលផ្អាប់ទុករយៈពេលពី១០-១៥នាទី រួចហើយត្រូវយកទឹកមួយកាធុនលាយជាមួយទឹកក្រូចឆ្មា ឬទឹកខ្មេះក៏បានចំនួនពីរស្លាបព្រាបាយ ហើយយកមកកក់សក់នោះ លោកអ្នកនឹងបានឃើញសក់របស់អ្នកទន់ និងភ្លឺរលោង ៕



# អាថ៌កំបាំងទឹក ជួយឱ្យស្ត្រីស្រស់ស្អាត

**តាមការស្រាវជ្រាវគេបានរកឃើញថា ទឹកមិនត្រឹមតែជួយឱ្យមានជីវិតរស់នៅយ៉ាងឋិតថេរទេ ថែមទាំងជួយឱ្យស្ត្រីមានសម្រស់ដ៏ផូរផង់ទៀតផង ។**

**-មុនចូលដំណេក** : ទទួលទានទឹកមួយកែវនឹងជួយកាត់បន្ថយភាពស្រេកឃ្លានទឹកនៅពេលពាក់កណ្តាលយប់ ជាពិសេសជួយឱ្យមានតុល្យភាពទឹកនៅក្នុងរាងកាយ ដែលត្រូវបាត់បង់ពេលទទួលទានដំណេកតាមរយៈខ្យល់ដកដង្ហើម ការបញ្ចេញញើសជាដើម ។




**-ភ្ញាក់ពេលព្រឹក** : ច្របាច់ក្រូចឆ្មារចូលក្នុងទឹកស្អាតល្អ ហើយទទួលទាននឹងជួយដាស់អារម្មណ៍គ្រប់ផ្នែកក្នុងរាងកាយឱ្យបាត់ងងុយដេក ឬស្វាបដោយភាពងងុយបាន ។ ជាមួយគ្នានេះ រសជាតិជូររបស់ក្រូចឆ្មារនៅជួយជំរុញឱ្យមានភាពស្រស់ស្រាយទូទាំងរាងកាយបានផង ។

**-ងូតទឹក** : ការងូតទឹកអាចជួយឱ្យស្បែកមានសំណើមមិនស្ងួតសោះកក្រោះ ។ ជាទូទៅស្ត្រីប្រើពេលងូតទឹកគិតជាមធ្យម១២នាទី ។ អ្នកឯកទេសបានធ្វើការណែនាំឱ្យស្ត្រីប្រើពេលងូតទឹកប្រចាំថ្ងៃក្នុងមួយលើកៗត្រឹម៥នាទី ជាការគ្រប់គ្រាន់ ហើយត្រូវជូតខ្លួនឱ្យបានថើៗមានសំណើមទឹកនៅជាប់លើខ្លួនឱ្យបានច្រើនជាការប្រសើរបំផុត ។ ក្នុងថ្ងៃណាដែលមានអារម្មណ៍តឹងតែងអ្នកអាចប្រើទឹកសម្រាប់បំបាត់អាការៈនេះចេញពីខ្លួនក៏បាន ។

វិធីបំបាត់មានច្រើនបែបទៅតាមអ្នកចូលចិត្ត និងភាពងាយស្រួលតែប៉ុណ្ណោះ ធ្វើយ៉ាងណាឱ្យមានអារម្មណ៍ធូរស្បើយ និងមានសេចក្តីសុខ ។

**-ត្រាំក្នុងទឹក** : បើកទឹកក្តៅឧណ្ហៗឱ្យពេញអាង រួចហើយប្រើខ្ទីដែលចិតជាបន្ទះស្តើងៗចាក់ចូលក្នុងអាងទឹកនោះ ត្រាំទុកចោលមួយសន្ទុះ ហើយអ្នកចូលដេកត្រាំខ្លួនឱ្យបានប្រហែល២០នាទី (**តទៅទំព័រទី២៧**)

ក្រុមហ៊ុនធានារ៉ាប់រង
TOP AUTO INSURANCE AGENCY

នាងខ្ញុំនិយាយភាសាខ្មែរ

AUTO -LIFE-HEALTH-HOME-COMMERCIAL
រថយន្ត-ជីវិត-សុខភាព-គេហដ្ឋាន-ពាណិជ្ជកម្ម

-Immediate Coverage FREE QUOTE Instant SR22
-Any car, any driver LOW RATES Why pay more



Tiffany Prak
Broker/Agent Lic.# 0E44334
(562) 230-5100

-Low Cost. Low Down
. Low Monthly Payment
Tickets, accident,DUI=No Problem

- Multiple Car discount
- Good driver discount
- ធានារ៉ាប់រងជូនភ្លាមៗដល់អ្នកបើកបរគ្រប់រូប និងយានយន្តគ្រប់ប្រភេទ
- ចុះថ្លៃជូនអ្នកបើកបរមានសុវត្ថិភាព និងចុះថ្លៃជូនចំពោះរថយន្តច្រើន
- បង់កាត់ខែតិច • ជំរាបតម្លៃជូនជាមុន

2760 E. Sprint St., Suite 140 • Long Beach, CA 90806
Tel: (562) 989-1800 Fax: (562) 989-1899

ហាងខ្មែរលក់គ្រឿងបន្លាស់រថយន្ត
**Parts For Less**
**Auto Parts & Accessories**
1050 E. Pacific Coast Hwy.
Long Beach, CA 90806
**562-599-6364**

មានលក់គ្រឿងបន្លាស់រថយន្តគ្រប់ប្រភេទសម្រាប់ក្រៅនិងក្នុងស្រុក ។ ទំនិញយើងខ្ញុំលក់តម្លៃសមរម្យ និងធានារកជូនលោកអ្នកនូវទំនិញដែលមិនមានក្នុងហាងយើងខ្ញុំ ។

Complete Foreign & Domestic Parts

**សូមអញ្ជើញដោយមេត្រីភាព!**



សុខភាព

# អាហារ និងកាយវិការដើម្បីសុខភាព



**-ត្រូវទទួលទានអាហារ"ប្រូតេអ៊ីន" :** អ្នកមានទម្លាប់លោភញ៉ាំបន្តិច នៅពេលព្រឹក ឬពេលរសៀលនៅចន្លោះអាហារពេលទាំងបី ដូចជាញ៉ាំនំ biscuits ពីរ-បី ឬសូកូឡាមួយបន្ទះ ដើម្បីផ្ទេរទៅជាថាមពល និងរក្សារាង របស់អ្នក ? អ្នកត្រូវប្តូរការចូលចិត្តចំណីអាហារឆ្ងាញ់របស់អ្នកមកជាការ ញ៉ាំចំណីអាហារដែលសម្បូរប្រូតេអ៊ីន (ហ្រ្វូម៉ាស្ស-ស មិនសូវមានខ្លាញ់ ស៊ុតស្ងោរហ្រ្វូម៉ាស្សគ្មានខ្លាញ់) ។

ជាដំបូងដើម្បីកាត់បន្ថយអាហារកាឡូរីប្រចាំថ្ងៃរបស់អ្នក(នំ Tarte ធ្វើពីផ្លែប៉ោមមាន៤០០គីឡូកាឡូរីជាមធ្យមស៊ុតមួយមានតែ៨០គីឡូកាឡូរី) ប៉ុន្តែក៏ត្រូវបន្ថែមប្រូតេអ៊ីនផងដែរ ព្រោះវាត្រូវការថាមពលច្រើនថែមទៀត ដែលសរីរាង្គត្រូវការស្រូបយក(រវាង២០ និង៤៥% នៃ កាឡូរីដែលប្រូតេអ៊ីន ផ្តល់ឱ្យសុទ្ធតែចាំបាច់ក្នុងការបំប្លែងថាមពលពី១០ទៅ១៥% សម្រាប់ស្ករ និង២ ទៅ៤%សម្រាប់ខ្លាញ់ ) ។

**-ត្រូវផឹកទឹក ប៉ុន្តែជាទឹកត្រជាក់ :** លោកវេជ្ជបណ្ឌិត ព្យែរ ឌុយកង់ (PierreDuKan) បាននិយាយថា កាលណាយើងផឹកទឹកដែលយកចេញពីទូទឹកកក ដែលមានសីតុណ្ហភាពទឹកនោះដល់៣៣អង្សាសេ (ដើម្បីបានទៅដល់៣៧អង្សាសេនៃសីតុណ្ហភាពខាងក្នុង) មុននឹងប្រែក្លាយជាទឹកមូត្រ ។ ក្នុងរូបធាតុកាឡូរីវិញ ប្រតិបត្តិការនេះរឹតតែស័ក្តិសិទ្ធិ ពីព្រោះវាជួយឱ្យអ្នកអាចដុតបំផ្លាញរហូតដល់៦០គីឡូកាឡូរីក្នុងមួយថ្ងៃដោយគ្មានខំប្រឹងអ្វីទាល់តែសោះ ។

**-ត្រូវពត់ខ្លួន១០នាទីមុនក្រោកពីគ្រែ :** គឺជាមធ្យោបាយល្អបំផុតក្នុងការភ្ញាក់ពីដំណេកដោយសន្សឹមៗ និងរៀបចំសម្រួលរាងកាយឱ្យដំណើរការហើយក៏ជាមធ្យោបាយល្អផងដែរក្នុងការដុតបំផ្លាញថាមពលរហូតដល់៣០គីឡូកាឡូរីពីខ្លាញ់បម្រុងទុករបស់អ្នក (ទោះបីជាអ្នកមិនទាន់បានញ៉ាំអាហារពេលព្រឹកក៏ដោយ) ។

**-ត្រូវប្រឹងហាត់ដើរ១០នាទីក្នុងមួយថ្ងៃ :** បើអាចឆ្លៀតទៅរួចយកល្អគួរហាត់ក្រោយពេលបាយថ្ងៃត្រង់ ។ ព្រោះថា វានឹងជួយអ្នកក្នុងការរំលាយអាហារបានល្អ និងជាពិសេសវាជួយដុតបំផ្លាញថាមពលលើសពី៣០គីឡូកាឡូរីក្នុងមួយថ្ងៃ ។ ការចំណាយពេលតែប៉ុន្មាននាទីនេះ មានប្រយោជន៍មួយទៀតលើរាងកាយរបស់អ្នក គឺនាំឱ្យអ្នកបង្កើតការចំណាយថាមពលមូលដ្ឋាន ។ មិនតែប៉ុណ្ណោះក៏អាចពង្រឹងសាច់ដុំរបស់អ្នកបានដែរ ។

**-ត្រូវបញ្ចប់ការងូតទឹកត្រជាក់ :** សម្រាប់ការកាត់បន្ថយសីតុណ្ហភាពលើផ្ទៃរាងកាយរបស់អ្នកអ្នកត្រូវដាស់ភ្ញោចរាងកាយឱ្យបញ្ចេញថាមពលដើម្បីលៃឱ្យមានកម្តៅស្មើគ្នា ។ បើអ្នកចាញ់ត្រជាក់អ្នកគួរតែស្រោចស្រពទឹកត្រជាក់ត្រង់កន្លែងណាដែលមិនសូវទទួលអារម្មណ៍ ដូចជាភ្លៅ ជើង ប្រអប់ជើង ។ បើអ្នកមិនខ្លាចត្រជាក់អ្នកត្រូវបាញ់ទឹកត្រជាក់លើរាងកាយដែលជាកន្លែងមានឈាមក្តៅក្នុងបរិមាណស្មើគ្នាដូចជាក្លៀកផ្នែកក្រោយនៃជង្គង់ ក្រលៀន...។ ៣០ វិនាទីនៃការងារញ័រញាក់អាចធ្វើឱ្យអ្នកកម្ចាត់កម្តៅរហូតដល់២៥គីឡូកាឡូរីក្នុងមួយថ្ងៃ ។

**-ត្រូវកាត់បន្ថយស្ករមួយដុំក្នុងមួយថ្ងៃ :** អ្នកត្រូវសាកល្បងផឹកតែ ឬកាហ្វេ"ធម្មជាតិ" ឱ្យបានយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ។ សម្រាប់ស្ករមួយដុំទម្ងន់៥ក្រាមមាន២០គីឡូកាឡូរី អ្នកអាចសន្សំបាន៦០០គីឡូកាឡូរីក្នុងមួយខែ គឺស្មើនឹងការបំផ្លាញកាឡូរីដោយការដើរចម្ងាយ១៨គីឡូម៉ែត្រ ។

**-ត្រូវបន្ថយកម្រិតកម្តៅ :** ការរស់នៅដ៏សាមញ្ញនៅក្នុងបរិយាកាសមិនសូវក្តៅនាំឱ្យរាងកាយរបស់អ្នកបង្កើនការចំណាយថាមពលជាក់ស្តែងដើម្បីកម្តៅខ្លួនឯង ។ ថាមពលជាក់ស្តែង គឺមានន័យថា ប្រហែល៣០គីឡូកាឡូរីក្នុងមួយថ្ងៃដើម្បីឱ្យកម្តៅខ្លួនអ្នកមានស្ថេរភាព ។ ជាក់ស្តែងអ្នកចាំបាច់ត្រូវតែហាត់ធាក់កង់យ៉ាងលឿន (១៥គីឡូម៉ែត្រក្នុងមួយម៉ោង) ចំនួន៧នាទី ៕

## អាចកំចាំងទឹក...

នឹងអាចជួយបន្ថយភាពតឹងតែងនៃសាច់ដុំ ជួយស្បែកឱ្យបញ្ចេញញើសតាមរន្ធរោមបានច្រើនឡើង ។ ពេលដេកត្រាំទឹកនេះ គួរទទួលទានទឹកស្អាតខ្លះៗផង ដើម្បីការពាររាងកាយពីការខ្វះខាតទឹក ។ អ្នកអាចធ្វើក្នុងមួយសប្តាហ៍មួយលើកក៏គ្រប់គ្រាន់ មិនដូច្នេះស្បែកនឹងឡើងស្ងួតសោះកក្រោះ ។

**-បាញ់ទឹកលើស្បែក :** បើកទឹកផ្កាឈូកតិចៗ ចរន្តទឹកនឹងធ្លាក់កាត់ស្បែកមុខថ្នមៗ និងយឺតៗ ។ ដាក់ផ្កាឈូកឱ្យឃ្លាតឆ្ងាយពីស្បែកប្រហែល៩សង់ទីម៉ែត្រ ដើម្បីកុំឱ្យកម្លាំងទឹកប៉ះត្រូវស្បែកខ្លាំងពេក ដែលវិធីនេះអាចជួយឱ្យស្បែកមានសំណើម និងមានភាពស្រស់ថ្លាឡើងយ៉ាងឆាប់រហ័ស ។

**-តម្រូវការទឹកក្នុងមួយថ្ងៃ :** តម្រូវការទឹកនៃសរីរាង្គកាយរបស់មនុស្សយើងម្នាក់ៗមានសភាពខុសប្លែកពីគ្នា និងទៅតាមវដ្តរកាល ។ ក្នុងរាងកាយរបស់យើងមានទឹកលាយផ្សំប្រហែល៧០% នៃទម្ងន់រាងកាយទាំងមូល ។ នៅត្រង់ស្បែក បើសិនខ្វះខាតទឹកនឹងនាំឱ្យស្បែកកើតស្នាមជ្រីវជ្រួញឆាប់រហ័សជាងធម្មតា ហើយបង្កឱ្យកើតការឆាប់ចាស់បានបំផុត ។ ទទួលទានមិនត្រឹមត្រូវ តែជួយនូវផលប្រយោជន៍ទាំងអស់នោះទេ ប៉ុន្តែបើសិនខ្វះខាតទឹកនេះ នឹងធ្វើឱ្យឆាប់អស់កម្លាំងកំហែងសាច់ដុំថមថយថាមពល និងផលប៉ះទង្គិចរយៈពេលយូរអង្វែង គឺនាំឱ្យកើតអាការឈឺខ្នង,ឈឺសន្លាក់, ទល់លាមក និងឫសដូងបាតបានផង ។ ស្ត្រីគ្រប់រូបគួរចងចាំទុកថា មិនត្រូវទទួលទានទឹក តែចំពោះការស្រេកប៉ុណ្ណោះទេ គួររកទទួលទានឱ្យបានគ្រប់ពេល បើមិនដូច្នេះទេ អ្នកនឹងស្ថិតក្នុងសភាពរាងកាយខ្វះខាតទឹកពុំខាន ។ បើទឹកក្នុងរាងកាយថយចុះត្រឹមតែ២% នឹងនាំឱ្យប៉ះពាល់ដល់ភាពចងចាំក្នុងរយៈពេលខ្លី ៕

## ភ្ញៀវទេសចរកើនឡើង...

អ្នកទេសចរដែលមកទស្សនាប្រទេសកម្ពុជាស្នាក់នៅរយៈពេលខ្លី ហើយមិនបានទៅកំសាន្តតាមតំបន់ឆ្ងាយៗឡើយ ដោយសារប្រព័ន្ធគមនាគមន៍មិនទាន់ល្អ ។

លោក ហូ វ៉ាន់ឌី ប្រធានសមាគមភ្នាក់ងារទេសចរណ៍កម្ពុជាបានមានប្រសាសន៍ថា រមណីយដ្ឋានដែលនៅឆ្ងាយៗ ដូចជា ប្រាសាទបន្ទាយឆ្មារ កោះកែ ប្រាសាទព្រះវិហារបានក្លាយជាគោលដៅទេសចរដ៏សំខាន់របស់អ្នកទេសចរទាំងក្នុង និងក្រៅប្រទេស ។

ប៉ុន្តែតំបន់ទេសចរណ៍មួយចំនួននៅជួបការរាំងស្ទះក្នុងការអភិវឌ្ឍ ដោយសារហេដ្ឋារចនាសម្ព័ន្ធសេវាកម្មមិនសូវល្អ បញ្ហានេះត្រូវបានលោក ហូរ វ៉ាន់ឌី អះអាងថា បណ្តាលមកពីប្រព័ន្ធគមនាគមន៍មិនសូវល្អ មិនសូវមានមគ្គុទ្ទេសក៍គ្រប់គ្រាន់សម្រាប់នាំផ្លូវអ្នកទេសចរ ។ ម្យ៉ាងទីកន្លែងនោះមិនមានហាងទទួលទានតាមតម្រូវការ និងមិនមានស្លាកសញ្ញាសម្រាប់ចង្អុលបង្ហាញដល់ភ្ញៀវ ដែលជាហេតុធ្វើឱ្យពួកគេមានការភ័យខ្លាច និងមិនចង់ស្នាក់នៅច្រើនថ្ងៃ ។

**បញ្ហាប្រឈមមុខដែលធ្វើឱ្យប្រាក់ចំណូលហូរចេញ :**

វិស័យទេសចរណ៍ ត្រូវបានគេសង្កេតឃើញមានការកើនឡើងជារៀងរាល់ឆ្នាំ ហើយក្លាយជាវិស័យអាទិភាពក្នុងការអភិវឌ្ឍប្រទេសជាតិ ប៉ុន្តែប្រាក់ចំណូលបានហូរទៅវិញអស់ប្រមាណជាង៥០% ។ បញ្ហានេះ ត្រូវបានលោក ហូរ វ៉ាន់ឌី បញ្ជាក់ថា បណ្តាលមកពីមធ្យោបាយដឹកជញ្ជូន សណ្ឋាគារ ភោជនីយដ្ឋាន មគ្គុទ្ទេសក៍ ហាងលក់វត្ថុអនុស្សាវរីយ៍ ភាគច្រើនជារបស់បរទេសទាំងអស់ ។ ប្រាក់ដែលហូរចេញនេះ គឺប្រហែលជាង៥០% នៃចំនួនភ្ញៀវទេសចរ ។

ការហូរចេញនៃប្រាក់នេះ ត្រូវបានលោក ហូរ វ៉ាន់ឌី បញ្ជាក់ថា បណ្តាលមកពីរាជរដ្ឋាភិបាលបើកចំហខ្លាំងពេក ធ្វើឱ្យអ្នករកស៊ីបរទេសគេមានលទ្ធភាពឆក់យកឱកាសនេះ និងទាញយកប្រាក់ទាំងនេះទៅវិញ ។ ចំណែកខ្មែរយើងដែលទើបនឹងងើបពីសង្គ្រាមមានចំណេះដឹងតិចតួចទទួលបានការងារដែរតែតិចតួចណាស់ ។

**ទិសដៅខាងមុខសម្រាប់វិស័យទេសចរណ៍ :**

បើយោងតាមរបាយការណ៍ក្រសួងទេសចរណ៍នៅឆ្នាំ២០០៧ គេសង្ឃឹមថា ភ្ញៀវទេសចរនឹងមានការកើនឡើងដល់ឆ្នាំ២០១២ ។ តាមរបាយការណ៍នោះបានអះអាងថា នៅឆ្នាំ២០១២ ភ្ញៀវកាន់តែកើនឡើងច្រើនជាង៥លាននាក់ ដែលមកទស្សនាប្រទេសកម្ពុជា ហើយក្នុងនោះមកទស្សនាខេត្តសៀមរាបកើនឡើងដល់៣លាននាក់ តាមរយៈជើងយន្តហោះ ។ គេសង្ឃឹមថា នៅឆ្នាំ២០១២ នឹងមានប្រាក់ចំណូល២.៣លានដុល្លារ និងមាននិយោជិក និយោជកកើនឡើង៣៦៥.០០០នាក់ ។

បើយោងតាមកិច្ចប្រជុំពាណិជ្ជកម្មការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងការអភិវឌ្ឍប្រទេស នៅថ្ងៃទី១៩ និង២០ កាលពីខែ វិច្ឆិកា ឆ្នាំ២០០៧

( តនៅទំព័រទី៣៤ )

## តាប្រពន្ធ៨ចេះផ្សំថ្នាំប្រយុទ្ធលើគ្រែពូកែស័ក្តិសិទ្ធិ

*កំពង់ធំ: សម្ផស្ស*

មនុស្សម្នាជាច្រើនតែងត្អូញត្អែរដាក់គ្នាពីរឿងបាត់បង់សមត្ថភាពផ្លូវភេទ កាលណាចូលដល់វ័យកណ្តាលហើយនោះ ។ ដោយឡែកលោក យឹម ផង់ អាយុ៧៤ឆ្នាំ រស់នៅ ភូមិក្រយា ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មានប្រពន្ធ៨នាក់ កូន១៩នាក់ ។

លោកតាទោះបីតែមានវ័យចំណាស់ពិតមែនតែកំលាំងកំហែងនៅមាំមួនខ្លាំងណាស់ ហើយប្រពន្ធគាត់ថា ក្នុងមួយយប់គាត់មានសមត្ថភាពអាចប្រយុទ្ធបាន៣ទៅ៤លើក ។ ជាពិសេសនោះ គាត់ចេះវិជ្ជាផ្សំថ្នាំពិសេសសំរាប់បុរស-ស្ត្រី ដែលបាត់បង់សមត្ថភាពឱ្យមានចលនារស់រវើកឡើងវិញបានទៀតផង ។

លោកតា យឹម ផង់ បានរៀបរាប់ថា លោកចេះវិជ្ជាផ្សំថ្នាំនេះតាំងពីនៅវ័យក្មេងម្ល៉េះ គឺចេះពីលោកគ្រូ ជ័យ សុខ ។ លោកបានបញ្ជាក់ថា មានចំណេះផ្សំថ្នាំបាន១០មុខព្យាបាលជំងឺ១០ប្រភេទ ហើយថ្នាំរបស់គាត់ដែលពូកែជាងគេនោះ គឺថ្នាំប៉ូវកំលាំងយក្ស ។ មានន័យថា អ្នកដែលធ្លាប់តែរួមរ័ក បានតែម្តងក្នុងមួយយប់អាចមានកំលាំងដល់ទៅ៣ឬ៤ដង ក្នុងមួយយប់ បន្ទាប់ពីផឹកថ្នាំរបស់គាត់រួចហើយ ។

លោកតាប្រពន្ធ៨ បានបន្តថា បើគាត់មិនខ្លាំងទេ គឺមិនអាចគ្រប់គ្រងប្រពន្ធដល់ទៅ៨នាក់បានទេ គឺប្រពន្ធរបស់គាត់នៅផ្ទះបែកគ្នា មានតែប្រពន្ធទី១ និងទី៤ទេ ដែលរស់នៅជុំគ្នា ។ សព្វថ្ងៃគាត់មានកូន១៩នាក់ ចៅ៤នាក់ និងចៅទួត២នាក់ ទៅហើយ ។

តាប្រពន្ធ៨ បានបន្តទៀតថា ថ្នាំរបស់គាត់នេះ គឺផ្សំឡើងពីឫសឈើ សំបកឈើ ដែលត្រូវទៅរកនៅលើភ្នំ និងព្រៃជ្រៅ ។ សព្វថ្ងៃនេះ មានអតិថិជនជិតឆ្ងាយទៅទិញដល់ផ្ទះផ្សំស្ទើរតែមិនទាន់ផង ។

លោកយាយ ស៊ុយ ថេន ប្រពន្ធទី១ និង នៅ រស់ ប្រពន្ធទី៤ បានរៀបរាប់ថា ប្តីរបស់គាត់ទោះបីជាមានអាយុចាស់មែន ប៉ុន្តែមានកំលាំងដូចក្របីមិនចាញ់ក្មេងៗកំលោះនោះទេ ។ ប្តីរបស់គាត់ក្នុងមួយសប្តាហ៍បាន៤ទៅ៥ដងដែរ ហើយម្តងៗយូរណាស់ ពួកគាត់ស្រីៗស្ទើរតែផុតដង្ហើម ។

អ្នកនៅភ្នំពេញ ឈ្មោះ សេង ចាន់ថា បានឱ្យដឹងថា នៅពេលគាត់ប្រើថ្នាំលោក យឹម ផង់ ម្តងៗមានកំលាំងដូចយក្ស ដែលកាលពីមុនក្នុងមួយយប់តែម្តងស្ទើរស្លាប់ ។ តែពេលនេះ មួយយប់អាចចាត់ការបានពី៣ទៅ៤ដងគ្មានបញ្ហា ៕


ក្រុមតន្ត្រីសោភារី

Sopheary Band

រីករាយបំពុំកក្នុងការប្រគុំតន្ត្រីជូនលោក-អ្នកក្នុងពិធីបុណ្យផ្សេងៗ ។

សូមទាក់ទងអ្នកគ្រប់គ្រង :

Charlie Ouk 562-591-2011

Cell: 562-400-7678



# លែងសត្វឱ្យមានសេរីភាពជឿថា អាចរំដោះគ្រោះចង្រៃ

*ភ្នំពេញ : គីម សារឿន*

ឥទ្ធិពលសាសនាបានចាក់ឫសយ៉ាងជ្រៅក្នុងផ្នត់គំនិតរបស់ប្រជាពលរដ្ឋខ្មែរស្ទើរគ្រប់វិស័យ តាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្ន ហើយនៅពេលណាពួកគេជួបទុក្ខលំបាកម្តងៗ តែងធ្វើការបន់ស្រន់ បួងសួងចំពោះអាទិទេព អារក្សអ្នកតា សូត្រមន្តរំដោះគ្រោះចង្រៃ និងលែងសត្វឱ្យមានសេរីភាពជាដើម ។

ការលែងសត្វឱ្យមានសេរីភាពនេះ អ្នកស្រុកជាច្រើនមានជំនឿថា អាចរំដោះកម្មពៀរវេរា ឧបទ្រវចង្រៃផងទាំងពួង ជាពិសេសធ្វើឱ្យពួកគាត់កាន់តែមានអារម្មណ៍ស្រស់ថ្លាក្នុងជីវិតមួយកម្រិតថែមទៀត ។

អ្នកស្រុកដែលរស់នៅទីក្រុងក៏ដូចជនបទដែរ នៅពេលណាដំណើរជីវិតផ្ទាល់ខ្លួន និងក្រុមគ្រួសារមានជួបនឹងរឿងរ៉ាវអពមង្គល ពួកគាត់តែងរិះរកគ្រប់វិធី ដើម្បីរំដោះគ្រោះចង្រៃទាំង



កន្លែងលក់ និងលែងសត្វនៅមុខព្រះអង្គដងកើ

នេះ ។ គ្រោះចង្រៃដែលអ្នកស្រុកកត់ចំណាំនោះរួមមាន : ប្រកបមុខរបរមិនបានផល ជំងឺបៀតបៀន យល់សប្តិមិនល្អ មានទំនាស់ញឹកញាប់ ។ ពេលមានបញ្ហាទាំងនេះកើតឡើងម្តងៗអ្នកខ្លះទៅរកហោរាទស្សន៍ទាយរកថ្ងៃល្អ ដើម្បីរៀបចំពិធី ដោយអ្នកខ្លះទៀតទៅនិមន្តព្រះសង្ឃសូត្រមន្តរំដោះគ្រោះលើករាសី និងអ្នកខ្លះទៀតទិញសត្វលែងតាមជំនឿរៀងៗខ្លួន ។

ការលែងសត្វឱ្យមានសេរីភាព ទៅជួបក្រុមគ្រួសាររបស់វាវិញនោះ គឺជាជំនឿរបស់អ្នកស្រុកនិយមធ្វើតាំងពីយូរលង់ណាស់មកហើយ ដែលមនុស្សគ្រប់វ័យនិយមអនុវត្តនៅគ្រប់តំបន់ ។ ពួកគេជឿថា បន្ទាប់ពីលែងសត្វឱ្យរួចខ្លួនហើយ ឧបទ្រវចង្រៃ ជំងឺបៀតបៀននឹងចៀសចេញឆ្ងាយ ហើយសិរីសួស្តីប្រាកដជាកើតមានដល់ពួកគេ គឺធ្វើឱ្យពួកគេមានអារម្មណ៍ល្អទៀតផង ។ អ្នកខ្លះដែលមានធនធានច្រើន បន្ទាប់ពីលែងសត្វក៏ចែកទានដល់ជនក្រីក្រតាមសទ្ធាជ្រះថ្លារបស់ខ្លួន ។

ការលែងសត្វឱ្យរួចពីទ្រុងនេះ មិនត្រឹមតែជួយដល់សត្វឱ្យបានរួសរានមានជីវិតប៉ុណ្ណោះទេ ប៉ុន្តែអ្នកស្រុកជឿថា សត្វទាំងនោះនឹងពាំនាំយកនូវគ្រោះចង្រៃទៅតាមខ្លួន ហើយឱ្យពរជ័យសិរីសួស្តីត្រលប់មកវិញមិនខាន ។ សត្វដែលគេនិយមលែង គឺសត្វដែលជាប់ក្នុងទ្រុងចំណែកអ្នកខ្លះទិញត្រីពីផ្សារយកទៅលែងក្នុងបឹងបួដែលមានទឹកជ្រៅ ដើម្បីឱ្យវាគេចផុតពីការចាប់ ឬប្រមាញ់របស់ព្រាន ។

ដោយសារសត្វមានសារប្រយោជន៍ អ្នកខ្លះមិនទទួលទានសាច់នោះទេ ជាពិសេសសត្វអណ្តើកឃើញមានចារអក្សរនៅពោះ ឬលើខ្នង គឺគេមានទម្លាប់មួយមិនទទួលទាននោះទេ ដោយចារបន្ត ហើយលែងបន្តទៅវិញ ។ ការលែងអណ្តើកនេះ គេមានជំនឿថា នឹងមានអាយុវែងដូចសត្វអណ្តើក ហើយមុនពេលលែងពួកគេធ្វើការបន់ស្រន់ ចំពោះវត្ថុស័ក្តិសិទ្ធិជួយថែរក្សាដល់ក្រុមគ្រួសាររបស់គេឱ្យមានសេចក្តីសុខរកស៊ីមានបានចាប់តាំងពីពេលនេះតទៅ ។

នៅតាមបណ្តាខេត្តនានា គេពុំសូវមានលែងសត្វច្រើននោះទេ ប៉ុន្តែ នៅទីក្រុងភ្នំពេញត្រង់ចំណុចព្រះអង្គដងកើពីមុខព្រះបរមរាជវាំង នៅថ្ងៃសីលគេសង្កេតឃើញមានប្រជាពលរដ្ឋជាច្រើនបាននាំគ្នាទៅធ្វើការ បួងសួង ដោយមាន ធូប ទៀន ផ្កាភ្ញី ប្រាថ្នាសុំឱ្យសុខសប្បាយ ខ្លះលាបំណន់ និងមានភ្លេងពិណពាទ្យកំដរផង ។ បន្ទាប់ពីធ្វើការបួងសួងរួចពុទ្ធ-សាសនិកទាំងនោះ ខ្លះក៏ទៅទិញសត្វមួយគូ ឬពីរគូលែងដោយម្នាក់ៗបានធ្វើការបួងសួងតាមបំណងប្រាថ្នារៀងៗខ្លួន ។

អ្នកស្រី ឡន លាងស៊ីម អាយុ៤៩ឆ្នាំ រស់នៅសង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ បានរៀបរាប់ថា គាត់មកធ្វើការបន់ស្រន់ និងលែងសត្វនៅមុខព្រះអង្គដងកើរៀងរាល់ថ្ងៃសីលជាមួយកូនចៅក្នុងគោលបំណងសុំសេចក្តីសុខសប្បាយដល់ក្រុមគ្រួសារ និងរំដោះនូវគ្រោះចង្រៃកម្មពៀរវេរាឱ្យអស់ ។

អ្នកស្រីបន្តថា នៅពេលលែងសត្វម្តងៗ គាត់តែងតែធ្វើការបួងសួងចំពោះវត្ថុស័ក្តិសិទ្ធិឱ្យជួយថែរក្សាកូនចៅបានសុខសប្បាយគ្រប់ៗគ្នា ហើយពេលណាគាត់បានលែងសត្វម្តងៗក្នុងអារម្មណ៍ ហាក់ដូចជាធូរស្បើយភ្លេចអស់នូវទុក្ខកង្វល់ដោយជឿថា សេចក្តីចម្រុងចម្រើន នឹងកើតមានដល់ក្រុមគ្រួសារមិនខានឡើយ ។

មិនថាតែប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រនោះទេ ដែលជឿលើការលែងសត្វនេះ សូម្បីតែអ្នករាជការ ឬថ្នាក់ដឹកនាំមួយចំនួន ពេលជួបនឹងរឿងរ៉ាវអពមង្គល ក៏ទៅទិញសត្វលែងដែរ ។ ម្យ៉ាងទៀតក្នុងពិធីបុណ្យធំៗ ដូចជាបុណ្យឯករាជ្យជាតិ គេសង្កេតឃើញព្រះមហាក្សត្រប្រមុខរាជរដ្ឋាភិបាលមន្ត្រីជាន់ខ្ពស់ បានធ្វើពិធីលែងសត្វនៅវិមានឯករាជ្យជារៀងរាល់ឆ្នាំ ក្នុងបំណងសុំឱ្យមហាគ្រួសារខ្មែរបានជួបតែសេចក្តីសុខ ។

លើសពីនេះទៅទៀត អតីតព្រះមហាក្សត្រ គឺព្រះបាទនរោត្តម សីហនុ ( **តទៅទំព័រទី៣២** )

គង់ថតរូបរហ័សទាន់ចិត្ត
KONG'S ONE HOUR PHOTO
DIGITAL LAB SYSTEM
PASSPORT & I.D PHOTOS
PRINTS FROM YOUR DIGITAL CAMERA
FAMILY PORTRAIT & WEDDING
DIGITAL HD VIDEO PRODUCTION
837 E.ANAHEIM ST.
LONG BEACH,CA 90813
BUS(562)218-8434
CEL(562)896-0742
www.weddingvfx.com
DIGITAL CAMERA
Pro HDV

From :Philadelphia
ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ
Rathe`s Auto Service
State and Emission
Inspection General
Repairs and Maintenance
MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY
-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងក៏រិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ កាត់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*
5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

H&S IRON WORK CORP
ក្រុមហ៊ុនធ្វើរបង និងទ្វារដែក
1433 Daisy Ave., Suite B Long Beach, CA 90813
Bus : (562) 435-8753 Cell : (562) 595-3644
ក្រុមហ៊ុនយើងខ្ញុំមានទទួលធ្វើ :
▶FOLDING GATES
▶WINDOW GUARDS ▶GATES
▶RAILLINGS ▶IRON SCREEN DOORS
▶WELDING SERVICES
▶FENCES
▶DRIVEWAY GATES
▶FIRE ESCAPES ▶STAIRS
សូមអញ្ជើញទាក់ទងជាមួយខ្ញុំ ដោយមេត្រីភាព !

# ក្រុងព្រះសីហនុជាតំបន់សេដ្ឋកិច្ច និងទេសចរណ៍ដ៏សំខាន់

*ក្រុងព្រះសីហនុ: តឹម សារឿន*

ក្រុងព្រះសីហនុ ស្ថិតនៅភាគខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្បូរទៅដោយធនធានធម្មជាតិ តំបន់ភ្នំ សមុទ្រ និងដីប្រកប



មាត់សមុទ្រលំហែកាយ



និមិត្តរូបក្រុងព្រះសីហនុ

ដោយជីជាតិសម្រាប់ប្រកបការងារកសិកម្ម បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋយ៉ាងខ្លាំង ។ ក្រុងដែលនៅជាប់សមុទ្រមួយនេះ ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាតំបន់សេដ្ឋកិច្ច និងទេសចរដ៏ធំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ក្រុងព្រះសីហនុ ស្ថិតនៅតាមបណ្តោយឆ្នេរឆកកំពង់សោម មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពត ខាងជើងជាប់នឹងខេត្តកោះកុង និងខាងត្បូង-ខាងលិចជាប់នឹងឈូងសមុទ្រថៃ ។ គេអាចធ្វើដំណើរតាមផ្លូវជាតិចំនួន២ខ្សែ គឺតាមផ្លូវជាតិលេខ៤ ពីភ្នំពេញចម្ងាយ២៣០គីឡូម៉ែត្រ និងផ្លូវជាតិលេខ៣ ពីខេត្តកំពតចម្ងាយ២៣៨គីឡូម៉ែត្រ និងរថភ្លើងពីភ្នំពេញក៏បានដែរ ។

អ្នកស្រុកដែលរស់នៅតំបន់នោះមានខ្មែរ ចិន ចាម ស្ទួច កួយ និងជនជាតិដទៃទៀត ប្រកបរបរនេសាទ ពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍...។ ភាពអំណោយផលនៃភូមិសាស្ត្រនេះ បានធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើនយ៉ាងខ្លាំងគួបផ្សំនឹងសេវាកម្មដឹកជញ្ជូនល្អ ទាំងផ្លូវគោក ដែក ទឹក និងអាកាស បានទាក់ទាញភ្ញៀវទេសចរឱ្យទៅទស្សនាកាន់តែច្រើន ។

ក្រុងព្រះសីហនុ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៦ មានខណ្ឌចំនួន៣ គឺខណ្ឌមិត្តភាព ស្ទឹងហាវ និងព្រៃនប់ ដោយនៅតាមតំបន់ឆ្នេរសមុទ្រទុកសម្រាប់អភិវឌ្ឍន៍វិស័យទេសចរ កំពង់ផែ និងនេសាទ ។ នៅភាគខាងកើត និងខាងជើងទុកសម្រាប់អភិវឌ្ឍន៍វិស័យឧស្សាហកម្ម សិប្បកម្ម កសិកម្ម និងតំបន់ព្រៃជម្រកសត្វ សួនឧទ្យាន ។

លក្ខណៈពិសេសនៅក្រុងព្រះសីហនុ មានដែនសមុទ្រជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម និងថៃ ដែលមានប្រវែង៥០៧គីឡូម៉ែត្រ លាតសន្ធឹងពីព្រែកត្រពាំងល្ពៅ រហូតដល់ព្រែកថ្សរូង ក្នុងឆកកំពង់សោម ។ ឈូងសមុទ្រទាំងនេះ មានសារសំខាន់ណាស់សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ព្រោះមានឆ្នេរ និងកោះជាច្រើនក្នុងការកសាងកំពង់ផែ ដឹកទំនិញពីបណ្តាប្រទេសនានា មានមច្ឆជាតិគ្រប់ប្រភេទ និងជាកន្លែងទាក់ទាញភ្ញៀវទេសចរពីគ្រប់មជ្ឈដ្ឋាន ។

ដោយសារតែមានឆ្នេរសមុទ្រធំល្វឹងល្វើយ បានផ្តល់ភាពងាយស្រួលចំពោះកំពង់ផែនានា ដូចជាកំពង់ផែចាស់ Old jetty កំពង់ផែស្វយ័ត ក្រុងព្រះសីហនុ ក្រុមហ៊ុនផែស្ងួតកម្ពុជា និងកំពង់ផែប្រេងឥន្ធនៈ ។ ភាពងាយស្រួលទាំងនេះ ដូចជាការដឹកជញ្ជូនទំនិញ ផ្ទេរទំនិញ នាំផលិតផលចេញ-ចូលក្រៅប្រទេស ជាពិសេសនោះ នៅបាតសមុទ្រមានរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិយ៉ាងច្រើនសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ ។ ពេលនេះមានក្រុមហ៊ុនអន្តរជាតិជាច្រើន បានមកធ្វើការដេញថ្លៃ ដើម្បីរុករកប្រេងនៅបាតសមុទ្រ បើតាមការប៉ាន់ស្មានយើងនឹងបានប្រេងរាប់លានធុង ហើយទទួលបានចំណូលរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ ។

ក្រៅពីនេះ ក្រុងព្រះសីហនុមានសហគ្រាសផលិតស្បៀងអាហារ រោងចក្រកាត់ដេរ រោងចក្រស្បែកជើង រោងចក្រស្រាបៀរ សហគ្រាសសិប្បកម្ម និងសេវាកម្មជាច្រើនកន្លែងទៀត ដែលជួយសម្រួលដល់ជីវភាពសេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិទាំងមូល ។

សម្រស់ធម្មជាតិនៃឆ្នេរខ្សាច់ ទឹកសមុទ្រ និងកោះជាច្រើន បានទាក់ទាញភ្ញៀវទេសចរមកពីគ្រប់មជ្ឈដ្ឋានឱ្យទៅទស្សនាក្រុងព្រះសីហនុកាន់តែច្រើន ដើម្បីលំហែកាយ ហើយពួកគាត់បានអួតសរសើរមិនដាច់ពីមាត់ពីសម្រស់ធម្មជាតិនៅទីនោះ ។ តំបន់ទេសចរណ៍នៅទីនោះ មានការរីកចម្រើនខ្លាំងណាស់ គឺភ្ញៀវទេសចរនាំគ្នាទៅទស្សនានៅថ្ងៃបុណ្យ និងថ្ងៃឈប់សម្រាកយ៉ាងច្រើនកុះករ ហើយខេត្តនេះជាប់លំដាប់ថ្នាក់លេខទី៣ បន្ទាប់ពីខេត្តសៀមរាប និងក្រុងភ្នំពេញ ។

តំបន់ទេសចរណ៍សំខាន់ៗនៅក្រុងព្រះសីហនុមានរមណីយដ្ឋានឆ្នេរអូរឈើទាល ឆ្នេរសុខា ឆ្នេរប្រាំពីរជាន់ ឆ្នេរដើមជ្រៃ កោះពោះ ភ្នំលើ និងតំបន់ទឹកស្អាតក្បាលឆាយ ព្រមទាំងតំបន់មួយចំនួនទៀត ដែលមានសម្រស់ល្អត្រកាល ។

លោក សោម ចិន្តា ប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ បានបញ្ជាក់ថា ភ្ញៀវទេសចរ ដែលមកទស្សនាក្រុងព្រះសីហនុកាលពីឆ្នាំ ២០០៧ ប្រមាណ ៣៧ម៉ឺននាក់ គឺកើនឡើង ៣១% ធៀបនឹងឆ្នាំ២០០៦ ហើយក្នុងនោះ មានភ្ញៀវទេសចរអន្តរជាតិ៩ម៉ឺននាក់ ដែលមានការកើនឡើង៤៧% ។

លោក សោម ចិន្តា បានបញ្ជាក់ថា ការដែលភ្ញៀវទេសចរទស្សនាច្រើននោះ ដោយសារភូមិសាស្ត្រអំណោយផលផ្នែកឆ្នេរសមុទ្រល្អ ។ ជាពិសេសនោះ យើងមានសណ្ឋាគារចំនួន៤៨ ស្មើនឹង១៥៧០បន្ទប់ ផ្ទះសំណាក់១០៨កន្លែង ស្មើនឹង១៤៦០បន្ទប់ ភោជនីយដ្ឋានចំនួន៦៨កន្លែង និងឆ្នេរសមុទ្រប្រវែង ១០៦.៥ គីឡូម៉ែត្រ សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ ។

ចំណែកលោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ក៏បានបញ្ជាក់ថា មានភ្ញៀវទេសចរណ៍នៅឆ្នាំ២០០៧ មានការកើនឡើងខ្ពស់ជាងឆ្នាំកន្លងមកប្រមាណ២លាននាក់ ហើយភ្ញៀវមកពីប្រទេសកូរ៉េខាងត្បូងច្រើនជាងគេ បន្ទាប់មកមានជនជាតិជប៉ុន ចិន និងអាមេរិក ។ ភ្ញៀវទេសចរជាតិ និងអន្តរជាតិបានទៅទស្សនាទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាបច្រើនជាងគេ ។

អ្នកស្រុកដែលរស់នៅទីនេះភាគច្រើនប្រកបរបរនេសាទ សេវាកម្មទេសចរណ៍ ពាណិជ្ជករ ដាំដំណាំផ្សេងៗ ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ ។ លើសពីនេះទៅទៀត ក្រុមហ៊ុន ម៉ុងឫទ្ធី បានធ្វើការដាំដំឡូងមី និងដូងប្រេងសម្រាប់ចម្រាញ់យកទៅលក់នៅក្រៅប្រទេស ដែលអាចជួយរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិបានមួយកម្រិត ។

ក្រុងព្រះសីហនុ បានក្លាយជាតំបន់សេដ្ឋកិច្ចចុងក្រោយ៤ ដែលគេរៀបចំឡើងក្នុង ខេត្តកណ្តាល កំពត ស្វាយរៀង កោះកុង បន្ទាយមានជ័យ ។

ក្រុមអ្នកវិភាគថា នៅតំបន់សេដ្ឋកិច្ច ពិសេសនៅកម្ពុជា មានសិទ្ធិរួចពន្ធលើប្រាក់ចំណេញ មិនបង់ពន្ធការនាំចូលឧបករណ៍សំណង់ ឧបករណ៍ផលិត និងការដឹកជញ្ជូន ជួលដីរយៈពេលយូរ ។

តាមសេចក្តីប្រកាសព័ត៌មានមួយពីក្រុមហ៊ុនអភិវឌ្ឍន៍ចិន នៅតំបន់នោះ បានបញ្ជាក់ថា ផែនការសម្រាប់តំបន់សេដ្ឋកិច្ច ពិសេសក្រុងព្រះ-សីហនុ ក្នុងខណ្ឌព្រៃនប់ រួមមានមជ្ឈមណ្ឌលតាំងពិព័រណ៍ហិរញ្ញវត្ថុ មន្ទីរពេទ្យ កន្លែងស្រាវជ្រាវបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលមូលដ្ឋាន ។

លោក ជីមី ហ៊្គ័រ ប្រធានសភាពាណិជ្ជកម្មចិនក្រុងភ្នំពេញ បានឱ្យដឹងថា តំបន់សេដ្ឋកិច្ចថ្មីនេះនឹងផ្តល់នូវការលើកស្ទួយដ៏សំខាន់មួយដល់កម្ពុជាក្នុងការទាក់ទាញវិនិយោគពីក្រៅប្រទេស ។

លោក ជីមី ហ៊្គ័រ បន្តថា តំបន់នេះមិនមែនសម្រាប់តែក្រុមហ៊ុនចិនទេ ក្រុមហ៊ុនមកពីបណ្តាប្រទេសនានាក៏ល្អដែរ ។ គំរោងនេះនឹងធ្វើឱ្យប្រសើរឡើង រវាងទំនាក់ទំនងប្រទេសចិន-កម្ពុជាផងដែរ ៕



# ទុរេនកំពតមានរសជាតិឆ្ងាញ់ និងលក់ដាច់ជាងគេ

***កំពត : សោម សុខុន***

កំពត គឺជាខេត្តមួយដែលសម្បូរទៅដោយបឹងបួ សមុទ្រ ភ្នំ និងប្រាង្គសាទ រមណីយដ្ឋាន សួនសត្វ អាហារសមុទ្រ និងផ្លែឈើសំរាប់ទទួលទានក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យទៅទស្សនាកាន់តែច្រើន ។ ពិសេសនោះ អ្នកស្រុកបានស្រុះស្រួលគ្នាដាំធុរេនកាន់តែច្រើន ដើម្បីដោះស្រាយជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ។

ចំការ នៅភូមិអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត បានមានប្រសាសន៏ថា ប្រកបមុខរបរដាំទុរេន តាំងពីឆ្នាំ១៩៩២ ហើយមានចំការចំនួន២ហិកតា ដែលមានទុរេនចំនួន៩០ដើម កំពុងឱ្យផលទាំងអស់ ។

លោកបានបន្ថែមទៀតថា ប្រជាជនខេត្តកំពតភាគច្រើនរួមទាំងរូបលោកផងដែរ ពេញចិត្តនឹងដាំផ្លែទុរេនខ្លាំងណាស់ ។ ទោះបីវាលំបាកក្នុងការដាំដុះ និងថែរក្សាយ៉ាងណាក៏ដោយ តែវាអាចទទួលនូវប្រាក់ចំណូលខ្ពស់ និងមានភាពងាយស្រួលក្នុងការលក់ដូរ ។ ទុរេន ជាដំណាំដែលរើសដីណាស់ គឺអាចដាំវាបានលើដីក្រហម ដែលលាយល្បាយខ្សាច់ និងគ្មានថ្ម ។



ផ្លែទុរេននៅក្នុងចំការរបស់អ្នកស្រុកកំពត

អ្វីដែលអ្នកទេសចរមិនអាចបំភ្លេចបាននោះ គឺរសជាតិផ្លែទុរេនដ៏ឈ្ងុញឆ្ងាញ់របស់អ្នកស្រុកកំពត ទោះមានប៉ុន្មានក៏លក់អស់ដែរ ។

បច្ចុប្បន្ននេះ ទុរេនកំពតបានក្លាយជាដំណាំពេញនិយមរបស់អ្នកស្រុក ហើយផ្លែទុរេននេះបានធ្វើចរាចរនៅលើទីផ្សារតូចធំទូទាំងប្រទេស ។ ក្នុងចំណោមផ្លែទុរេនកំពត ក៏មាននាំចូលមកពីប្រទេសវៀតណាម ថៃ និងតាមបណ្តាខេត្តនានាដូចជា ខេត្តកំពង់ចាម ក្រុងព្រះសីហនុ ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ។ល។ ប៉ុន្តែ ទុរេនដែលលក់ដាច់ជាងគេ គឺទុរេនដែលនាំចូលមកពីខេត្តកំពត ព្រោះវាមានឱជារសឈ្ងុញឆ្ងាញ់ផ្អែមជាប់មាត់ និងមិនប្រើប្រាស់ជាតិគីមីក្នុងការដាំដុះឡើយ ។

ទុរេន ជារុក្ខជាតិហូបផ្លែម្យ៉ាងមានស្លឹកតូចៗ ដើមវាសាខាមិនសូវជាខ្ពស់ប៉ុន្មានទេ ចំណែកផ្កា របស់វាស្រដៀងនឹងផ្កាគ រីឯផ្លែរបស់វាមានបន្លាច្រើនស្រដៀងនឹងផ្លែខ្នុរ ។ នៅខាងក្នុងវិញ គឺវាចែកចេញជាក្លែបមានច្រើន ឬតិចទៅតាមផ្លែវាធំ ឬ តូចមានសាច់ពណ៌លឿង និងមានរសជាតិផ្អែម ។

ទុរេន ជារុក្ខជាតិពិបាកក្នុងការដាំដុះបន្តិច និងរើសស្ថានភាពដី ព្រមទាំងទាមទារនូវការប្រើប្រាស់បច្ចេកទេសត្រឹមត្រូវ ទើបអាចទទួលបានទិន្នផលខ្ពស់ ។ ទោះបីមានការលំបាកយ៉ាងណាក៏ដោយ ក៏ប្រជាជននៅខេត្តកំពត មិនរុញរាក្នុងការដាំដុះនោះទេ ។ ចំការទុរេន ខេត្តកំពត សម្បូរជាងគេ គឺនៅក្បែររមណីយដ្ឋានទឹកឈូ និងនៅក្បែរភ្នំបូកគោ ។

លោក ខៀវ សារឿន អាយុ៥២ឆ្នាំ ជាម្ចាស់

សព្វថ្ងៃនេះ អ្នកស្រុកអាចទិញកូនទុរេនដែលគេផ្សាំសម្រាប់លក់នៅក្បែរទឹកឈូ មួយដើមតំលៃ១ដុល្លារ ឬអាចយកគ្រាប់ទុរេន ដែលផ្លែវាល្អមកបណ្តុះខ្លួនឯងក៏បាន ។ ប៉ុន្តែក្នុងចំណោមទុរេនដែលផ្សាំ និងបណ្តុះកូន គឺទុរេនផ្សាំឆាប់ឱ្យផ្លែជាងមានអាយុពី៦ខែទៅ៨ឆ្នាំ ទើបចាប់ផ្តើមផ្លែ ។ រីឯការបណ្តុះគ្រាប់វិញរយៈពេល១០ឆ្នាំទើបផ្លែ ហើយវាឱ្យផលរហូតដល់ពី៣០ទៅ៥០ឆ្នាំ ។

ទាក់ទិននឹងបញ្ហាការដាំដុះនេះ លោក ខៀវ សារឿន បានឱ្យដឹងថាគេត្រូវជីករណ្តៅជម្រៅ ១ម x ៤ម ហើយកំណត់ពីរណ្តៅ១ទៅរណ្តៅ១ ចំងាយពីគ្នា៨ទៅ១០ម៉ែត្រ រួចគេប្រមូលសំរាមមកដាក់ក្នុងរណ្តៅឱ្យពេញ រួចដុតវាហើយយកដីដែលនៅជិតមាត់រណ្តៅដាក់ឱ្យជិតពេញ រួចស្រោចទឹកវាឱ្យសើមល្អម ។

ពេលដាំហើយត្រូវធ្វើរបាំងព័ទ្ធជុំវិញកុំឱ្យត្រូវខ្យល់ដោយទុករយៈពេលពីរឆ្នាំ គឺមើលថែទាំកុំមានដង្កូវ និងសត្វល្អិតស៊ី ព្រមទាំងស្រោចទឹកឱ្យជិតដល់ដាក់ជីអាចម៍គោលាយជាមួយអាចម៍ប្រចៀវ ។ នៅពេលបាន៥ ទៅ៦ឆ្នាំ ត្រូវយកលួសមកចងដើមវា ដើម្បីការពារកុំឱ្យខ្យល់បក់រលំទុរេនចាប់ផ្តើមផ្លែ ដោយត្រូវថែរក្សាដោយប្រុងប្រយ័ត្នកុំឱ្យដង្កូវស៊ី បេះផ្កាចុងមែកចោល ព្រោះបើទុកវាផ្លែមិនល្អ ហើយធ្វើឱ្យទន់ដើមទុរេន ។



អាជីវករលក់ទុរេននៅផ្សារអូឡាំពិក

ចាប់ផ្លែពីខែមីនា ដល់ខែកក្កដា ទុរេនកំពត មិនពិបាកក្នុងការលក់ដូរនោះទេ ព្រោះមានអតិថិជន និងឈ្មួញជាច្រើន បានស្គាល់ពីរសជាតិរបស់

( តទៅទំព័រទី៣២ )

# ពីរដ្ឋ "រ៉ូដអាយឡិន"

ដែលបានសឹកជាគ្រហស្ថរួចហើយៗបានទៅនិយាយសារភាពនៅចំពោះមុខគណៈកម្មាធិការវត្ត អំពីករណីដែលព្រះគ្រូចៅអធិការ ជា ឆោម បង្ខំរួមភេទជាមួយខ្លួនជាច្រើនលើកច្រើនសារក្នុងអារ៉ាម (ទាំងក្នុងកុដិ និងក្នុងព្រះវិហារ) ពេលដែលខ្លួននៅជាសង្ឃ ។ ករណីនេះ បានជំរុញឱ្យគណៈកម្មាធិការវត្តធម្មឃោសនារ៉ាម ដែលដឹកនាំដោយលោក កែ ភិរុណ ជាប្រធាន ដែលទើបនឹងជាប់ឆ្នោតថ្មី ធ្វើការកោះប្រជុំសមាជិកគណៈកម្មាធិការរបស់ខ្លួននៅថ្ងៃអាទិត្យទី២០ ខែមករា ដើម្បីធ្វើការសាកសួរជនរងគ្រោះអំពីដំណើររឿង ។ នៅចំពោះមុខសមាជិកគណៈកម្មាធិការលោក យូវឌ្បន៍ សូ បាននិយាយរៀបរាប់យ៉ាងក្បោះក្បាយអំពីដំណោះស្រាយរឿងទាំងអស់ ។ ក្នុងនោះដែរ ប្រធាន និងអនុប្រធាននៃគណៈកម្មាធិការវត្ត គឺលោក កែ ភិរុណ និង លោក សារិន រ័ត្ន ក៏បានឯកភាពថា និងរៀបចំជួបជាមួយព្រះគ្រូចៅអធិការ ជា ឆោម ដើម្បីសាកសួរ និងធ្វើការដោះស្រាយរឿងនេះ ក្នុងគោលបំណងបញ្ចប់ក្តីមន្ទិលសង្ស័យ ហើយរកភាពបរិសុទ្ធឱ្យភាគីទាំងសងខាងផង ។ ក៏ប៉ុន្តែមកដល់ថ្ងៃសុក្រ ទី២៥ ខែមករា ឆ្នាំ២០០៨, ស្រាប់តែមានជំនួបដ៏ស្ងាត់ជ្រងំ ដែលមានគ្នាតែបីនាក់ គឺលោក កែ ភិរុណ, លោក សារិន រ័ត្ន និងព្រះគ្រូចៅអធិការ ជា ឆោម ពុំមាននរណាផ្សេងដឹងរឿងពិតនេះឡើយ សូម្បីតែអគ្គលេខាធិការ ក៏មិនត្រូវបានអនុញ្ញាតិ្តឱ្យដឹងពីការនិយាយគ្នានេះដែរ ?

តាមប្រភពច្បាស់ការណ៍បានឱ្យដឹងថា មុនពេលចេញទៅជួបជាមួយព្រះសង្ឃ ជា ឆោម, លោក កែ ភិរុណ ជាប្រធានគណៈកម្មាធិការហាមមិនឱ្យលោក សារិន រ័ត្ន ដែលជាអនុប្រធាននិយាយ ឬសាកសួររឿងនេះ ទៅព្រះសង្ឃ ជា ឆោម ទេ ។ តែដោយស្មារតីចង់រកយុត្តិធម៌ ជូនជនរងគ្រោះ និងជនដែលត្រូវគេចោទប្រកាន់ លោក សារិន រ័ត្ន បានជំនះនិយាយ និងសាកសួរបានមួយចំនួន ។ ប្រភពដដែលបានបន្ថែមទៀតថា លោក កែ ភិរុណ មិនត្រឹមតែគ្មានជំហររកការពិតទេ គឺថែមទាំងបានទទួលយកនូវសំណូមពរពីរចំណុចពីលោកគ្រូចៅអធិការ ជា ឆោម ទៀតផង គឺ : ១-មិនយករឿងនេះទៅដេញដោលនៅតុលាការ **និង២**-មិនផ្តល់ឱ្យមានការជជែកជាសាធារណៈរវាងជនរងគ្រោះ និងជនសង្ស័យនៅចំពោះមុខសមាជិកវត្ត ។ ភាពអសកម្មរបស់ប្រធានថ្មីរូបនេះ មិនបានធ្វើឱ្យអ្នកដែលបានអះអាងថា ខ្លួនជាជនរងគ្រោះនោះស្ងប់ចិត្តទេ ដូច្នោះហើយទើបលោក យូវឌ្បន៍ សូ ដែលជាជនរងគ្រោះ និងដែលជាសមាជិកគណៈកម្មាធិការវត្តផងដែរនោះ បានសរសេរលិខិតមួយដាក់ចូលទៅក្នុងសម័យប្រជុំ កាលពីថ្ងៃអាទិត្យទី១០ ខែកុម្ភៈ កន្លងទៅនេះ ដោយយោងទៅតាមច្បាប់លក្ខន្តិកៈរបស់វត្ត គឺសំណូមពរឱ្យបង្កើតគណៈកម្មាធិការឯករាជ្យមួយ ដើម្បីធ្វើការដោះស្រាយវិវាទ និងបញ្ចប់បញ្ហា ប៉ុន្តែតាមការផ្តល់ព័ត៌មានពីសំណាក់សមាជិកគណៈកម្មាធិការវត្តបានឱ្យដឹងថា លោក កែ ភិរុណ គឺបានជំទាស់ និងមិនព្រមអនុវត្តតាមលក្ខន្តិកៈរបស់វត្ត ដែលកំពុងស្ថិតនៅជាធរមាននោះទេ ហើយលោកប្រធានថ្មីរូបនេះ ថែមទាំងបង្ហើបពាក្យថាលោកមិនចង់ឱ្យមានរឿងក្នុងពេលដែលលោកទើបនឹងកាន់ដំណែងនោះទេ...? ។

រឿងព្រះគ្រូចៅអធិការវត្តធម្មឃោសនារ៉ាមព្រះឧត្តមសេក្កា ជា ឆោម រួមភេទជាមួយព្រះសង្ឃដូចគ្នានៅក្នុងវត្តនេះ គឺមិនបានបញ្ចប់ដោយយុទ្ធសាស្ត្រ "ហ៊ីនិយម" របស់ប្រធានថ្មីនោះទេ តែនៅខាងក្រៅបែរជាមានពាក្យចរចាមរាមពីប្រភពពីរផ្សេងគ្នា ។ **ប្រភពទី១**បាននិយាយថា គណៈកម្មាធិការវត្តមានបំណងចាប់ផ្សឹកលោកចៅអធិការ ជា ឆោម ទៅវិញ ។ ឯប្រភពទី២បាននិយាយថា លោកចៅអធិការ ជា ឆោម គឺបានបរាជិករួចបាត់ទៅហើយ គ្មានភាពបរិសុទ្ធជាសង្ឃ ដែលត្រូវគោរពទៀតទេ ព្រោះលោក



លោក កែ គិរុណ ប្រធានដែលទើបជាប់ឆ្នោតថ្មី

មានចរិត និងនិស្ស័យចង់តែរួមភេទ មិនថាជាមួយមនុស្សប្រុស ឬមនុស្សស្រី ។

សូមបញ្ជាក់ថា កាលដែលនៅគង់ជាចៅអធិការវត្តពុទ្ធមណ្ឌល ក្នុងក្រុងប្រ៊ូវិដិន ព្រះសង្ឃ ជា ឆោម ត្រូវបានគណៈកម្មាធិការវត្ត ពុទ្ធមណ្ឌល បណ្តេញចេញពីអារ៉ាម ដោយបានចោទថា បរាជិក ព្រោះបង្ខំរួមភេទជាមួយយាយជីនៅក្នុងវត្ត ។ ហើយនេះជាលើកទី២ហើយ ដែលមានមនុស្សជាអតីតព្រះសង្ឃដូចគ្នា បានចេញមុខមកបកអាក្រាតថា ព្រះគ្រូចៅអធិការរូបនេះបានបង្ខំរួមភេទជាមួយខ្លួន ។

ចំពោះអ្នកគាំទ្រ ដែលមានជំហរឯករាជ្យយល់ថា ដើម្បីបញ្ចប់បញ្ហា គណៈកម្មាធិការវត្តត្រូវតែបង្កើតគណៈកម្មាធិការឯករាជ្យមួយ រួចហើយកោះហៅទាំងអ្នកចោទ និងទាំងអ្នកដែលត្រូវបានគេចោទមកឆ្លើយឆ្លងនៅចំពោះមុខសមាជិកវត្ត ដើម្បីរកការពិតឱ្យឃើញ ។ ធ្វើរបៀបនេះ **គឺ១**-លាងភាពស្អាតស្អំ ឱ្យលោកគ្រូចៅអធិការ ជា ឆោម ប្រសិនបើលោកមិនបានប្រព្រឹត្ត **២**-រកយុត្តិធម៌ឱ្យជនរងគ្រោះ និងផ្សឹកព្រះសង្ឃបរាជិក ដែលមិនគោរពធម៌វិន័យ និងមិនបន្តឱ្យពុទ្ធសាសនិកជនថ្វាយបង្គំព្រះសង្ឃដែលមិនបរិសុទ្ធ ។

**<u>កំណត់និពន្ធ</u> : <u>សេរីភាព</u> :**

វត្តជាច្រើនដែលបានផុសឡើងសំរាប់បំរើជំនឿសាសនា មហាជនបានក្លាយទៅជាមណ្ឌលរកស៊ី ឬខិលខូចយ៉ាងគួរឱ្យខ្មាសអៀននៅ សហរដ្ឋអាមេរិកនេះ ។ ព្រះសង្ឃដែលជាអ្នកបង្ហាញពីផ្លូវលះបង់បែរជាមានប្រាក់រាប់លានគ្មានការត្រួតពិនិត្យរកតម្លាភាព ។ នៅវត្តនៃហ្វីឡាដែលហ្វីយ៉ានេះ រឿងអាស្រូវស្រដៀងគ្នាបានកើតឡើង ព្រះសង្ឃជាចៅអធិការកំពុងទទួលទណ្ឌកម្មថ្នាក់ឧក្រិដ្ឋក្នុងពន្ធនាគារ ដោយពុំទាន់មានស្ថាប័នសង្ឃណាមួយផ្សឹកលោកឱ្យស្របវិន័យនៅឡើយទេ ។

គណៈកម្មាធិការវត្តនៅសហរដ្ឋអាមេរិកមានសិទ្ធិធំទូលាយល្អម ធ្វើឱ្យវត្តអារ៉ាមមានវិន័យគ្រប់គ្រាន់បាន ក៏ប៉ុន្តែ **"គេខ្លាចលោកសង្ឃជាងច្បាប់" "ខ្លាចខូចកិត្តិយសជាងបង្ហាញគំរូល្អ" "ខ្លាចគេស្អប់ច្រើនជាងខ្លាចព្រះធម៌"** នេះជាដំណើរដែលសាសនាព្រះពុទ្ធក្នុងសហគមន៍ខ្មែរត្រូវរលាយនាពេលអនាគត ។ វត្តខ្មែរមួយនៅរដ្ឋ ម៉ារីឡែន ក្បែរវ៉ាស៊ិនតោនឌីស៊ី បានបង្ហាញគំរូ ការគ្រប់គ្រងល្អមួយ វត្តមានតិចណាស់ចង់ធ្វើតាមគំរូនោះ ៕

ផ្សារ 186th Market

-ត្រូវការលក់ក្នុងតម្លៃសមរម្យ ដែលផ្សារយើងខ្ញុំមានទំនិញលក់ដូរ ដូចជា: Wine, Beer គ្រឿងទេសផ្សេងៗ ។

សូមទាក់ទងបើលោក-អ្នកចាប់អារម្មណ៍ តាមទូរស័ព្ទលេខ: (310) 515 - 6806

អាសយដ្ឋាន: 18545 S. WESTERN GARDINA , CA 90248

## Oppletree credit.com solution




➪ក្រុមហ៊ុនយើងខ្ញុំរងចាំទទួលជួយ សំរួលកិច្ចការលោក-អ្នកនៅពេល មានបញ្ហាជាមួយ Credit Card.

- ▶ការលួចបន្លំ ID. ▶ID Theft.
- ▶ក្ស័យធន ▶Bankruptcies.
- ▶ការរឹបអូសអចលនៈទ្រព្យ ▶Foreclosures.
- ▶ជំពាក់បំណុលរដ្ឋ ▶Tax Liens.
- ▶បង់សងប្រាក់មិនទៀតទាត់ ▶Late Payments.
- ▶ខូចឈ្មោះ ព្រោះជំពាក់Credit ▶Charge Offs.
- ▶បង់ប្រាក់ដាច់ស្រេចហើយ នៅតែមានឈ្មោះខូច Credit
- ▶Paid Collection.
- ▶ការបន្លំឈ្មោះនៅក្នុង Credit Report
- ▶In Correct Personal Info.
- ▶យើងខ្ញុំត្រូវការបុគ្គលិក ឬភ្នាក់ងារធ្វើការពេញម៉ោង ឬមិនពេញម៉ោង ។

2338 E. Anaheim St., Suite 200, Long Beach, CA 90804
EX23 Office: (562) 433-1130
Fax: (562) 433-1133, E-mail: info@appletreecredit.com

## apple tree Leasing.com

▶សំរាប់លោក-អ្នកដែលនឹងត្រៀមបើកមុខជំនួញ ឬបើកមុខជំនួញរួចហើយក្តី ដោយមិនចង់ចំណាយលុយផ្ទាល់ខ្លួន ក្នុងការទិញសម្ភារៈរៀបចំហាង ឬ រោងចក្រ ដូចជា: ហាង Donut, Chinese Food, Computer Equipment, សម្ភារៈកសិកម្ម សម្ភារៈរោងចក្រ និងគ្រឿងប្រដាប់ប្រដាឡានធំៗដឹកជំនួញ ។

▶សូមលោក-អ្នកមេត្តាទាក់ទងជាមួយក្រុមហ៊ុនយើងខ្ញុំ ដោយក្រុមហ៊ុនយើងមានសម្ភារៈប្រដាប់ប្រដារៀបចំ និងតម្លើងជូនលោក-អ្នក ។

▶សូមកុំឱ្យឱកាសដ៏ល្អសំរាប់របរជំនួញជួញដូររបស់លោក-អ្នកកន្លងផុត ក្រុមហ៊ុនយើងខ្ញុំរងចាំទទួលធ្វើការ និងទំនាក់ទំនងជាមួយលោក-អ្នកជានិច្ច ។

## LENNYBUYSHOUSE.COM

You Sell it ! I buy it !

➪បើសិនលោក-អ្នកចង់ទិញផ្ទាល់ពីក្រុមហ៊ុនយើងខ្ញុំ ដោយមិនចាំបាច់មានប្រវត្តិរូបល្អ, ខូចក្រេឌីត, មិនមានក្រេឌីត ឬមួយមានបញ្ហាខាងការរឹបអូសអចលនៈទ្រព្យ និងក្ស័យធន ។

ដោយលោក-អ្នកគ្រាន់តែមានលុយកាក់បន្តិចបន្តួច ក៏ក្រុមហ៊ុនយើងខ្ញុំអាចជួយឱ្យបានក្នុងការទិញផ្ទះសម្បែងដោយបងថ្លៃផ្ទះប្រចាំខែក្នុងតម្លៃសមរម្យប្រសើរជាងជួលផ្ទះគេ ។

▶Our Company is a Private Real Estate Consultant. We are Helping People Who has Credit Problem, Judgement, Tax Lien, Child Support, Late Payment, Collection, Charge Off, BK Problem, and Foreclosures Situation. We Can Help With-Out Involves Real Estate Brokers, Banks, or Lenders. You are Buying Direct from for Sales by Owner If You're Interested, Please Contact Our Company Also.

2338 E. Anaheim St., Suite 200, Long Beach, CA 90804
Office: (562) 433-1130 Fax: (562) 433-1133

▶ក្រុមហ៊ុនយើងខ្ញុំ ជាក្រុមហ៊ុនផ្នែកវិនិយោគទុន ក្នុង និងក្រៅប្រទេសរកស៊ីបណ្តាក់ទុនក្នុងផ្នែកជំនួញលក់ដូរអចលនៈទ្រព្យ (ផ្ទះ, ដីធ្លី) ។

▶ប្រសិនបើលោក-អ្នកចង់រកស៊ីជាមួយក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាទាក់ទងយើងខ្ញុំ និងសហការរកស៊ីជាមួយគ្នា ដោយភាពស្មោះត្រង់ទៀងទាត់ តាមផ្លូវច្បាប់រដ្ឋ ។

▶We are Seeking Private Investor Who Want to Buy at Discount Wholesale Price.
If You Are Interested Please Contact Office.



# បច្ចុប្បន្នភាពរឿងមិនគួរកើតនៅកម្ពុជា

*តាកែវៈ សម្ផស្ស*

## បងប្អូនពីនាក់យកប្ដីតែមួយ រស់នៅយ៉ាងសុខសាន្ត

ការងាររកស៊ីគេតែតែងចូលហ៊ុនគ្នា ដើម្បីឱ្យកិច្ចការនោះមានភាពងាយស្រួល និងរីកចម្រើន ។ ប៉ុន្តែបើរឿងរ៉ាវស្នេហាវិញ គឺគេកម្រយកចូលគ្នាណាស់ ហើយបើមានក៏ជាស្នេហាឆក់កន្ទ្រៀត និងច្រណែនឈ្នានីសដាក់គ្នាដែរ ។

ដោយឡែកស្នេហាមួយគួរឱ្យចម្លែកនោះ គឺស្ត្រីបីនាក់បងប្អូនរស់នៅភូមិខ្នុរ ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ បានស្រុះស្រួលគ្នាយក ប្ដីតែមួយ ហើយរស់នៅជាមួយគ្នាយ៉ាងសុខសាន្តថែមទៀតផង ។

ស្ត្រីបីនាក់បងប្អូននោះ ទី១-ឈ្មោះ សន យ៉ាន់ អាយុ៥២ឆ្នាំ, ទី២-ឈ្មោះ សន យ៉ុន អាយុ៤៨ឆ្នាំ និង ទី៣-ឈ្មោះ សន យ៉ាប់ អាយុ៣៥ឆ្នាំ ។ ចំណែកបុរសជើងខ្លាំងជាប្ដី ដែលគេល្បីថា ចេះមន្តស្នេហ៍ ឈ្មោះ រស់ ណែម អាយុ៥៣ឆ្នាំ ត្រូវជាបងប្អូនជីដូនមួយនឹងគ្នាទៀត ។

ស្ត្រីឈ្មោះ សន យ៉ាន់ បានឱ្យដឹងថា គាត់មានបងប្អូន៦នាក់ គឺស្រី៣ និងប្រុស៣ ហើយប្អូនស្រីៗរបស់គាត់សុទ្ធតែនៅក្រមុំចាស់គ្មាននរណាចូលថែចូវនោះទេ ។ ទន្ទឹមនឹងនោះប្ដីរបស់គាត់សព្វថ្ងៃនេះ កាលណោះចេះតែចេញចូល និងសម្លក់សម្លឹងពួកគាត់មិនសូវដាក់ភ្នែកឡើយ ។

ស្ត្រី សន យ៉ាន់ បន្តថា នៅយប់មួយនោះ លោក រស់ ណែម បានបបួលខ្ញុំទៅមើលល្ខោនក្នុងវត្ត នៅពេលត្រឡប់មកវិញដល់កន្លែងស្ងាត់ គាត់ក៏ចាប់អោបខ្ញុំពីក្រោយ ហើយក៏និយាយភាសាស្នេហារហូតដល់គាត់ទន់ចិត្ត ។ ខណៈនោះភ្លើងតណ្ហាក៏ចាប់ផុតរោលដល់កំពូលភ្លេចគិតអ្វីទាំងអស់ រហូតក្លាយជាប្ដីប្រពន្ធដល់សព្វថ្ងៃ ។

អ្នកស្រី សន យ៉ុន បានឱ្យដឹងថា គាត់បានធ្លាក់ក្នុងកណ្ដាប់ដៃរបស់លោក រស់ ណែម ដោយសារចាញ់ល្បិចកល និងមន្តស្នេហ៍របស់គាត់ជាពិសេសនឹកស្មានថា បានគ្នាជាប្ដីប្រពន្ធ ។ ប៉ុន្តែនៅពេលក្រោយទើបដឹងថា ប្ដីកំហូចនេះស៊ីទាំងបងស៊ីទាំងប្អូនគ្មានរើសមុខឡើយ ។

រីឯអ្នកស្រី សន យ៉ាប់ បាននិយាយស្រដៀងគ្នានិងបងៗទាំងពីរនាក់ដែរ ដែលលង់ខ្លួនចាញ់បោក រស់ ណែម ។ ពេលនេះគាត់ឈប់ទាក់ទងជាមួយ រស់ ណែម ទៀតហើយ គឺប្រគល់ឱ្យបងស្រីធំផ្ដាច់មុខតែម្ដង ។

បុរស រស់ ណែម ដែលស៊ីមិនរើសមុខបានបងហើយស៊ីប្អូនៗរហូតមានទាំងផ្ទៃពោះទាំងអស់គ្នានោះ បានឱ្យដឹងថា កាលពីដើមគាត់ស្រឡាញ់តែប្រពន្ធទី១ទេ ប៉ុន្តែដោយសារតែតណ្ហាភ្លេចគិតពីច្បាប់ទម្លាប់ប្រពៃណី ក៏ទៅសាករសជាតិប្អូនៗទៀត ។ ពេលនោះចាស់ទុំបានរៀបចំគាត់ឱ្យយកប្រពន្ធទី១ ចំណែកប្រពន្ធទី២ និងទី៣លែងទាក់ទងគ្នាហើយ ប៉ុន្តែដំណក់ឈាមនៅតែតិតតូរដដែល ។

ស្នេហាចតុកោណខាងលើនេះ ត្រូវបានអ្នកស្រុករិះគន់យ៉ាងខ្លាំងថា ទង្វើរបស់ រស់ ណែម ខ្វះការពិចារណាធ្វើឱ្យប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណី និងកិត្តិយសរបស់ក្រុមគ្រួសារថែមទៀត ។ ទង្វើបែបនេះ បើច្បាប់មិនជួយទប់ស្កាត់នោះទេ សីលធម៌សង្គមខ្មែរនឹងធ្លាក់ចុះកាន់តែខ្លាំង ហើយមនុស្សជំនាន់ក្រោយនឹងយកគំរូតាមមិនខានឡើយ ៕

## ជាច់របបយូរចាប់កូនរំលោភ

*តាកែវៈ សម្ផស្ស*

មនុស្សយើងខុសពីសត្វត្រង់ មានការពិចារណាស្គាល់ល្អ-អាក្រក់ មានប្រាជ្ញាឈ្លាសវៃ ចេះស្រឡាញ់ប្រពន្ធកូន ថែរក្សាការពារឱ្យមានអនាគតល្អ ។ ចំណែកឪពុកតិរច្ឆានចាប់រំលោភកូនដើម្បីបំពេញតណ្ហានោះ ត្រូវបានអ្នកស្រុកភូមិជ្រៃ ឃុំជម្ពូវ័ន្ត ស្រុកជុំគីរី ខេត្តតាកែវ ដាក់បណ្ដាសារយ៉ាងខ្លាំង ព្រោះតែគ្មានគុណធម៌ជាឪពុក ។

អ្នកស្រី ចាប ខន អាយុ៥០ឆ្នាំ រស់នៅភូមិឃុំកើតហេតុខាងលើបានរៀបរាប់ទាំងទឹកមុខក្រៀមក្រំថា ប្ដីរបស់គាត់ឈ្មោះ មាឃ ស៊ុប អាយុ៥១ឆ្នាំ និងមានកូន៩នាក់ ចំណែកកូនស្រីដែលរងគ្រោះឈ្មោះ ស.ឃ អាយុ១៨ឆ្នាំ ជាកូនទី៤ ។

អ្នកស្រី ចាប ខន បានបន្តថា មួយរយៈនោះគាត់មានជំងឺធ្លាក់ស និងឈឺស្បូន មិនអាចរួមដំណេកជាមួយប្ដីបានទេ ។ ដោយសារកាលពីមុនគាត់រួមរ័កញឹកញាប់ពេក ។ សព្វថ្ងៃខ្ញុំ និងគាត់ត្រូវចែកបន្ទប់គ្នាដេក ជាហេតុធ្វើឱ្យគាត់មិនអាចទប់អារម្មណ៍បាន ហើយចាប់កូនស្រីឯងរំលោភបែបនោះ ។

កូនស្រីរងគ្រោះ ស.ឃ បានឱ្យដឹងថា នាងធ្លាប់ទៅជាមួយឪពុករកត្រី កង្កែប នាពេលយប់នៅឯវាលស្រែ ហើយនៅយប់ខែមករា ឆ្នាំ ២០០៨ ឪពុករបស់នាងបានបង្ខំឱ្យនាងដោះសំលៀកបំពាក់ រួចចាប់រំលោភរហូតបានសំរេច ទោះបីជានៅពេលនោះនាងមិនព្រមយ៉ាងណាក៏ដោយ ហើយបានគំរាមសម្លាប់ និងមិនឱ្យនិយាយប្រាប់នរណាឡើយ ។

កូនស្រីរងគ្រោះបានបន្តថា ក្រោយពីរំលោភនាងបានម្ដងហើយ គាត់តែងតែបង្ខំឱ្យនាងទៅឆ្មុះកង្កែបជាមួយគាត់ទៀត ដោយពេលខ្លះចាប់រំលោភនាងនៅលើភ្លឺស្រែ គុម្ពោតព្រៃយ៉ាងសាហាវបំផុត ។ ពេលណានាងយំគាត់គំរាមសម្លាប់មិនឱ្យនិយាយប្រាប់នរណាទេ ដោយខ្លាចគាត់វាយធ្វើបាប គឺចេះតែទ្រាំទាំងឈឺចាប់ខ្លោចផ្សា ពេលខ្លះនាងអង្គុយសំរក់ទឹកភ្នែកតែម្នាក់ឯងទាំងមិនដឹងខ្លួន ។

កូនស្រីរងគ្រោះបានបន្តទៀតថា ដោយឃើញសកម្មភាពព្រៃផ្សៃរបស់ឪពុកមកលើខ្លួន ម្ដងហើយម្ដងទៀតបែបនេះ ។ នាងក៏សំរេចចិត្តទៅប្ដឹងប៉ូលិសឱ្យចាប់ខ្លួនគាត់តាមច្បាប់ បើសិនបណ្ដោយបែបនេះបន្តទៀត នាងនឹងមានផ្ទៃពោះមិនខាន ហើយប្អូនស្រីក៏រងគ្រោះបន្តទៀតដែរ ។

កម្មតាមចងពៀរបុរសជាឪពុកត្រូវសមត្ថកិច្ចតាមចាប់ឃាត់ខ្លួនផ្ដន្ទាទោសនៅពន្ធនាគារ ចំណែកក្រុមគ្រួសាររបស់កូនស្រីរងគ្រោះ ក៏ទទួលនូវពាក្យនិន្ទាពីសំណាក់អ្នកភូមិមិនតិចដែរ ដោយសារតែឪពុកតិរច្ឆានរូបនេះ ៕




CLE
CHHAYLEE ENTERTAINMENT
Part 3
ស្តេច
ជូមឹង
Jumong
Tel: 562-253-2458
Jumong
Jumong

# SPP VIDEO & GIFT SHOP







## ហាងសិលាផ្កាយព្រឹកវីដេអូ និងលក់វត្ថុអនុស្សាវរីយ៍

-ក្រុមហ៊ុនសិលាផ្កាយព្រឹក (SILA PKAY PREK VIDEO ) បានបើកហាងលក់ជុំ,ភាយ,និងជួលកុន ជូនដល់អតិថិជនពីក្រុមហ៊ុនយើងខ្ញុំ , ក្រុមហ៊ុនថៃសេង និងក្រុមហ៊ុន (SILA PKAY PREK VIDEO ) ផងដែរ ។

-ហាងយើងខ្ញុំក៏មានលក់នូវសំលៀកបំពាក់ ស្បែកជើង វត្ថុក្មេងលេង កាបូបរៀន ខោអាវកូនសិស្ស និងវត្ថុអនុស្សាវរីយ៍ផ្សេងៗទៀត ។

សូមអញ្ជើញដោយមេត្រីភាពពីហាងសិលាផ្កាយព្រឹកយើងខ្ញុំ ចាប់បើកពីថ្ងៃនេះតទៅហើយ ។











1001E Pacific Coast Hwy, Ste 125
Long Beach, CA 90806 , Cell: (562) 682 2544


BELMONT SHORE TRAVEL
ក្រុមហ៊ុនទេសចរណ៍ និងលក់សំបុត្រយន្តហោះ
•យើងខ្ញុំរីករាយក្នុងការបំរើសេវាជូន
លោកអ្នកអាចទិញ និង ទទួលសំបុត្រយន្តហោះបានភ្លាមៗមួយរំពេច ។
តម្លៃសំបុត្រទៅកាន់ប្រទេសកម្ពុជាសមរម្យមិនថ្លៃមិនថោក ។
EVA Airline
Cathay pacific Airline
China Airline
ប្រភេទយន្តហោះ Boeing ថ្មីទំនើប , បំរើភ្ញៀវដោយហ្មត់ចត់ ដែលធ្វើឱ្យលោកអ្នកមិនខុសបំណងឡើយ !
ក្រុមហ៊ុនយើងខ្ញុំជួយសំរួល និងយកចិត្តទុកដាក់រាល់កិច្ចការដែលទាក់ទងនឹងការធ្វើដំណើរសំរាប់លោកអ្នកប្រកបដោយសុវត្ថិភាពគ្មានការភ័យព្រួយ ។
បើលោកអ្នកមាន Green Card ហើយមានអាសន្ន ឬបន្ទាន់ក្នុងករណីណាដែលត្រូវធ្វើដំណើរទៅកាន់ស្រុកខ្មែរ សូមទាក់ទងយើងខ្ញុំដោយរងចាំតែពីរសប្តាហ៍តែប៉ុណ្ណោះ ។
EVA AIR
777-300ER
ទទួលធ្វើ :
លិខិតឆ្លងដែនខ្មែរបន្តឆ្នាំ លិខិតឆ្លងដែនខ្មែរ ដែលផុតកំណត់
Cambodia passport , Cambodia passport Extension
Notary Public
744 Redondo Ave
Long Beach , CA 90804
1-800 - 732 - 9363
Phone : (562) 439-2129
FAX : (562) 439- 2550
belmontshoretravel@charter.net
www. belmontshoretravel.net
M-F : 9:00AM - 6:00 PM
SAT : 10:00 AM - 4:00PM

# M.L.K MARKET និងលក់សំបុត្រយន្តហោះ

## យើងខ្ញុំមានលក់សំបុត្រយន្តហោះគ្រប់ក្រុមហ៊ុន











- ហាងខ្មែរលក់ទំនិញមានសំលៀកបំពាក់ជាឯកសណ្ឋានសិស្ស (Uniform), រឿងកុនថៃ, ចិន, កូរ៉េ ផ្នែកមនោសញ្ចេតនា បាញ់ប្រហារ កាប់ចាក់ និងក្បាច់គុណបុរាណ កំពុងចេញលក់ថ្មីៗ មានបកប្រែជាភាសាខ្មែរ ។
- ហាងខ្មែរ M.L.K ក៏មានកន្លែងលក់ទឹកផងដែរ ។
- ហាងយើងខ្ញុំក៏មានលក់ដូរនូវសំលៀកបំពាក់ជាច្រើនផ្នែកទៀត ទាំងសំភារៈផ្ទះបាយ, សំភារៈដំណេក, សំភារៈបន្ទប់ទឹក និងឧបភោគគ្រឿងទេស, ភេសជ្ជៈជាដើម ។

## ទទួលយក Card EBT







## មានលក់ Phone Card

សូមអញ្ជើញជាមួយហាងថ្មីយើងខ្ញុំដោយរីករាយ

**ហាងយើងខ្ញុំមានលក់កុនថៃពីក្រុមហ៊ុនមយូរា**

**1821 M.L.K.JR Ave, Long Beach, CA 90806**
**Tel: (562) 591-4295**



First AMERICAN TEAM
REALTY
Mr. Monorom Neth
Licensed Realtor
2501 Cherry Ave.,#100 • Signal Hill, CA 90755
Office (562) 427-7765 Ext.333
Cell (562) 483-7333 Fax (562) 427-0767




ALL TRANSMISSION & CLUTCH
complete Auto RePair
- Engine
- Tune Up
- Brakes
Rebuild
Automatic Transmission (Front Wheel Drive & Over Drive ) MANUAL Transmission
ALL TRANSMISSIONS & CLUTCH
494-6968
TRANSMISSION PARTS
MOTOR TUNE-UP
(562)494-6968
2800E .PCH Hwy . Long Beach , CA 90804




HILLSIDE CHIROPRACTIC & REHAB CENTER
AUTO COLLISION . WORK INJURY . SPORT INJURY
មន្ទីរពេទ្យចាប់សរសៃ
Dr. Rene Uong D.C
Receptionist
Alfredo Munoz Jr., LMT Massage Therapy
Dr. Hanh Bullee, D.C.
Dr. Rene E.Uong
FULL SERVICE TREATMENT
▸Personal Injury /Sports Injury
▸Wellness Care ▸Work Related Injuries
▸Chronic Care ▸Chiropratic Care
▸Chronic Pain Syndromes
▸Physical Therapy
▸Customize Rehabilitation ▸Massage Therapy
▸Program ▸Complete physical Exams
▸Posture/Body Mechanics ▸Athletes-DMV / DOT
▸Per / Post Operation Care ▸Nutritional Analysis
▸Neck and Back School
▸Auto Accident Care Specialist
▸Therapy Products
CHIROPRACTIC IS PROVEN EFFECTIVE IN THE TREATMENT OF MANY COMMON AILMENTS INCLUDING...
▸Headaches ▸Neck Pain ▸Back Pain
▸Shoulder and Arm Pain ▸Leg Pain ( Sciatica )
▸Carpal Tunnel Syndrome
▸Numbness & Tingling
▸And Many Other Common Health Issues
▸Joint Stiffness ▸Muscle Spasms ▸Disc Herniation
▸Scoliosis ▸Low Energy ▸Stress
2760E. SPRING STREET, SUITE 150 , LONG BEACH, CA 90806
PHONE : (562) 424-1200, FAX : (562) 424-1214




ភោជនីយដ្ឋាន សុភី
Sophy's CAMBODIAN & THAI CUISINE
3720E. Anaheim St., 102 . Long Beach, CA 90804
Tel: (562) 494-1763 Delivery FREE with Purchase of $15.00 or More